# លទ្ធផល
# ការសង្កេតសភា និងតំណាងរាស្ត្រ

## របាយការណ៍ឆ្នាំទី២ នីតិកាលទី៤(តុលា ២០០៩- កញ្ញា២០១០)










*គណបក្សរំលាយអសនៈ សមាជិកភាព នឹងត្រូវបាត់បង់*

*ការប្រកាន់និន្នាការនយោបាយ ហាក់ជាឧបសគ្គក្នុងការបង្កើតក្រុម តំណាងរាស្ត្រស្ត្រី*







ខែសីហា ឆ្នាំ២០១២

ផលិតដោយៈខុមហ្វ្រែល COMFREL

# លទ្ធផល
# ការសង្កេតសភា និងតំណាងរាស្ត្រ

**មតិក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងពីជំហររបស់ម្ចាស់ជំនួយ និងដៃគូឡើយ ។**

**រូបថតក្របមុខ៖** ការចុះមូលដ្ឋានរបស់តំណាងរាស្ត្របានមកពីគណបក្សនយោបាយ និងវ៉ែបសាយ របស់គណបក្សនយោបាយ

## ឧបត្ថម្ភដោយ


ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@comfrel.org, comfrel@online.com.kh

គេហទំព័រ: www.comfrel.org

# មាតិកា


**បុព្វកថា** ........ 1

**លទ្ធផលនៃការសង្កេតដោយសង្ខេប** ........ 3

**អនុសាសន៍** ........ 6

**សភា និងតំណាងរាស្ត្រ** ........ 8

**១. ដំណើរការសម័យប្រជុំពេញអង្គរដ្ឋសភា** ........ 8

*តួលេខ ១៖ប្រៀបធៀបចំនួនកិច្ចប្រជុំ និងចំនួនអ្នកតំណាងរាស្ត្រជាមធ្យមចូលរួមក្នុង១កិច្ចប្រជុំ* ........ 8

*តួលេខ ២៖ ៖ អត្រាកំណើនជា%នៃវត្តមានអ្នកតំណាងរាស្ត្រតាមគណបក្សចូលរួមក្នុង១កិច្ចប្រជុំធៀបនឹងឆ្នាំសង្កេតមុន (តុលា ២០០៩-កញ្ញា ២០១០ ធៀប កញ្ញា ២០០៨ - កញ្ញា ២០០៩)* ........ 9

*តួលេខ ៣៖ ៖ ប្រៀបធៀបរបៀបវារៈតាមប្រភេទរវាងឆ្នាំ ២០០៨-២០០៩ និងឆ្នាំ ២០០៩-២០១០* ........ 10

**១.១. ការបញ្ចេញមតរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា** ........ 10

*តួលេខ ៤៖ កំណើនសេចក្ដីព្រាងច្បាប់ កិច្ចប្រជុំ និងការបញ្ចេញមតិក្នុងឆ្នាំ២០១០ធៀបនឹង២០០៩* ........ 11

*តួលេខ ៥៖ ភាគរយតំណាងរាស្ត្រឡើងបញ្ចេញមតិធៀបនឹងតំណាងរាស្ត្រសរុបក្នុងបក្សខ្លួន* ........ 12

**១.២. ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា** ........ 12

*តួលេខ ៦៖ចំនួនតំណាងរាស្ត្រ និងរយៈពេលបញ្ចេញមតិតាមគណបក្ស* ........ 12

**១.៣. ខ្លឹមសារនៃការបញ្ចេញមតរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប** ........ 13

*តួលេខ ៧៖ ចំនួននាទី និងភាគរយខ្លឹមសារព្យាក្រឹតតាមគណបក្សនៃការបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រ* ........ 13

*តួលេខ ៨៖ខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្សធៀបនឹងរយៈពេលសរុបរបស់គណបក្ស* ........ 14

*តួលេខ ៩៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអព្យាក្រឹតតាមគណបក្ស* ........ 14

*តួលេខ ១០៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបវិជ្ជមានតាមគណបក្ស* ........ 15

*តួលេខ ១១៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអវិជ្ជមានតាមគណបក្ស* ........ 15

**១.៤. ខ្លឹមសារការបញ្ចេញមតរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស** ........ 15

*តួលេខ ១២៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា* .. 16

*តួលេខ១៣៖ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា* ........ 16

*តួលេខ ១៤៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី* ........ 17

*តួលេខ១៥៖ ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី* ........ 17

*តួលេខ១៦៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម* ........ 18

*តួលេខ ១៧៖ ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សជាតិនិយម*......18
*តួលេខ ១៨៖ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច*......19
**១.៥. ខ្លឹមសារបញ្ចេញមតរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនៅលើតួអង្គស្ថាប័ននិងចំនុចផ្សេងៗ**......19
*តារាងទី១៖គុណភាពការបញ្ចេញមតិរបស់សមាជិកសភាតាមគណបក្សនយោបាយទាំងបីលើចំណុចសំខាន់ៗមួយចំនួន (គិតជានាទី)*. ......19
*តួលេខ ១៩៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សាតាមគណបក្ស*......21
*តួលេខ ២០៖ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស ទៅលើរបៀបវារៈពិភាក្សា (សេចក្តីព្រាងច្បាប់)*......21
*តួលេខ ២១៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរាជរដ្ឋាភិបាលតាមគណបក្ស*......22
*តួលេខ២២៖ ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្សទៅលើរាជរដ្ឋាភិបាល*......23
*តួលេខ ២៣៖ ៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្សទៅលើតំណាងរាស្ត្រដទៃទៀត*......24
*តារាងទី២៖ ការប៉ាន់ប្រមាណគុណភាពការបញ្ចេញមតិរបស់តំណាងរាស្ត្រ ១០រូប ដែលឈានមុខគេក្នុងការបញ្ចេញមតិ*......25
**១.៦. គុណភាពនៃការពិភាក្សា និងអនុម័តរបៀបវារៈ**......26
**១.៧. សេចក្តីព្រាងច្បាប់សំខាន់ៗត្រូវបានអនុម័តហើយបន្សល់នូវភាពចម្រូងចម្រាស**......27
**២. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ**......32
**២.១. ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន**......32
*តួលេខ ២៥៖ កំណើនចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន និងចំនួនចុះមូលដ្ឋានជា% ធៀងនឹងឆ្នាំ២០០៨-២០០៩*......32
*តួលេខ ២៦៖ចំនួន និងភាគរយតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងចុះមូលដ្ឋានសរុប*......33
*តួលេខ ២៧៖ភាគរយនៃអាសនៈរដ្ឋសភា និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុបតាមគណបក្ស*......33
*តួលេខ ២៨៖ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន*......34
*តួលេខ ២៩៖ ចំនួន នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុបតាមគណបក្ស*......34
**២.២. គោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ**......35
*តួលេខ៣០៖ ភាគរយនៃគោលបំណងនីមួយរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស ធៀបនឹងគោលបំណងសរុបតាមគណបក្ស*......35
*តារាងទី ៣ ៖ ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង*......36
*តួលេខ៣១៖កំណើនជាភាគរយចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងធៀបនឹងឆ្នាំ២០០៨-២០០៩*......41
*តារាងទី៤៖ រាយនាមអ្នកតំណាងរាស្ត្រសកម្មជាងគេ១០រូបដែលបានចុះមូលដ្ឋានច្រើនជាងគេ (រៀបតាមលំដាប់ពីច្រើនទៅតិចចាប់ពីថ្ងៃទី០១តុលា២០០៩ដល់ថ្ងៃទី៣០កញ្ញា២០១០)*......41

**២.៣. គោលបំណងចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមគណបក្សនយោបាយនីមួយៗ** ........ 42
*តួលេខ ៣២៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតាមគោលបំណងនីមួយៗ* ........ 43
*តួលេខ ៣៣៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ីតាមគោលបំណងនីមួយៗ* ........ 43
*តួលេខ ៣៤៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សតាមគោលបំណងនីមួយៗ* ........ 44
*តួលេខ ៣៥៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សជាតិនិយមតាមគោលបំណងនីមួយៗ* ........ 44
*តួលេខ ៣៦៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចតាមគោលបំណងនីមួយៗ* ........ 45
**២.៤. មណ្ឌលរាជធានី-ខេត្តនានាដែលអ្នកតំណាងរាស្ត្របានចុះ** ........ 45
*តួលេខ ៣៧៖ ភាគរយចុះមូលដ្ឋានក្នុង និងក្រៅមណ្ឌលធៀបនឹងចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស* ........ 45
*តួលេខ ៣៨៖ មណ្ឌលរាជធានី-ខេត្តដែលតំណាងរាស្ត្របានចុះ* ........ 46
**២.៥.ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី-ខេត្ត** ........ 46
**៣. ការចេញលិខិតអរបស់អ្នកតំណាងរាស្ត្រ** ........ 48
*តារាងទី ៥ ៖ ឈ្មោះអ្នកតំណាងរាស្ត្រទាំង ១៤ រូបដែលបានចេញលិខិត និងគោលបំណងនៃលិខិត* ........ 48
**៤. អ្នកតំណាងរាស្ត្រស្ត្រី** ........ 50
**៤.១. ការចូលរួមប្រជុំពេញអង្គរបស់អ្នកតំណាងរាស្ត្រស្ត្រី** ........ 51
**៥. ព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ** ........ 52
បន្តការអនុវត្តន៍ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភាដែលមិនស៊ីសង្វាក់តាមច្បាប់ដែលមានស្រាប់ ........ 52
អ្នកតំណាងរាស្ត្រស្ត្រីចង់បង្កើតក្រុមតំណាងរាស្ត្រស្ត្រី ........ 55
គណបក្សរំលាយអាសនៈតំណាងរាស្ត្របាត់បង់ ........ 56
អ្នកតំណាងរាស្ត្រសមរង្ស៊ីត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ១២ឆ្នាំ ........ 57
**ឧបសម្ព័ន្ធទី១ : ការប៉ាន់ប្រមាណគុណភាពនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រ** ........ 59
**ឧបសម្ព័ន្ធទី២ : សេចក្តីព្រាងច្បាប់ និងរបៀបវារៈដែលបានពិភាក្សានិងអនុម័តក្នុងសម័យប្រជុំសភា** ........ 61
**ឧបសម្ព័ន្ធទី៣ : នាមអ្នកតំណាងរាស្ត្រម្នាក់ៗដែលបានចុះមូលដ្ឋាន** ........ 64
**ឧបសម្ព័ន្ធទី ៤៖ គោលបំណង កម្មវត្ថុ វិធីសាស្ត្រ** ........ 71
**ឧបសម្ព័ន្ធទី ៥៖ ទម្រង់សង្កេតសម័យប្រជុំរដ្ឋសភា** ........ 74
**ឧបសម្ព័ន្ធទី ៦៖ ទម្រង់សង្កេតការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ** ........ 77

សញ្ញាសម្គាល់គណបក្សប្រើប្រាស់ក្នុងរបាយការណ៍នេះ

| **ផ្លាកសញ្ញា** | **ឈ្មោះ និងអក្សរកាត់** |
|---|---|
| | គណបក្សប្រជាជនកម្ពុជា (គ.ប្រ.ជ) |
| | គណបក្សហ្វ៊ុនស៊ិនប៉ិច (គ.ហ.ស.ប) |
| | គណបក្សសមរង្ស៊ី (គ.ស.រ) |
| | គណបក្សជាតិនិយម (គ.ជ.ន) |
| | គណបក្សសិទ្ធិមនុស្ស (គ.ស.ម) |

# បុព្វកថា

នេះគឺជាឆ្នាំទី២ ហើយក្នុងនីតិកាលទី៤ ដែលខុមហ្វ្រែលបានធ្វើការសង្កេតសភា និងតំណាងរាស្ត្រហើយចេញរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដែលជាលទ្ធផលនៃការសង្កេត និងវិភាគពីសភា និងតំណាងរាស្ត្រក្នុងចន្លោះពីខែតុលា ឆ្នាំ ២០០៩ ដល់ខែកញ្ញា ឆ្នាំ២០១០។

ក្នុងរបាយការណ៍សង្កេតឆ្នាំនេះ បន្ថែមទៅលើការវិភាគទៅលើការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៅសម័យប្រជុំពេញអង្គ ដំណើរការរបស់ស្ថាប័នរដ្ឋសភា និងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រខុមហ្វ្រែល និងធ្វើការប្រៀបធៀបពីលទ្ធផលឆ្នាំសង្កេតនេះ ទៅនឹងលទ្ធផលឆ្នាំសង្កេតចាស់។ ខ្លឹមសារពិភាក្សា និងការដេញដោលគ្នាក្នុងសម័យប្រជុំរដ្ឋសភាទៅលើសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួនដែលត្រូវបានអនុម័តក្នុងឆ្នាំសង្កេតនេះ ក៏ត្រូវបង្ហាញក្នុងរបាយការណ៍។ ព័ត៌មានសំខាន់ទាក់ទងនឹងតំណាងរាស្ត្រក៏ត្រូវយកបង្ហាញ និងវិភាគផងដែរ។

ការសង្កេតជារួមក្នុងឆ្នាំនេះ គឺបង្ហាញថា បញ្ហានានាដែលអ្នកតំណាងរាស្ត្រប្រឈមតាំងពីឆ្នាំសង្កេតមុន គឺមិនត្រូវបានដោះស្រាយ ដូចជាការកំណត់ចំនួនអតិបរមាសម្រាប់ក្រុមឡើងបញ្ចេញមតិ ភាពងាយស្រួលក្នុងការដកអភ័យឯកសិទ្ធិ និងរចនាសម្ព័ន្ធគ្រងគ្រងស្ថាប័នរដ្ឋសភាជាដើម។

របាយការណ៍ឆ្នាំសង្កេតនេះ នឹងនៅតែជាប្រភពឯកសារ ដែលម្ចាស់ឆ្នោតអាចប្រើប្រាស់ដើម្បីថ្លឹងថ្លែង និងវាយតម្លៃសកម្មភាពតំណាងរាស្ត្រទាំងក្នុងសម័យប្រជុំសភា និងការចុះទៅមូលដ្ឋាន និងស្ថានភាពក៏ដូចជាបរិយាកាសដែលកើតឡើងចំពោះអ្នកតំណាងរាស្ត្រ ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកក្រោយៗ និងពង្រឹងគណនេយ្យភាព និងការទទួលខុសត្រូវរបស់អ្នកតំណាងរាស្ត្រ ឬគណបក្សជាប់ឆ្នោត។ របាយការណ៍នេះក៏ជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់អ្នកសិក្សា ឬអ្នកស្រាវជ្រាវដែលទាក់ទិនសភា និងអ្នកតំណាងរាស្ត្រផងដែរ។ ជាពិសេស គឺការបង្ហាញពីនិន្នាការប្រែប្រួលនៃសកម្មភាពរបស់តំណាងរាស្ត្រពីមួយឆ្នាំ ទៅមួយឆ្នាំ។

ក្នុងការវិភាគលទ្ធផលសង្កេត ខុមហ្វ្រែលបានខិតខំប្រមូលទិន្នន័យ និងព័ត៌មានដើម្បីវិភាគ និងរៀបចំរបាយការណ៍នេះដោយឈរលើជំហរអព្យាក្រឹត និងមិនលម្អៀង ហើយរបាយការណ៍នេះក៏អាចឆ្លុះបញ្ចាំងពីទិន្នន័យពិតជាក់ស្តែងដែលទទួលបាន។

ទិន្នន័យទាំងនោះយោងទៅសកម្មភាពរបស់អ្នកតំណាងរាស្ត្រ រួមមានការចុះមូលដ្ឋាន ការចេញលិខិតអន្តរាគមន៍នានាឲ្យបានច្រើនបំផុតតាមដែលអាចទៅរួច ក៏ប៉ុន្តែចំនួននេះ គឺអាចតិចជាងចំនួនជាក់ស្តែងដែលតំណាងរាស្ត្រទាំងអស់បានធ្វើសកម្មភាព។ ប្រភពព័ត៌មានដែលខុមហ្វ្រែលទទួលបានទាក់ទងនឹងសកម្មភាពនានារបស់អ្នកតំណាងរាស្ត្ររួមមាន ការសង្កេតដោយផ្ទាល់ ការយកព័ត៌មានពីការិយាល័យតំណាងរាស្ត្រតាមរាជធានី/ខេត្ត ការយកព័ត៌មានពីសាខាគណបក្សជាប់ឆ្នោតទាំងអស់នៅរាជធានី/ខេត្ត ការប្រមូលព័ត៌មានពីវេបសាយរបស់គណបក្សជាប់ឆ្នោត ពីអ៊ីម៉ែល (Email) ការប្រមូលព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ និងការប្រមូលព័ត៌មានពីតំណាងរាស្ត្រផ្ទាល់ដែលបានផ្តល់ឲ្យ។

ខុមហ្វ្រែលក៏សូមថ្លែងអំណរគុណចំពោះអគ្គលេខាធិការដ្ឋានរដ្ឋសភា សមាជិក សមាជិកាមួយចំនួន ព្រមទាំងអ្នកតំណាងរាស្ត្រមួយចំនួន ដែលបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធក្នុងការផ្តល់ព័ត៌មានផ្សេងៗទាក់ទិននឹងសកម្មភាពរបស់ខ្លួន និងបង្កឱ្យការងារសង្កេតនេះប្រព្រឹត្តទៅដោយជោគជ័យ។

សមាសភាពក្រុមការងារក្នុងការប្រមូល ចងក្រង និងវិភាគឲ្យចេញជារបាយការណ៍ឆ្នាំនេះ រួមមានលោក សុខ ពិទូរ្យ កញ្ញា គង់ រ៉ាវីន លោក កន សាវ៉ាង្ស កញ្ញា លី ម៉ាលីន លោក មី សុភក្រ្តា កញ្ញា កែម ចន្ថា ព្រមទាំងអ្នកសម្របសម្រួល លេខាធិការ និងបណ្តាញរាជធានី/ខេត្តរបស់ខុមហ្វ្រែលនៅទូទាំងប្រទេស។

ជាចុងក្រោយ ខុមហ្វ្រែលសូមថ្លែងអំណរគុណចំពោះម្ចាស់ជំនួយជាច្រើន ដូចជា EU, , Oxfam NOVIB, Forum Syd, NPA និង UNDEF ដែលបានបន្តជួយគាំទ្រ និងឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសម្រាប់ដំណើរការកម្មវិធីសង្កេតសភា និងតំណាងរាស្ត្រ ព្រមទាំងការចងក្រងការបោះពុម្ពកម្រងឯកសារនេះ។

របាយការណ៍ គឺជាការរកឃើញការវិភាគ និងមតិរបស់ខុមហ្វ្រែល ប៉ុន្តែវាមិនឆ្លុះបញ្ចាំងពីទស្សនៈ និងមតិរបស់ម្ចាស់ជំនួយ និងដៃគូអង្គការសហការ សមាជិកដែលសហការជាមួយខុមហ្វ្រែលនេះទេ។

**គល់បញ្ញា**

នាយកប្រតិបត្តិនៃគណៈកម្មាធិការខុមហ្វ្រែល

## លទ្ធផលនៃការសង្កេតដោយសង្ខេប

នៅក្នុងឆ្នាំទី២នៃការសង្កេតនេះ រចនាសម្ព័ន្ធនៃរដ្ឋសភាដែលប្រធាន អនុប្រធានទាំង២នៃរដ្ឋសភា គណៈកម្មការអចិន្ត្រៃយ៍ ប្រធាន និងអនុប្រធានទាំង៩នៃគណៈកម្មការជំនាញរបស់រដ្ឋសភា គឺនៅតែក្រោមការក្តោបក្តាប់ពីគណបក្សប្រជាជនកម្ពុជា។ គឺគណបក្សកាន់អំណាចដែលមានសម្លេងភាគច្រើននោះ នៅតែបន្តកាន់កាប់តំណែងដឹកនាំទាំងអស់នៅក្នុងរដ្ឋសភា ដោយផាត់ចេញតំណាងរាស្ត្រដែលមានសម្លេងច្រើនបន្ទាប់ៗ។

សមាជិកគណៈកម្មការទាំង៩នៃរដ្ឋសភា នៅតែមិនមានវត្តមានរបស់តំណាងរាស្ត្រគណបក្សជំទាស់ សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សដែលទទួលបានអាសនៈច្រើនលំដាប់ទី២ និងទី៣។

បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ប្រការ៤៨ថ្មី(ពីរ) នៅតែជាឧបសគ្គមិនអាចឲ្យអ្នកតំណាងរាស្ត្រមកពីគណបក្សបានសម្លេងតិចជាង១០ បង្កើតបានក្រុមរបស់ខ្លួន១។ ហើយប្រការ៤៨ថ្មី (ពីរ)នេះ នៅតែមិនទាន់ត្រូវបានធ្វើវិសោធនកម្មធានាសិទ្ធិបញ្ចេញមតិរបស់គណបក្សមានអាសនៈតិចជាង១០។ ជាលទ្ធផល តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សនៅតែមិនអាចបញ្ចេញមតិបានក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា ចំណែកតំណាងរាស្ត្រគណបក្សជាតិនិយម និងហ៊្វុនស៊ិនប៉ិចនៅតែបន្តចូលជាមួយក្រុមឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា។

ក្រៅពីការរកឃើញខាងលើ ដែលដូចនឹងការរកឃើញក្នុងឆ្នាំសង្កេតមុន លទ្ធផលសង្កេតក្នុងឆ្នាំនេះ បង្ហាញពីការកើនឡើងនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គ ការកើនឡើងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ និងការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ។

**ការប្រជុំពេញអង្គរដ្ឋសភា៖** ក្នុងឆ្នាំសង្កេតនេះ រដ្ឋសភាបានបើកសម័យកាលប្រជុំទី៣ និងទី៤របស់ខ្លួន ក្នុងនោះរួមមាន ប្រជុំវិសាមញ្ញចំនួន២ដងផងដែរដោយបានធ្វើការកោះប្រជុំសរុបចំនួន៣៧ព្រឹក/ប្រជុំ។ ក្នុងកិច្ចប្រជុំទាំង៣៧ព្រឹក រដ្ឋសភាបានពិភាក្សា និង/ឬអនុម័តរបៀបវារៈសរុបចំនួនសរុបចំនួន៣៥។ ក្នុងនោះ របៀបវារៈចំនួន២៩តម្រូវឲ្យមានការពិភាក្សា និង/ឬការអនុម័ត ដូចជាសេចក្តីព្រាងច្បាប់ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ការដកអភ័យឯកសិទ្ធិ។ ចំណែករបៀបវារៈចំនួន៦ទៀត គឺទាក់ទងនឹងការប្រកាសទទួលស្គាល់តំណាងរាស្ត្រថ្មី/ការផ្លាស់ប្តូរតំណាងរាស្ត្រ...ដែលគ្មានការពិភាក្សា និងអនុម័តនោះទេ។ល។ នៅក្នុងកិច្ចប្រជុំទាំង៣៧ដងនោះ ជាមធ្យមក្នុងមួយកិច្ចប្រជុំមានអ្នកតំណាងរាស្ត្រចូលរួមប្រជុំប្រមាណ៩៧រូប គឺមិនបានបង្កការខ្វះកូរ៉ុមសម្រាប់ការប្រជុំពេញអង្គសភានោះទេ។

ក្នុងចំណោមរបៀបវារៈដែលតម្រូវឲ្យមានការអនុម័ត គឺរដ្ឋសភាបើកឲ្យមានការពិភាក្សាតែរបៀបវារៈចំនួន២៤ប៉ុណ្ណោះ ទាក់ទងនឹងសេចក្តីព្រាងច្បាប់ រួមទាំងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង និងសន្ធិសញ្ញានានាផងដែរ។ ចំណែករបៀបវារៈ៥ផ្សេងទៀត គឺរដ្ឋសភាអនុម័តដោយគ្មានការពិភាក្សាទាក់ទងនឹងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់សមាជិករាជរដ្ឋាភិបាល និងការដកអភ័យឯកសិទ្ធសភាជាដើម។

ការបញ្ចេញមតិ ការពិភាក្សា និងការអនុម័តសេចក្តីព្រាងច្បាប់របៀបវារៈផ្សេងៗ៖ នៅក្នុងឆ្នាំសង្កេតនេះ មានរបៀបវារៈចំនួន២៤ប៉ុណ្ណោះមានការពិភាក្សា។ មានអ្នកតំណាងរាស្ត្រសរុប៤៦រូប មកពីគណបក្ស៤ ដែលបានបញ្ចេញមតិបាន៣០៧ដង ប្រើរយៈពេលសរុប៣១៣២នាទី ស្មើនឹង៥២ម៉ោង១២នាទី ។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូប នៅតែមិនអាចបញ្ចេញមិតបានដដែល។

ក្នុងចំណោមតំណាងរាស្ត្រដែលបានបញ្ចេញមតិ មានអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាចំនួន២៧រូប ឬ៥៩%នៃតំណាងរាស្ត្រដែលបានបញ្ចេញមតិទាំង៤៦រូប ខណៈគណបក្សនេះមានអាសនៈក្នុងសភាសរុប៧៣% (៩០

អាសនៈ)។ គណបក្សសមរង្ស៊ីចំនួន១៧រូប ឬ៣៧%នៃតំណាងរាស្ត្រដែលបានបញ្ចេញមតិ គណបក្សនេះមានអាសនៈសរុប២១% ឬ២៦អាសនៈ។ តំណាងរាស្ត្រគណបក្សជាតិនិយម និងហ្វ៊ុនស៊ិនប៉ិចមាន១រូបដូចគ្នានៃតំណាងរាស្ត្រ២រូបដូចគ្នា ឬម្នាក់២%។

រយៈពេលនៃការបញ្ចេញមតិ គឺត្រូវនាំមុខដោយតំណាងរាស្ត្រគណបក្សសមរង្ស៊ីដែលបញ្ចេញមតិបាន១៨២៩នាទី ស្មើនឹង៥៩%នៃរយៈពេលបញ្ចេញមតិសរុប៣១៣២នាទី។ តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជាបញ្ចេញមតិបាន ១១៩៩នាទី ស្មើនឹង៣៨%នៃរយៈពេលសរុប ចំណែកគណបក្សជាតិនិយមបាន៩០នាទី និងគណបក្សហ្វ៊ុនស៊ិនប៉ិចបាន ១៤នាទី។

ខ្លឹមសារអ្នកតំណាងរាស្ត្របញ្ចេញមតិ ត្រូវបានបែងចែកជាអព្យាក្រិត វិជ្ជមាន និងអវិជ្ជមានទៅលើតួអង្គ ឬប្រធានបទផ្សេងៗដែលអ្នកតំណាងរាស្ត្របាននិយាយទៅដល់។ អ្នកតំណាងរាស្ត្រភាគច្រើនបញ្ចេញមតិ ក្នុងន័យអព្យាក្រិត ២០១៤នាទី ឬ៣៣ម៉ោង៣៤នាទី ឬ៦៤%នៃការបញ្ចេញមតិសរុប។ ដោយឡែកក្នុងន័យអវិជ្ជមាន គឺ៧២៧នាទី ១២ម៉ោង៧នាទី ឬ២៣% ក្នុងនោះភាគច្រើនធ្វើឡើងដោយតំណាងរាស្ត្រគណបក្សសមរង្ស៊ីដែលមាន៥៧៧នាទី ៩ម៉ោង៣៧នាទី ចំណែកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាប្រហែល២ម៉ោង១៦នាទី។

តំណាងរាស្ត្របញ្ចេញមតិក្នុងន័យវិជ្ជមាន ចំពោះសេចក្តីព្រាងរបស់រដ្ឋាភិបាល គឺ៣៩១នាទី ឬ ៦ម៉ោង៣១នាទី ក្នុងនោះភាគច្រើន គឺធ្វើឡើងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលមាន២៧៧នាទី ឬ៤ម៉ោង៣៧នាទី ខណៈ ដែលតំណាងរាស្ត្រគណបក្សសមរង្ស៊ីបាន១ម៉ោង៣៦នាទី បញ្ចេញមតិភាគច្រើនអវិជ្ជមាន និងអព្យាក្រិត (នៅកណ្តាល)។

បើធៀបកិច្ចប្រជុំសរុបទាំង៣៧លើក និងរបៀបវារៈដែលបានអនុម័តទាំង២៩បង្ហាញថា ជាមធ្យមក្នុងរបៀបវារៈមួយត្រូវបានអនុម័តក្នុងចន្លោះ១ ទៅ២កិច្ចប្រជុំ។

ដោយឡែក បើធៀបកិច្ចប្រជុំសរុបទាំង៣៧លើក និងសេចក្តីព្រាងច្បាប់ រួមទាំងកិច្ចព្រមព្រៀងទាំង២៤ និងរយៈពេលបញ្ចេញមតិបង្ហាញថា ជាមធ្យមសេចក្តីព្រាងច្បាប់មួយត្រូវបានពិភាក្សា និងអនុម័តក្នុងចន្លោះពី១ ទៅ២កិច្ចប្រជុំ ដែលក្នុងអំឡុងពេលពិភាក្សានោះ មានអ្នកតំណាងរាស្ត្របញ្ចេញមតិប្រមាណ១៣ដង ប្រើរយៈពេលសរុបប្រមាណ១៣០ នាទី (២ម៉ោង ១០នាទី)។

ក្នុងឆ្នាំសង្កេតឆ្នាំនេះ ដូចឆ្នាំមុនដែរ គឺរដ្ឋសភាបានអនុម័តរបៀបវារៈទាំងអស់តាមខ្លឹមសារដើម ដោយគ្មានការកែប្រែខ្លឹមសារឡើយ។

ការសង្កេតរបស់ខុមហ្វ្រែលក៏រកឃើញដូចឆ្នាំមុនដែរថា អ្នកតំណាងរាស្ត្រភាគច្រើនធ្វើការគាំទ្រ ឬមិនគាំទ្រទៅលើរបៀបវារៈទៅតាមគោលជំហររបស់គណបក្សរបស់ខ្លួន។

**ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ៖** ក្នុងឆ្នាំសង្កេតនេះមានអ្នកតំណាងរាស្ត្រសរុប១០៩រូប ក្នុងចំណោម១២៣រូបមកពីគ្រប់គណបក្សជាប់ឆ្នោតបានចុះមូលដ្ឋានសរុប១៧២១លើក ឬជាមធ្យមក្នុងមួយខែអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប១៤៣លើក ឬមួយថ្ងៃមានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានប្រមាណ៥លើក។

ក្នុងចំណោមតំណាងរាស្ត្រដែលចុះមូលដ្ឋាន មានអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន៧៩រូប ឬ៧២% នៃតំណាងរាស្ត្រសរុបទាំង១០៩ ដែលបានចុះមូលដ្ឋាន (គណបក្សនេះមានអាសនៈក្នុងរដ្ឋសភា៧៣% ឬ៩០អាសនៈ/រូប) ចុះមូលដ្ឋានសរុបបាន៩៧៥លើក។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន២៤រូប ឬ២២% នៃតំណាងរាស្ត្រសរុបដែលចុះមូលដ្ឋាន (គណបក្សនេះមានអាសនៈសរុប២១% ឬ២៦អាសនៈ/រូបលើក)។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូប ឬប្រមាណ៣% នៃតំណាងរាស្ត្រដែលបានចុះមូលដ្ឋាន (គណបក្សនេះមានអាសនៈក្នុងរដ្ឋសភា២% ឬ៣អាសនៈ/រូប) ចុះមូលដ្ឋានសរុបបាន៣៣៦លើក។ តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច និងជាតិនិយមរួមគ្នាមាន៣រូបចុះសរុបបាន១៤លើក។ ទិន្នន័យនេះបង្ហាញថា ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានតាមគណបក្ស និងភាគរយអាសនៈ/តំណាងរាស្ត្រដែលគណបក្សមាននៅក្នុងរដ្ឋសភា គឺស្មើរតែសមាមាត្រគ្នា។

បើគិតជាមធ្យមភាគនៃចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋាន និងចំនួនដងនៃការចុះមូលដ្ឋានឃើញថាជាមធ្យមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា១រូបចុះមូលដ្ឋានសរុបបានប្រមាណ ១២ ដង ក្នុង១ឆ្នាំ ។ តំណាងរាស្ត្រ គណបក្សសមរង្ស៊ីបានប្រមាណ១៧លើក ។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបាន១១២លើក ។ តំណាងរាស្ត្រគណបក្ស ហ៊្វុនស៊ីនប៉ិច១រូប ចុះបាន ៤លើក ចំណែកតំណាងរាស្ត្រគណបក្សជាតិនិយម១រូបចុះបាន ៧លើក ។

គោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានបែងចែកជា៥ គឺទី១. ចុះសួរសុខទុក្ខ រួមមានការចែកអំណោយ សម្ពោធសមិទ្ធផលនានា សរុបបាន៩៤១លើក។ ទី២. ការចុះមូលដ្ឋានដើម្បីពង្រឹងបណ្ដាញគណបក្សរបស់ខ្លួន រួមទាំងការប្រជុំឬវេទិកាដែលចាត់ចែកដោយគណបក្សខ្លួនឯង សរុប៥៩៨លើក។ ទី៣. ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំសរុប១០១លើក។ ទី៤. ការចូលរួមវេទិកា/សិក្ខាសាលាសាធារណៈ ដែលចាត់ចែងដោយភាគីផ្សេងដូចជាអង្គការ NGO សរុប៤៦លើក។ និងទី៥. ចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានា (អន្តរាគមន៍) សរុប៣៥លើក។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ផ្ដោតខ្លាំងការចុះមូលដ្ឋានរបស់ខ្លួនក្នុងគោលបំណងសួរសុខទុក្ខដែលសរុបមាន៦៧៥លើក។ ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ី និងសិទ្ធិមនុស្សផ្ដោតខ្លាំងលើការពង្រឹងបណ្ដាញគណបក្សរបស់ខ្លួន ក្នុងនោះ គណបក្សសមរង្ស៊ីមាន១៨៩លើក និងសិទ្ធិមនុស្សមាន២២៣លើក។

ការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍បញ្ហាជូនប្រជាពលរដ្ឋភាគច្រើនធ្វើឡើងដោយតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន២០លើក និងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា១៣លើក។

**ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ៖** មានតំណាងរាស្ត្រសរុបចំនួន១៤រូប ដែល១៣រូបមកពីគណបក្សសមរង្ស៊ី និង១រូបមកពីគណបក្សសិទ្ធិមនុស្សបានចេញលិខិតសរុបចំនួន៧៤ ច្បាប់ជូនរាជរដ្ឋាភិបាល និងជូនស្ថាប័នពាក់ព័ន្ធនានា។ ចំនួនលិខិតនេះ មានការកើនឡើងជាងឆ្នាំសង្កេតមុន២៨% ឬ១៦លិខិត។ លិខិតភាគច្រើនដែលតំណាងរាស្ត្របានចេញគឺក្នុងគោលបំណងស្នើបន្តឲ្យស្ថាប័នរាជរដ្ឋាភិបាលចាត់វិធានការ ឬអន្តរាគមន៍ទៅលើបញ្ហានានាដែលអ្នកតំណាងរាស្ត្របានប្រមូលព័ត៌មាន និងបានទទួលពីម្ចាស់ឆ្នោតដែលលិខិតក្នុងគោលបំណងនេះ មានរហូតដល់៥៥លិខិត ក្នុងគោលបំណងអន្តរាគមន៍ដោយផ្ទាល់(គឺដាក់លិខិតទៅភាគីដែលមានបញ្ហាដោយផ្ទាល់) មាន១០លិខិត និងការស្នើឲ្យរាជរដ្ឋាភិបាលមកបំភ្លឺផ្ទាល់មាត់នៅរដ្ឋសភាមានចំនួន៧លិខិត និងការដាក់សំណួរដល់រាជរដ្ឋាភិបាលមាន២លិខិត។

ក្នុងឆ្នាំសង្កេតនេះ ខុមហ្វ្រែលទទួលបានព័ត៌មានថា ក្នុងចំណោមលិខិតទាំង៧៤ គឺមានលិខិតតែ២២ (គឺប្រមាណ ៣០%) ប៉ុណ្ណោះដែលមានការឆ្លើយបតពីរាជរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធ។

**អ្នកតំណាងរាស្ត្រស្ត្រី៖** ចំនួនអ្នកតំណាងរាស្ត្រស្ត្រីមិនមានការកើន និងថយចុះទេ គឺមានចំនួនថេរ២៦រូប ស្មើនឹង ២១%នៃចំនួនសមាជិកសភាសរុប១២៣រូប ដែលក្នុងនោះ ៦រូបមកពីគណបក្ស សមរង្ស៊ី និង២០រូបទៀតមកពីគណក្ស ប្រជាជនកម្ពុជា។

រឿងក្តីក្តាំរបស់អ្នកតំណាងរាស្ត្រជំទាវ មូរ សុខហួរ និងនាយករដ្ឋមន្ត្រីត្រូវបានបញ្ចប់ក្នុងខែសីហា ឆ្នាំនេះ ដោយតំរូវឲ្យអ្នកតំណាងរាស្ត្រស្ត្រី មូរ សុខហួរ ត្រូវបង់ពិន័យសងជំងឺចិត្តសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរាជរដ្ឋាភិបាលចំនួន១៦.៥លានរៀល តាមរយៈការកាត់ប្រាក់ខែរដ្ឋសភារបស់គាត់។ អ្នកតំណាងរាស្ត្រ មូរ សុខហួរ ត្រូវរង់ចាំរហូតដល់ ៣ ឆ្នាំទើបទទួលបានអភ័យឯកសិទ្ធិរបស់គាត់បានវិញ។

ចំណែកការប្រជុំពេញអង្គរបស់អ្នកជាស្ត្រីវិញ គឺមានការចូលរួមយ៉ាងសកម្ម និងមានការកើនឡើងជាងឆ្នាំមុន ដែលចំនួននេះ មាន៧៣% ធៀបនឹងតំណាងរាស្ត្រស្ត្រីសរុប ជិតប្រហាក់ប្រហែលនឹងភាគរយរបស់អ្នកតំណាងរាស្ត្របុរស៨០% ដែលបានចូលរួមការប្រជុំធៀបនឹងចំនួនតំណាងរាស្ត្រសរុប។

ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រស្ត្រីក៏មានការកើនឡើងដែរ គឺមានអ្នកតំណាងរាស្ត្រ១២រូប(៤៦%នៃអ្នកតំណាងរាស្ត្រស្ត្រីសរុប) បញ្ចេញមតិបាន៩ម៉ោង និង៥៧នាទីក្នុងកិច្ចប្រជុំ៣៧លើក គឺកើនចំនួន៣ដង។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី ក៏មានការកើនឡើងដែរ គឺកើន១៦%ធៀបនឹងឆ្នាំមុន(២០០៨-២០០៩) ដែលមានអ្នកតំណាងរាស្ត្រីចំនួន២២រូប បានចុះមូលដ្ឋានចំនួន៤៥៦លើកស្មើនឹង២៦%នៃចំនួនចុះមូលដ្ឋានសរុប១៧២១ លើក។

## អនុសាសន៍

- **រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋសភា៖** ខុមហ្វ្រែលសូមបន្តផ្តល់អនុសាសន៍ ដូចមានក្នុងរបាយការណ៍ឆ្នាំសង្កេតមុន ដោយតួនាទីថ្នាក់ដឹកនាំរដ្ឋសភា រួមទាំងសមាជិកក្នុងគណៈកម្មការជំនាញក្នុងរដ្ឋ គួរត្រូវបានបែងចែកក្នុងចំណោមគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា។
- **ការបង្កើតក្រុមឡើងបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គ៖** អស់រយៈពេល២ឆ្នាំ ហើយដែលតំណាងរាស្ត្រមកពីគណបក្សតិចជាង១០អាសនៈ មិនអាចបង្កើតក្រុមបញ្ចេញមតិឯករាជ្យដោយខ្លួនឯង ហើយតំណាងរាស្ត្រខ្លះត្រូវបាត់បង់សិទ្ធិបញ្ចេញមតិរបស់ខ្លួន និងខ្លះទៀតត្រូវទៅចូលរួមជាមួយគណបក្សដទៃ ដែលជាគូប្រកួតប្រជែងដណ្តើមអំណាចរបស់ខ្លួន។ *ខុមហ្វ្រែលនៅបន្តសូមផ្តល់អនុសាសន៍ឲ្យវិសោធនកម្មប្រការ៤៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដោយអនុញ្ញាតឲ្យគណបក្សដែលទទួលបានអាសនៈតិចជាង១០ អាចបង្កើតក្រុមបញ្ចេញមតិរបស់ខ្លួនបាន១។*
- **តម្លាភាព និងការចូលរួមពីម្ចាស់ឆ្នោតនៅក្នុងគណៈកម្មការជំនាញរដ្ឋសភា៖** ការសង្កេតបង្ហាញថា ការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នៅសម័យប្រជុំពេញអង្គ គឺគ្រាន់តែជាវេទិកាបង្ហាញឲ្យល្អមើលតែប៉ុណ្ណោះ ដោយគ្រប់របៀបវារៈទាំងអស់ត្រូវបានអនុម័តជានិច្ច។ ទាំងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងរដ្ឋសភាសុទ្ធតែបានលើកឡើងថា សេចក្តីព្រាងច្បាប់ ត្រូវបានពិភាក្សាយ៉ាងស៊ីជម្រៅនៅក្នុងគណៈកម្មការជំនាញរដ្ឋសភា មុននឹងចូលដល់សម័យប្រជុំពេញអង្គដើម្បីរដ្ឋសភាអនុម័ត។ នៅខណៈដែលសម័យប្រជុំពេញអង្គបើកទូលាយឲ្យមានការចូលរួមសង្កេតពីម្ចាស់ឆ្នោត ការពិភាក្សានៅក្នុងគណៈកម្មការជំនាញបែរជាការសម្ងាត់ទៅវិញ និងមិនបើកឲ្យមានការចូលរួមសង្កេត

ការណ៍ទៅវិញ។*ខុមហ្វ្រែលសូមផ្តល់អនុសាសន៍ឲ្យរដ្ឋសភាបើកទូលាយ ឲ្យមានការចូលរួមសង្កេតការណ៍ រាល់ការពិភាក្សាសេចក្តីព្រាងច្បាប់/ស្នើច្បាប់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា ដើម្បីបង្កើនការចូលរួមរបស់ម្ចាស់ឆ្នោតទៅលើសេចក្តីព្រាងច្បាប់ និងតម្លាភាពក្នុងការពិភាក្សា។*

# សភា និងតំណាងរាស្ត្រ

## តុលា ២០០៩ កញ្ញា ២០១០

### ១. ដំណើរការសម័យប្រជុំពេញអង្គរដ្ឋសភា

**ចំនួនកិច្ចប្រជុំក្នុងសម័យប្រជុំពេញអង្គ៖**ក្នុងឆ្នាំទី ២ (តុលា ២០០៩ - កញ្ញា ២០១០) នៃការសង្កេតនេះ រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួនចំនួន២លើក រួមមានសម័យប្រជុំលើកទី៣(ចន្លោះពីខែតុលា ដល់ធ្នូ ឆ្នាំ២០០៩) និងសម័យប្រជុំលើកទី៤ (ចន្លោះពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០១០)។ រដ្ឋសភាក៏បានកោះប្រជុំវិសាមញ្ញចំនួនពីរដង គឺទី១ ចន្លោះសម័យប្រជុំទី៣ និងទី៤ នាទី២ចន្លោះសម័យប្រជុំលើទី៤និងទី៥។ រដ្ឋសភាមានការប្រជុំសំងាត់មួយដងទាក់ទងនឹងការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រសម រង្ស៊ី។

ក្នុងសម័យប្រជុំទាំងពីរលើកនេះ មានកិច្ចប្រជុំចំនួន៣៧កិច្ចប្រជុំ ដោយកិច្ចប្រជុំនីមួយៗមានរយៈពេល១ព្រឹក[1]។

ក្នុងឆ្នាំសង្កេតនេះ ចំនួនកិច្ចប្រជុំពេញអង្គរដ្ឋសភាមានការកើនឡើងជាងឆ្នាំមុនប្រមាណ៦១%(ឆ្នាំមុន៖ កញ្ញា ២០០៨- កញ្ញា ២០០៩ មានកិច្ចប្រជុំ២៣ដង)។ កំណើននៃកិច្ចប្រជុំនេះ ក៏ដោយសារក្នុងឆ្នាំសង្កេតនេះ រដ្ឋសភាបានទទួលសេចក្តីព្រាងច្បាប់ រួមទាំងកិច្ចព្រមព្រៀងច្រើនពីរាជរដ្ឋាភិបាលដែលសភាបានពិភាក្សា និងអនុម័តមាន២៤អត្ថបទ (ឆ្នាំមុនមានចំនួន១៧អត្ថបទ)។

**វត្តមានអ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំ៖** នៅខណៈចំនួនកិច្ចប្រជុំមានការកើនឡើងធៀបនឹងឆ្នាំមុន ចំនួនអ្នកតំណាងរាស្ត្រចូលរួមក្នុងកិច្ចប្រជុំបែរជាធ្លាក់ចុះខ្លះៗក្នុងឆ្នាំសង្កេតនេះ។

នៅក្នុងឆ្នាំសង្កេតនេះ ចំនួនអ្នកតំណាងរាស្ត្រជាមធ្យមចូលរួមក្នុងមួយកិច្ចប្រជុំមាន៩៧រូបមានការធ្លាក់ចុះប្រមាណ ២% ធៀបនឹងឆ្នាំមុនដែលមានតំណាងរាស្ត្រចូលប្រជុំជាមធ្យម៩៩ រូប។

ដូចឆ្នាំសង្កេតមុនៗដែរ រដ្ឋសភាក្នុងឆ្នាំសង្កេតនេះមិនបានជួបឧបសគ្គខ្វះកូរ៉ុមសម្រាប់កិច្ចប្រជុំរបស់ខ្លួននោះទេ ដោយសារគណបក្សប្រជាជនកម្ពុជាមានតំណាងលើសគ្រប់គ្រាន់ដើម្បីដំណើរការកិច្ចប្រជុំរដ្ឋសភា។

*<u>តួលេខ ១៖ប្រៀបធៀបចំនួនកិច្ចប្រជុំ និងចំនួនអ្នកតំណាងរាស្ត្រជាមធ្យមចូលរួមក្នុង១កិច្ចប្រជុំ</u>*




---

[1]មានតែកិច្ចប្រជុំពីរលើកដែលមានរយៈពេល១ថ្ងៃពេញ៖កិច្ចប្រជុំថ្ងៃ៣០ តុលា ២០០៩ ស្តីពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ និងកិច្ចប្រជុំថ្ងៃ១០មីនា ២០១០ ស្តីពីសេចក្តីព្រាងច្បាប់ការប្រឆាំងអំពើពុករលួយ។

*<u>តួលេខ ២៖ ៖ អត្រាកំណើនជា%នៃវត្តមានអ្នកតំណាងរាស្ត្រតាមគណបក្សចូលរួមក្នុង១កិច្ចប្រជុំធៀបនឹងឆ្នាំសង្កេតមុន (តុលា ២០០៩-កញ្ញា ២០១០ ធៀប កញ្ញា ២០០៨ - កញ្ញា ២០០៩)</u>*




ក្នុងចំណោមវត្តមានទាំង៩៧រូប ជាមធ្យមមានអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាប្រមាណ៧៣រូប (ឆ្នាំមុនមាន៧៦រូប)។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានប្រមាណ១៩រូប (ឆ្នាំមុនមាន១៨រូប) អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានចំនួន២រូប (ឆ្នាំមុនមាន២រូបដែរ) អ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចមាន២រូប (ឆ្នាំមុនមាន១រូប) និងគណបក្សជាតិនិយមមាន១រូប (ឆ្នាំមុនមាន២រូប)។

**ការពិភាក្សា និង/ឬអនុម័តសេចក្តីព្រាងច្បាប់/ស្នើច្បាប់ និងរបៀបវារៈផ្សេង៖** រដ្ឋសភាបានលើករបៀបវារៈសរុបចំនួន៣៥ ក្នុងសម័យប្រជុំពេញអង្គសាមញ្ញ និងវិសាមញ្ញលើកទី៣ និងទី៤។ ក្នុងនោះរបៀបវារៈចំនួន២៩ ដែលតម្រូវឲ្យមានការពិភាក្សា និង/ឬការអនុម័តដូចជាសេចក្តីព្រាងច្បាប់ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ការដកអភ័យឯកសិទ្ធិ។ ចំណែករបៀបវារៈចំនួន៦ទៀតគឺទាក់ទងនឹងការការប្រកាសទទួលស្គាល់តំណាងរាស្ត្រថ្មី/ការផ្លាស់ប្តូរតំណាងរាស្ត្រ...ដែលគ្មានការពិភាក្សា និងអនុម័តនោះទេ។ល។

ទោះបីយ៉ាងណា ការសង្កេតឃើញថា ក្នុងចំណោមរបៀបវារៈដែលតម្រូវឲ្យមានការអនុម័ត គឺរដ្ឋសភាបើកឲ្យមានការពិភាក្សាតែរបៀបវារៈចំនួន២៤ប៉ុណ្ណោះ ទាក់ទងនឹងសេចក្តីព្រាងច្បាប់ រួមទាំងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង និងសន្ធិសញ្ញានានាផងដែរ។ ចំណែករបៀបវារៈ ៥ផ្សេងទៀតគឺរដ្ឋសភាអនុម័តដោយគ្មានការពិភាក្សាក្នុងប្រជុំពេញអង្គទាក់ទងនឹងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់សមាជិករាជរដ្ឋាភិបាល និងការដកអភ័យឯកសិទ្ធសភាជាដើម។ របៀបនៃការអនុម័តពិតជាមិនស្របតាមរដ្ឋធម្មនុញ្ញនិងបទបញ្ជាផ្ទៃក្នុងរបស់សភា។

របៀបវារៈក្នុងឆ្នាំសង្កេតនេះភាគច្រើន គឺទាក់ទងនឹងសេចក្តីព្រាងច្បាប់ ដែលខុសពីឆ្នាំមុនដែលភាគច្រើនគឺទាក់ទងនឹងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ឬមិនមែនសេចក្តីព្រាងច្បាប់ដោយសារតែជាឆ្នាំដំបូងនៃនីតិកាលទី៤ដែលមានការផ្លាស់ប្តូរតំណាងរាស្ត្រ និងការកែប្រែសមាជិករាជរដ្ឋាភិបាល។

*<u>តួលេខ ៣៖ ៖ ប្រៀបធៀបរបៀបវារៈតាមប្រភេទរវាងឆ្នាំ ២០០៨-២០០៩ និងឆ្នាំ ២០០៩-២០១០</u>*




របៀបវារៈទាំង៣១ក្នុងឆ្នាំសង្កេតនេះរួមមាន សេចក្តីព្រាង/ស្នើច្បាប់ចំនួន១៨ កិច្ចព្រមព្រៀងចំនួន១០ និងផ្សេងដូចជាការបំភ្លឺនៅរដ្ឋសភា និងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៣។ រដ្ឋសភាក្នុងឆ្នាំសង្កេតនេះ បានពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់សំខាន់ៗមួយចំនួន ដូចជាសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ សេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ស្តីពីអាស្សាមិករណ៍ (ការដកហូតទ្រព្យស្របច្បាប់ដោយរដ្ឋ) និងសេចក្តីព្រាងច្បាប់ស្តីពីការផ្តល់កម្មសិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស។

ទោះបីយ៉ាងណា សេចក្តីព្រាងច្បាប់ទាំងនេះ មិនបានទទួលការគាំទ្រទាំងស្រុងពីតំណាងរាស្ត្រមកពីគ្រប់គណបក្សនោះទេ ហើយក៏បន្សល់ទុកនូវភាពចម្រូងចម្រាសខ្លះៗផងដែរ ក្នុងអំឡុងពេលពិភាក្សា (ភាពចម្រូងចម្រាសមាននៅក្នុងចំនុច ២ ទាក់ទងនឹងការបញ្ចេញមិតរបស់អ្នកតំណាងរាស្ត្រ)។

**១.១. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា**

ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រត្រូវបានរាប់ជាលើក ពេលដែលអ្នកតំណាងរាស្ត្របានឡើងបញ្ចេញមតិម្តងៗ ហើយនិងវាស់រយៈពេលដែលឡើងបញ្ចេញមតិនោះដោយគិតជានាទី។ ការសង្កេតនេះ ក៏វិភាគទៅលើខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញក្នុងសម័យប្រជុំផងដែរ។

ក្នុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រមកពី៤គណបក្សឡើងបញ្ចេញមតិ។ ចំណែកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សដែលគ្មានក្រុមបញ្ចេញមតិ នៅតែមិនបានបញ្ចេញមតិដូចឆ្នាំមុនដែរ។ បទបញ្ជាផ្ទៃក្នុងរដ្ឋសភាដែលកំណត់ចំនួនតំណាងរាស្ត្រយ៉ាងតិច១០រូប ទើបអាចបង្កើតក្រុមឡើងបញ្ចេញមតិបាន នៅតែជាឧបសគ្គរាំងដល់ការបញ្ចេញរបស់អ្នកតំណាងរាស្ត្រភាគតិចដដែល ហើយក្នុងឆ្នាំសង្កេតនេះ រដ្ឋសភាមិនបានយកចិត្តទុកដាក់កែប្រែបទបញ្ជាផ្ទៃក្នុងនេះក្នុងគោលបំណងការពារតំណាងរាស្ត្រសម្លេងភាគតិចនោះទេ។ ខុមហ្វ្រែលនៅតែយល់ឃើញថា ការកែប្រែបញ្ជាផ្ទៃក្នុងរដ្ឋសភាប្រការ៤៨ថ្មី(ពីរ) នៅតែចាំបាច់ដោយប្រយោគចុងក្រោយនៃកថាខណ្ឌទី១នៃប្រការនេះ គួរដូរដាក់ថា "គណបក្សនយោបាយណាមានអាសនៈតិចជាងដប់ អាចបង្កើតក្រុមបាន១សម្រាប់តំណាងរាស្ត្ររបស់ខ្លួន"។ ការកែប្រែប្រការនេះ ធ្វើឲ្យស្របស្មារតីរបស់រដ្ឋធម្មនុញ្ញមាត្រា៥១ថ្មីដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។

ក្នុងឆ្នាំសង្កេតនេះ មានអ្នកតំណាងរាស្ត្រច្រើនជាងឆ្នាំមុនឡើងបញ្ចេញមតិគឺសរុបមាន ៤៦រូប (ឬ៣៧%នៃសមាជិកសភាសរុប ១២៣រូប)។ ចំនួននេះកើនជាងឆ្នាំមុនប្រមាណ៥៩%(ឆ្នាំ២០០៨-២០០៩ មានតំណាងរាស្ត្រឡើងបញ្ចេញមិត

តែ ២៩រូប)។ការសង្កេតក៏បង្ហាញដែរថា ក្នុងចំណោមតំណាងរាស្ត្រទាំង២៩រូបដែលបានបញ្ចេញមតិឆ្នាំមុន គឺមាន២៨រូប បានឡើងបញ្ចេញមតិក្នុងឆ្នាំសង្កេតនេះ។

តំណាងរាស្ត្រទាំង៤៦រូប បានឡើងបញ្ចេញមតិសរុប៣០៧ដង និងប្រើពេលអស់ ៣១៣២នាទី (ឬ៥២ម៉ោង១២នាទី)។

បើធៀបកិច្ចប្រជុំសុរបទាំង៣៧លើក និងរបៀបវារៈដែលបានអនុម័តទាំង២៩បង្ហាញថា ជាមធ្យមក្នុងរបៀបវារៈមួយត្រូវបានអនុម័តក្នុងចន្លោះ១ ទៅ២កិច្ចប្រជុំ។

ដោយឡែក បើធៀបកិច្ចប្រជុំសុរបទាំង៣៧លើក និងសេចក្តីព្រាងច្បាប់ រួមទាំងកិច្ចព្រមព្រៀង ទាំង២៤ និងរយៈពេលបញ្ចេញមតិបង្ហាញថា ជាមធ្យមសេចក្តីព្រាងច្បាប់មួយត្រូវបានពិភាក្សា និងអនុម័តក្នុងចន្លោះពី១ ទៅ២កិច្ចប្រជុំដែលក្នុងអំឡុងពេលពិភាក្សានោះមានអ្នកតំណាងរាស្ត្របញ្ចេញមតិប្រមាណ១៣ដង ប្រើរយៈពេលសរុបប្រមាណ១៣០នាទី (២ម៉ោង១០នាទី)។ រយៈពេលនៃការបញ្ចេញមតិនេះមានការកើនឡើង បើធៀបនឹងឆ្នាំមុនដែលសេចក្តីព្រាងច្បាប់មួយ ត្រូវបានពិភាក្សា និងអនុម័តក្នុងចន្លោះពី១ទៅ២កិច្ចប្រជុំដែរតែមានតំណាងរាស្ត្របញ្ចេញមតិប្រមាណ៨ដង ដែលប្រើរយៈពេលសរុបប្រមាណ៨៣នាទី។

*<u>តួលេខ ៤៖ កំណើនសេចក្តីព្រាងច្បាប់ កិច្ចប្រជុំ និងការបញ្ចេញមតិក្នុងឆ្នាំ២០១០ធៀបនឹង២០០៩</u>*




ទោះបីយ៉ាងណាកំណើនកិច្ចប្រជុំ និងការបញ្ចេញមតិ គឺដោយសារកំណើនសេចក្តីព្រាងច្បាប់ ជាពិសេស ការពិភាក្សាទៅលើច្បាប់សំខាន់ៗ ដូចជាក្រមព្រហ្មទណ្ឌ ដែលត្រូវការចំណាយ៨កិច្ចប្រជុំ។

ក្នុងចំណោមតំណាងរាស្ត្រដែលបានបញ្ចេញមតិទាំង៤៦ មានតំណាងរាស្ត្រមកពីគណបក្សប្រជាជនចំនួន២៧រូប(ស្មើនឹង៥៩% នៃតំណាងរាស្ត្របញ្ចេញមតិសរុប) អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ១៧រូប (ស្មើនឹង៣៧%) តំណាងរាស្ត្រគណបក្សហ្វុនស៊ិនប៉ិច និងជាតិនិយមរួមគ្នាមាន២រូប (៤%)។ បើធៀបនឹងចំនួនអាសនៈ ឬចំនួនតំណាងរាស្ត្រសរុបតាមគណបក្សនៅរដ្ឋសភាបង្ហាញថា គណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្របញ្ចេញមតិមិនសមាមាត្រទៅនឹងចំនួនអ្នកតំណាងរាស្ត្រដែលខ្លួនមាននៅក្នុងរដ្ឋសភា (៧៣% នៃអាសនៈសរុប) ខណៈគណបក្សសមរង្ស៊ីមាន ២១% គណបក្សសិទ្ធិមនុស្ស ជាតិនិយម និងហ៊្វុនស៊ិនប៉ិចមាន ៧%។ ចំណែកតំណាងរាស្ត្រមិនបានបញ្ចេញមតិមាន៧៧រូប។

*តួលេខ ៥៖ ភាគរយតំណាងរាស្ត្រឡើងបញ្ចេញមតិធៀបនឹងតំណាងរាស្ត្រសរុបក្នុងបក្សខ្លួន*




តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មាន៣០% (ស្មើនឹង២៧រូប នៃចំនួនតំណាងរាស្ត្រគណបក្សនេះសរុបទាំង៩០រូប) បានបញ្ចេញមតិក្នុងឆ្នាំសង្កេតនេះ។ តំណាងរាស្ត្រគណបក្ស សមរង្ស៊ីមាន៦៥% (ស្មើនឹង១៧រូប ក្នុងចំណោម២៦រូប)។

គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សជាតិនិយមមានចំនួន១រូបដូចគ្នា(ស្មើនឹង៥០%នៃ អ្នកតំណាងរាស្ត្រគណបក្សនេះសរុបដូចគ្នា)។ ដោយឡែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមិនអាចបញ្ចេញមតិបានដោយសារតែគណបក្សនេះ មិនអាចមានលទ្ធភាពបង្កើតក្រុមបញ្ចេញមតិរបស់ខ្លួន និងមិនព្រមទៅចូលរួមជាមួយក្រុមគណបក្សដទៃ។

## ១.២. ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា

ក្នុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រសរុប៤៦មកពីគណបក្សនយោបាយចំនួន៤ ដែលបានឡើងបញ្ចេញមតិសរុប ៣១៣២នាទី (៥២ម៉ោង ១២នាទី) ឬជាមធ្យមតំណាងរាស្ត្រមួយរូបបញ្ចេញមតិបានប្រមាណ៦៨នាទី។

*តួលេខ ៦៖ចំនួនតំណាងរាស្ត្រ និងរយៈពេលបញ្ចេញមតិតាមគណបក្ស*




ក្នុងចំណោម គណបក្សទាំង៤ មានគណបក្សប្រជាជនកម្ពុជាចំនួន២៧រូប(ស្មើនឹង៥៩% នៃតំណាងរាស្ត្របញ្ចេញមតិសរុប) បញ្ចេញមតិសរុបបាន ប្រមាណ ៣៨% (ស្មើនឹង១១៩៩នាទី ឬប្រមាណ២០ម៉ោង) នៃរយៈពេលបញ្ចេញមតិសរុប។

ចំណែកគណបក្ស សម រង្ស៊ីមានតំណាងរាស្ត្រ១៧រូប (ស្មើនឹង ៣៧% នៃចំនួនតំណាងរាស្ត្របានបញ្ចេញមតិសរុប) បញ្ចេញមតិសរុបច្រើនជាងគេបានប្រហែល៥៩% (ស្មើនឹង១៨២៩នាទី ឬ៣០ម៉ោង២៩នាទី)។ គណបក្សជាតិនិយមមាន១រូបបញ្ចេញមតិបានប្រមាណ៣% (ស្មើនឹង៩០នាទី) និងគណបក្សហ្វ៊ុនស៊ិនប៉ិចបាន១៤នាទី។ គណបក្សហ្វ៊ុនស៊ិនប៉ិច ក្នុងឆ្នាំសង្កេតមុនមិនបានបញ្ចេញមតិនោះទេ។

ដូចឆ្នាំសង្កេតមុនដែរ ចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលបានឡើងបញ្ចេញមតិ គឺច្រើនជាងគណបក្សដទៃទៀត (ប្រមាណ៥៩%) ក៏ប៉ុន្តែរយៈពេលបញ្ចេញមតិគឺមិនបានច្រើនជាងគេនោះទេគឺបានប្រមាណ៣៨% ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ីនៅតែនាំមុខក្នុងការបញ្ចេញមតិបានច្រើនជាងតំណាងរាស្ត្រដទៃ។

ការដែលចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបញ្ចេញមតិបានច្រើន ក៏ដោយសារគណបក្សនេះមានតំណាងរាស្ត្រច្រើន (៧៣%) និងក្រុមបញ្ចេញមតិច្រើន (៩ក្រុម ក្នុង ១១ក្រុម)។ ទោះបីយ៉ាងណា រយៈពេលបញ្ចេញមតិមានតិចជាងគណបក្សសមរង្ស៊ី ក៏ដោយសារពេលបញ្ចេញមតិម្តងៗ អ្នកតំណាងរាស្ត្រគណបក្សនេះ មិនបានបញ្ចេញមតិច្រើននោះទេ។ ការធ្វើបែបនេះ គឺដើម្បីពន្លឿនដល់ការអនុម័តសេចក្តីព្រាងច្បាប់។

អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី១រូប (ក្នុងចំណោមអ្នកដែលបានបញ្ចេញមតិសរុប១៧រូប) គឺបញ្ចេញមតិជាមធ្យមបានប្រមាណ ១០៧នាទី ក្នុង១ឆ្នាំសង្កេតនេះ (ឆ្នាំមុន១រូបជាមធ្យមបាន ៧៤នាទីក្នុងចំណោមតំណាងរាស្ត្រ១០រូប)។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានប្រមាណ៤៤នាទី (ឆ្នាំមុនជាមធ្យម២៦នាទីក្នុងចំណោម១៨រូប)។ គណបក្សជាតិនិយមបាន ៩០ នាទី (ឆ្នាំមុនបាន៣៩នាទីក្នុងចំណោម១រូប) និងគណបក្សហ្វ៊ុនស៊ិនប៉ិចបាន១៤នាទី (ឆ្នាំមុនមិនបានបញ្ចេញមតិទេ)។ ដូចនេះ ក្នុងឆ្នាំសង្កេតនេះជាមធ្យម អ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងឆ្នាំសង្កេតមុន។

### ១.៣. ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រ ដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជាបីសូរ(Tone) គឺ៖ អព្យាក្រឹតវិជ្ជមាន និងអវិជ្ជមាន ចំពោះស្ថាប័នរបៀបវារៈឬតួអង្គ/ស្ថាប័នរដ្ឋាភិបាល ណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។ ខ្លឹមសារអព្យាក្រឹត គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។ ចំណែកឯវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិ សេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ រីឯអវិជ្ជមាន គឺនិយាយពីគុណវិបត្តិតួអង្គ ឬស្ថាប័នណាមួយ។

ក្នុងផ្នែកនេះ នឹងវិភាគពីអត្ថន័យធៀបនឹងរយៈពេលសរុបនៃការបញ្ចេញមតិ។ ដូចនេះតំណាងរាស្ត្រដែលមកពីគណបក្សបញ្ចេញមតិច្រើន អាចបញ្ចេញមតិក្នុងអត្ថន័យនីមួយៗច្រើនជាងគណបក្សដទៃទៀត។ ចំណែកការវិភាគអត្ថន័យនៃបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស និងមានបង្ហាញនៅចំនុចបន្ទាប់។ ក្នុងឆ្នាំសង្កេតនេះ គ្រប់គណបក្សដែលបានបញ្ចេញមតិគឺសុទ្ធតែបានបញ្ចេញមតិក្នុងន័យអព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន។

*<u>តួលេខ ៧៖ ចំនួននាទី និងភាគរយខ្លឹមសារព្យាក្រឹតតាមគណបក្សនៃការបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រ</u>*




ដូចឆ្នាំសង្កេតមុនដែរ លទ្ធផលសង្កេត បង្ហាញថា និន្នាការនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគ្រប់គណបក្ស គឺផ្តោតខ្លាំងក្នុងន័យអព្យាក្រឹត អវិជ្ជមាន និងវិជ្ជមាន។ ការបញ្ចេញមតិបែបអព្យាក្រឹត្យ មាន ៦៤% (ឬស្មើនឹង២០១៤នាទី ឬ៣៣ម៉ោង ៣៤នាទី) នៃរយៈពេលបញ្ចេញមតិសរុបរបស់អ្នក

តំណាងរាស្ត្រទាំងអស់ដែលមាន រយៈពេលសរុប៣១៣២នាទី។

ចំណែកការបញ្ចេញមតិបែបអវិជ្ជមាន ក្នុងលំដាប់លេខ២ដែលមានរយៈពេលសរុប ៧២៧នាទី (ឬ១២ម៉ោង ៧នាទី) នៃរយៈពេលបញ្ចេញមតិសរុប ស្មើនឹង២៣%។ រីឯការបញ្ចេញមតិបែបវិជ្ជមានគឺមាន១៣% (ស្មើនឹង៣៩១នាទី ឬ៦ម៉ោង៣១នាទី)។

*តួលេខ ៨៖ខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្សធៀបនឹងរយៈពេលសរុបរបស់គណបក្ស*




និន្នាការនៃការបញ្ចេញមតិ របស់អ្នកតំណាងរាស្ត្រ ក្នុងឆ្នាំសង្កេតនេះ គឺដូចជាឆ្នាំមុនដែរ ដោយតំណាងរាស្ត្រភាគច្រើន គឺបញ្ចេញមតិបែបអព្យាក្រឹត។ ចំណែកការបញ្ចេញមតិបែបវិជ្ជមាន គឺភាគច្រើនធ្វើឡើង ដោយតំណាងរាស្ត្រ គណបក្សកាន់អំណាចប្រជាជនកម្ពុជា និងការបញ្ចេញមតិបែបអវិជ្ជមាន ឬការរិះគន់ គឺភាគច្រើនធ្វើឡើងដោយតំណាងរាស្ត្រគណបក្សសមរង្ស៊ី។

*តួលេខ ៩៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអព្យាក្រឹតតាមគណបក្ស*




តំណាងរាស្ត្រមកពីគណបក្សទាំង៤សុទ្ធ តែបានបញ្ចេញមតិក្នុងន័យអព្យាក្រឹត។ តំណាងរាស្ត្រគណបក្សសមរង្ស៊ី បាននាំមុខក្នុងការបញ្ចេញមតិក្នុងខ្លឹមសារនេះ ១៩ម៉ោង១៦នាទី (ឬស្មើនឹង៥៨% នៃរយៈពេលបញ្ចេញមតិសរុបក្នុងន័យអព្យាក្រឹត)។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាប្រើពេល១៣ម៉ោង និង៦នាទី (ស្មើនឹង៣៩%) និងគណបក្សជាតិនិយម៦៤នាទី (ស្មើនឹង៣%) និងគណបក្សហ្វ៊ុនស៊ិនប៉ិចបាន៨នាទី (ស្មើនឹង ១%នៃរយៈពេលបញ្ចេញមតិសរុបក្នុងន័យអព្យាក្រឹត)។

*តួលេខ ១០៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបវិជ្ជមានតាមគណបក្ស*




តំណាងរាស្ត្រមកពីគណបក្សនយោបាយទាំង ៤ សុទ្ធតែបានបញ្ចេញមតិបែបវិជ្ជមាន។ ទោះបីយ៉ាងណា សូរ(Tone)បែបវិជ្ជមាននេះ គឺភាគច្រើន ធ្វើឡើងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលសរុបមាន៧១% (ស្មើនឹង៤ម៉ោង៣៧នាទី) នៃរយៈពេលបញ្ចេញមតិបែបវិជ្ជមានសរុប គឺធ្វើឡើងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។ ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលបញ្ចេញមតិបែបវិជ្ជមាននោះដែលមានរយៈពេលតែ៩៦នាទី (ស្មើនឹង២៥%នៃចំនួនការបញ្ចេញមតិរបស់ខ្លួន)។គណបក្សជាតិនិយមមាន១៦នាទី (៤%) និងអ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបាន២នាទី។ និន្នាការនេះ គឺដូចជាឆ្នាំសង្កេតមុន ដែលតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាផ្តោតខ្លាំងក្នុងការបញ្ចេញមតិបែបវិជ្ជមានបន្ទាប់ពីអព្យាក្រឹត។

*តួលេខ ១១៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអវិជ្ជមានតាមគណបក្ស*




ទោះបីយ៉ាងណា ការបញ្ចេញមតិបែបអវិជ្ជមានណាមួយនោះ នៅតែកើតមានឡើងមិនថាធ្វើឡើងដោយគណបក្សកាន់អំណាច ឬគណបក្សប្រឆាំងនោះទេ។ ក្នុងនោះគណបក្សសមរង្ស៊ី បានបញ្ចេញមតិអវិជ្ជមានច្រើនរហូតដល់ ៧៩% នៃចំនួនសូរបញ្ចេញមតិអវិជ្ជមាន ទាំងអស់(ស្មើនឹង៩ម៉ោង៣៧)នៃរយៈពេលបញ្ចេញមតិក្នុងខ្លឹមសារអវិជ្ជមានសរុប។ ចំណែកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានថ្លែងក្នុងខ្លឹមសារអវិជ្ជមាន ប្រហែល១៩% (២ម៉ោង១៦នាទី)។ តំណាងរាស្ត្រគណបក្សជាតិនិយមបានបញ្ចេញមតិរយៈ១០នាទី ស្មើនឹង ១% និងអ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបាន ៤នាទីស្មើនឹង ១%។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីក្នុងឆ្នាំសង្កេតមុន បញ្ចេញមតិក្នុងន័យអវិជ្ជមានច្រើនបន្ទាប់ពីអព្យាក្រឹតផងដែរ។

## ១.៤. ខ្លឹមសារការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស

ក្នុងផ្នែកនេះ បង្ហាញពីការវិភាគនៃនិន្នាការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សថា តើគណបក្សណាផ្តោតក្នុងការបញ្ចេញមតិក្នុងខ្លឹមសារបែបណា។

បើធៀបខ្លឹមសារនៃការបញ្ចេញមតិរប់សតំណាងរាស្ត្រ តាមគណបក្សទៅនឹងរយៈពេលដែលគណបក្សរបស់ខ្លួនបានបញ្ចេញមតិ គឺថាតំណាងរាស្ត្រក្នុងគណបក្សទាំងបួននេះសុទ្ធតែផ្តោតទៅលើការបញ្ចេញមតិក្នុងន័យអព្យាក្រឹត។

ទោះបីយ៉ាងណា ក្រៅពីការផ្តោតទៅលើខ្លឹមសារអព្យាក្រឹត គណបក្សសមរង្ស៊ី និងគណបក្សប្រជាជនកម្ពុជាដូចឆ្នាំសង្កេតមុនដែរ គឺមាននិន្នាការខុសគ្នាក្នុងការបញ្ចេញមតិបែបវិជ្ជមាន និងបែបអវិជ្ជមានដោយគណបក្សប្រជាជនកម្ពុជាផ្តោតទៅលើការបញ្ចេញមតិបែបវិជ្ជមាន ច្រើនជាងអវិជ្ជមាន ហើយតំណាងរាស្ត្រគណបក្សសមរង្ស៊ីបែបអវិជ្ជមានច្រើនជាងវិជ្ជមាន។

*តួលេខ ១២៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា*




តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិរបស់ខ្លួន ក្នុងន័យ អព្យាក្រឹតច្រើនដែលមានរយៈពេល៦៦% នៃចំនួនសូរបញ្ចេញមតិអព្យាក្រិត ទាំងអស់(ស្មើ១៣ម៉ោង៦នាទី) នៃរយៈពេល បញ្ចេញមតិសរុបរបស់គណបក្សនេះ។ ចំណែកក្នុងន័យវិជ្ជមាន ស្ថិតនៅលំដាប់ទី២ មាន២៣%នៃចំនួនសូរបញ្ចេញមតិអព្យាក្រិតទាំងអស់ (ស្មើនឹង៤ម៉ោង៣៧នាទី) ខណៈការបញ្ចេញមតិបែបអវិជ្ជមានបាន១១%នៃចំនួនសូរបញ្ចេញមតិអព្យាក្រិតទាំងអស់ (ឬ២ម៉ោង និង១៦នាទី)

*តួលេខ១៣៖ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា*




ថ្វីត្បិតឆ្នាំនេះអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិច្រើនជាងឆ្នាំមុន ក៏ប៉ុន្តែនិន្នាការនៃសូរ(Tone) នៃ ការបញ្ចេញមតិ របស់គណបក្សនេះគឺដូចឆ្នាំសង្កេតមុនដែរ ដែលភាគច្រើន គឺក្នុងន័យអព្យាក្រឹត វិជ្ជមាន និង អវិជ្ជមានតិចជាងគេ។

*តួលេខ ១៤៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី*




តំណាងរាស្ត្រគណបក្សសមរង្ស៊ី ក៏ផ្តោតការបញ្ចេញមតិ ក្នុងន័យអព្យាក្រឹតច្រើនជាងគេដែរដែលមាន៦៣% (១៩ម៉ោងនិង១៦នាទី) នៃការបញ្ចេញមតិសរុបរបស់គណបក្សនេះ។

ផ្ទុយពីតំណាងរាស្ត្រគណបក្សកាន់អំណាច តំណាងរាស្ត្រគណបក្សសមរង្ស៊ីក៏ផ្តោតខ្លាំងទៅលើការរិះគន់និងបញ្ចេញមតិបែបអវិជ្ជមានសំដៅទៅលើស្ថាប័ន និងតួអង្គមួយចំនួនដែរ ដែលមានរហូតដល់ទៅ៩ម៉ោងនិង៣៧នាទី។ ចំណែកការបញ្ចេញមតិសរសើរ ឬបែបវិជ្ជមានមានតែ (៥%) ៩៦នាទីប៉ុណ្ណោះ។

*តួលេខ១៥៖ ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី*




និន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់គណបក្សសមរង្ស៊ី គឺដូចឆ្នាំសង្កេតមុនដែរដែលភាគច្រើនគឺក្នុងន័យអព្យាក្រឹត (ឆ្នាំសង្កេតមុន៦៨% និងឆ្នាំនេះ៦៣%) បន្ទាប់មកគឺក្នុងន័យអវិជ្ជមានដូចជាការរិះគន់ ឬការលើកឡើងពីភាពអសកម្មនានារបស់ស្ថាប័ន ឬបុគ្គលរដ្ឋាភិបាល (ឆ្នាំសង្កេតមុន២៦% និងឆ្នាំនេះ ៣២%) និងវិជ្ជមានតិចជាងគេ (ឆ្នាំសង្កេតមុន ៦% និងឆ្នាំនេះ ៥%)។

*តួលេខ១៦៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម*




គណបក្សជាតិនិយម មានតំណាងរាស្ត្រ២រូប ហើយបានចូលរួម ក្នុងក្រុមបញ្ចេញមតិរបស់គណបក្សប្រជាជនកម្ពុជា។ ក្នុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រគណបក្សនេះ១រូបប៉ុណ្ណោះ ដែលបានបញ្ចេញមតិ។ តំណាងរាស្ត្រគណបក្សជាតិនិយម គឺភាគច្រើនបញ្ចេញមតិរបស់ខ្លួន ក្នុងន័យអព្យាក្រឹត ដែលមាន៧១% (១ម៉ោង៤នាទី) នៃការបញ្ចេញមតិសរុបរបស់គណបក្សនេះ។ចំណែកមតិវិជ្ជមាន១៨% (១៦នាទី) និងការបញ្ចេញមតិបែបអវិជ្ជមាន១១% (១០នាទី)។

*តួលេខ ១៧៖ ប្រៀបធៀបនិន្នាការនៃខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សជាតិនិយម*




និន្នាការនៃខ្លឹមសារបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម គឺដូចជាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែរ គឺ អព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន។ ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្រគណបក្សនេះ បានបញ្ចេញមតិបែបអវិជ្ជមានខ្លះ ដែលខុសពីឆ្នាំសង្កេតមុនដែលមិនមាន។

*<u>តួលេខ ១៨៖ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច</u>*




គណបក្សហ្វ៊ុនស៊ិនប៉ិច មានតំណាងរាស្ត្រពីរូប ហើយតំណាងរាស្ត្រទាំងពីររូបនេះ ក៏ចូលរួមក្នុងក្រុមបញ្ចេញមតិរបស់គណបក្សប្រជាជនកម្ពុជា។ ក៏ប៉ុន្តែក្នុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រតែមួយរូបប៉ុណ្ណោះបញ្ចេញមតិសរុបបាន១៤នាទី។ ក្នុងនោះ តំណាងរាស្ត្របញ្ចេញមតិ ក្នុងន័យអព្យាក្រឹត៨នាទី វិជ្ជមាន២នាទី និងអវិជ្ជមាន៤នាទី។ ក្នុងឆ្នាំសង្កេតមុន អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចមិនបានបញ្ចេញមតិ

## ១.៥. ខ្លឹមសារបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនៅលើតួអង្គស្ថាប័ននិងចំនុចផ្សេងៗ

តារាងខាងក្រោមនឹងបង្ហាញពីចំណុចផ្សេងៗ ឬតួអង្គផ្សេងៗដែលត្រូវបានអ្នកតំណាងរាស្ត្រលើកឡើងនៅសម័យប្រជុំពេញអង្គទាំង៣៧ដង និងខ្លឹមសារបែបអព្យាក្រឹតវិជ្ជមាន អវិជ្ជមានដែលអ្នកតំណាងរាស្ត្របាននិយាយសំដៅតួអង្គ ឬស្ថាប័នទាំងនោះ។ តារាងខាងក្រោមក៏បង្ហាញពីនិន្នាការនៃការបញ្ចេញមតិរបស់គណបក្សនយោបាយ ថាតើតំណាងរាស្ត្រគណបក្សណាបញ្ចេញមតិចំពោះស្ថាប័ន ឬតួអង្គណាក្នុងខ្លឹមសារបែបណាខ្លះ។

*<u>តារាងទី១៖គុណភាពការបញ្ចេញមតិរបស់សមាជិកសភាតាមគណបក្សនយោបាយទាំងបីលើចំណុចសំខាន់ៗមួយចំនួន (គិតជានាទី)</u>*

សំគាល់៖ អ.ក្រឹត=អព្យាក្រឹត វ.មាន=វិជ្ជមាន អ.មាន=អវិជ្ជមាន

| លរ | ចំណុចពាក់ព័ន្ធ | | | | | | | | | | | | | សរុបជានាទី និងជាភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អ. ក្រឹត | វ. មាន | អ.មាន | អ.ក្រឹត | វ.មាន | អ.មាន | អ.ក្រឹត | វ.មាន | អ.មាន | អ. ក្រឹត | វ. មាន | អ.មាន | |
| ១ | របៀបវារៈកំពុងពិភាក្សា | 310 | 87 | 2 | 8 | 2 | 0 | 54 | 11 | 10 | 758 | 45 | 311 | 1598 (51%) |
| ២ | រាជរដ្ឋាភិបាល | 95 | 156 | 10 | 0 | 0 | 0 | 4 | 5 | 0 | 171 | 33 | 165 | 639 (20%) |
| ៣ | រដ្ឋសភា | 66 | 3 | 7 | 0 | 0 | 0 | 5 | 0 | 0 | 32 | 2 | 4 | 119 (4%) |
| ៤ | ព្រឹទ្ធសភា | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 4 (0%) |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥ | គណបក្សខ្លួនគាត់ | 43 | 16 | | | | | | | | 47 | 3 | | 109 (4%) |
| ៦ | គណបក្សដទៃទៀត | 39 | | 29 | | | | | | | 5 | | | 73 (2%) |
| ៧ | តំណាងរាស្ត្រខ្លួនឯង | 39 | 11 | | | | | | | | 28 | 6 | 4 | 88 (3%) |
| ៨ | តំណាងរាស្ត្រដទៃទៀត | 129 | 2 | 87 | | | 4 | | | | 34 | 4 | 11 | 271 (9%) |
| ៩ | មណ្ឌលរបស់គាត់ | 20 | | | | | | | | | 15 | | 17 | 52 (2%) |
| ១០ | មណ្ឌលផ្សេងទៀត | 2 | | | | | | | | | 9 | | 10 | 21 (1%) |
| ១១ | តុលាការ | 15 | | 1 | | | | 1 | | | 33 | 3 | 55 | 108 (3%) |
| ១២ | ស្ត្រី | | | | | | | | | | 10 | | | 10 (0%) |
| ១៣ | បញ្ហាផ្សេងៗ | 28 | | | | | | | | | 12 | | | 40 (1%) |
| **សរុបជានាទី និងភាគរយ** | | 1199 (38%) | | | 90(3)% | | | 14(0%) | | | 1829(59%) | | | 3132 (100%) |

ដូចឆ្នាំសង្កេតមុនដែរ ចំណុចពាក់ព័ន្ធចំនួន៣ ដែលអ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើន គឺលើរបៀបវារៈកំពុងពិភាក្សា រាជរដ្ឋាភិបាល និងតំណាងរាស្ត្រដទៃទៀតដែលសរុបមាន៨០% ឬ៤១ម៉ោង៤៨នាទីនៃរយៈពេលបញ្ចេញមតិសរុបរបស់អ្នកតំណាងរាស្ត្រ (ឆ្នាំមុនសរុបមាន ៧៥% ឬ១៥ម៉ោង២៩នាទី)។

ការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សា (និយាយទៅលើខ្លឹមសារចោទជាសំណួរ ផ្តល់អនុសាសន៍លើសេចក្តីព្រាងច្បាប់) គឺមាន៥១% (២៦នាទី ៣៨នាទី)។ ចំណែករាជរដ្ឋាភិបាល រួមនឹងនាយករដ្ឋមន្ត្រី ត្រូវបានអ្នកតំណាងរាស្ត្រលើកឡើងច្រើនលំដាប់ទី២ គឺ២០% (១០ម៉ោង៣៩នាទី) ដោយសារស្ថាប័ននេះ គឺមានទំនាក់ទំនងជាមួយរបៀបវារៈកំពុងពិភាក្សា ហើយជារឿយៗ គឺអ្នកតំណាងរាស្ត្រតែភ្ជាប់របៀបវារៈកំពុងពិភាក្សា ទៅនឹងការអនុវត្តន៍របស់រាជរដ្ឋាភិបាល។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ភាគច្រើនបញ្ចេញមតិក្នុងអព្យាក្រឹត និងវិជ្ជមានទាក់ទងនិងការងារដែលធ្វើឡើងដោយគណបក្សរបស់ខ្លួនដូចជាសេចក្តីព្រាងច្បាប់ រាជរដ្ឋាភិបាល ចំណែកខ្លឹមសារអវិជ្ជមានភាគច្រើនទាក់ទងនឹងគណបក្សដទៃទៀតរួមទាំងតំណាងរាស្ត្រផងដែរ។ ចំណែកគណបក្សសមរង្ស៊ីវិញ ភាគច្រើនបញ្ចេញមតិក្នុន័យអព្យាក្រឹត និងអវិជ្ជមានទាក់ទងនឹងការងាររបស់គណបក្សកាន់អំណាចដូចជាសេចក្តីព្រាងច្បាប់ រាជរដ្ឋាភិបាល។ ស្ថាប័នតុលាការក៏ត្រូវទទួលរងការរិះគន់ពីអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីផងដែរ។ ចំណែកគណបក្សជាតិនិយម និងហ៊្វុនស៊ិនប៉ិចភាគច្រើនប្រើពេលវេលាតិចតួចរបស់ខ្លួនបញ្ចេញមតិទាក់ទងសេចក្តីព្រាងច្បាប់ និងរាជរដ្ឋាភិបាលក្នុងន័យព្យាក្រឹត។

- **ការបញ្ចេញមតិលើរបៀបវារៈកំពុងពិភាក្សា៖**

រយៈពេលភាគច្រើននៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើការបញ្ចេញមតិ យោបល់ សំណួរ អនុសាសន៍លើអត្ថបទច្បាប់ និងបញ្ហានានាដែលទាក់ទងនឹងសេចក្តីព្រាងច្បាប់មាន៥១% (២៦នាទី ៣៨នាទី)។

*តួលេខ ១៩៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សាតាមគណបក្ស*




អ្នកតំណាងរាស្ត្រមកពីគណបក្សទាំង៤ សុទ្ធតែបានបញ្ចេញមតិ ទាក់ទងនឹងរបៀបវារៈពិភាក្សា (សេចក្តីព្រាងច្បាប់)។ អ្នកតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជាបាន បញ្ចេញមតិសរុបទៅលើសេចក្តីព្រាងច្បាប់ ៦ម៉ោង៣៩នាទី (ឬ២៥%)។ គណបក្សសមរង្ស៊ី ១៨ម៉ោង៣៤នាទី (ឬ៧០%)។ គណបក្សជាតិនិយម និងហ្វ៊ុនស៊ិនប៉ិចរួមគ្នាបាន១ម៉ោង ២៥នាទី (ឬ៥%)។

ចំពោះការបញ្ចេញមតិលើសេចក្តីព្រាងច្បាប់នេះ គឺភាគច្រើនក្នុងន័យអព្យាក្រឹត គឺ៧១% (ឬ១៨ម៉ោង៥០នាទី) នៃរយៈពេលសរុបដែលអ្នកតំណាងរាស្ត្របញ្ចេញមតិលើចំណុចនេះ។ ចំណែកការបញ្ចេញមតិក្នុងន័យវិជ្ជមាន គឺ៩%(២ម៉ោង ២៥នាទី) និងអវិជ្ជមាន គឺ២០% (សរុប ៥ម៉ោង២៣នាទី)។

*តួលេខ ២០៖ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស ទៅលើរបៀបវារៈពិភាក្សា (សេចក្តីព្រាងច្បាប់)*




បើធ្វើការប្រៀបធៀបខ្លឹមសារ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រ តាមគណបក្សទៅនឹងរយៈពេលសរុប ដែលតំណាងរាស្ត្រ គណបក្សនីមួយបញ្ចេញមតិ ទៅលើសេចក្តីព្រាងច្បាប់នេះបង្ហាញថា អ្នកតំណាងរាស្ត្រមកពីគណបក្សទាំង៤ជារួមបញ្ចេញមតិក្នុងន័យអព្យាក្រឹតលើសេចក្តីព្រាង។

ទោះបីយ៉ាងណាតំណាងរាស្ត្រមកពីគណបក្សធំពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី មាននិន្នាការខុសគ្នាក្នុងការបញ្ចេញមតិបែបអវិជ្ជមាន និងវិជ្ជមាន។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលជាអ្នកដឹកនាំរាជរដ្ឋាភិបាល និងជាអ្នកតាក់តែងសេចក្តីព្រាងច្បាប់ គឺបញ្ចេញមតិបែបវិជ្ជមាន ដូចជាសរសើរលើសេចក្តីព្រាងច្បាប់ថា មានលក្ខណៈល្អពេញលេញ ច្បាប់មានសារៈសំខាន់ណាស់ សមស្របពេលប្រទេសយើងកំពុងអភិវឌ្ឍន៍ និងរួមទាំងអរគុណ និងមានមោទនភាពចំពោះរាជរដ្ឋា

ភិបាល ដែលខំប្រឹងប្រែងធ្វើសេចក្តីព្រាងច្បាប់នេះ (២២%នៃរយៈពេលសរុបដែលតំណាងរាស្ត្រគណបក្សនេះបញ្ចេញមតិទៅលើសេចក្តីព្រាងច្បាប់)។ ចំណែកក្នុងន័យអវិជ្ជមានគឺមានតែ១%។

ចំណែកគណបក្សសមរង្ស៊ី ដែលនៅក្រៅរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ក្នុងការបញ្ចេញមតិបែបអវិជ្ជមាន ឬរិះគន់សេចក្តីព្រាងច្បាប់ប្រមាណ ២៨%នៃរយៈពេលសរុប ដែលតំណាងរាស្ត្រគណបក្សនេះបានបញ្ចេញមតិទៅលើសេចក្តីព្រាងច្បាប់។ ចំណែកការបញ្ចេញមតិបែបវិជ្ជមានគឺមានតែ៤%។

- **ការបញ្ចេញមតិរលើរាជរដ្ឋាភិបាលរួមទាំងនាយករដ្ឋមន្ត្រី៖**

រាជរដ្ឋាភិបាលរួមទាំងនាយករដ្ឋមន្ត្រី ត្រូវបានអ្នកតំណាងរាស្ត្រលើកឡើងច្រើនលំដាប់ទី២ ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាដែលមាន២០% (ឬ១០ម៉ោង ៣៩នាទី) នៃរយៈពេលបញ្ចេញមតិសរុបរបស់អ្នកតំណាងរាស្ត្រទាំងអស់។ រាជរដ្ឋាភិបាលត្រូវបានលើកឡើងច្រើន ក៏ដោយសារតែជាស្ថាប័នដែលបានតាក់តែងសេចក្តីព្រាងច្បាប់ ជាអ្នកអនុវត្តច្បាប់ ហើយត្រូវបានទទួលការរិះគន់ និងសរសើរផងដែរ។

*តួលេខ ២១៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរាជរដ្ឋាភិបាលតាមគណបក្ស*




មានតំណាងរាស្ត្រមកពី៣គណបក្ស ដែលបានបញ្ចេញមតិទាក់ទងនឹងរាជរដ្ឋាភិបាល។ ក្នុងនោះគណបក្សសមរង្ស៊ីបាននាំមុខ (៥៨% ឬ១១ម៉ោង ៩នាទី នៃរយៈពេលសរុប ដែលរាជ រដ្ឋាភិបាលត្រូវបានលើកឡើង)។

គណបក្សប្រជាជនកម្ពុជា បានលើក ៤១% (ឬ៤ម៉ោង ២១នាទី) និងគណបក្សជាតិនិយមបាន១% (ឬ៩នាទី)។ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រទៅលើរាជរដ្ឋាភិ បាល ក្នុងន័យអព្យាក្រឹត វិជ្ជមាន និងអវិជ្ជមាន គឺប្រហាក់ប្រហែលគ្នា។ ក្នុងនោះអព្យាក្រឹត (៤២% ឬ៤ម៉ោង ៣០នាទី) វិជ្ជមាន (៣០% ឬ៣ម៉ោង ១៤នាទី) និងអវិជ្ជមាន (ប្រមាណ២៨% ឬ២ម៉ោង ៥៥នាទី)។

*តួលេខ២២៖ ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្សទៅលើរាជរដ្ឋាភិបាល*




នៅពេលនិយាយពីរាជរដ្ឋាភិបាល តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិភាគច្រើន គឺក្នុងន័យវិជ្ជមាន ឬសរសើរដល់រាជរដ្ឋាភិបាលដែលមាន៦០% នៃរយៈពេលសរុបដែលតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានលើកឡើងទាក់ទងនឹងរាជរដ្ឋាភិបាល។

ចំណែកក្នុងន័យអព្យាក្រឹត គឺ ៣៦% និងអវិជ្ជមាន៤% ទាក់ទងនឹងការរំលោភបំពានរបស់អាជ្ញាធរ ប៉ូលីស ការប្រព្រឹត្តអំពើពុករលួយរបស់មន្ត្រីរាជរដ្ឋាភិបាល កុងត្រូលជជុះ ការខ្វះខាតរបស់រាជរដ្ឋាភិបាលដែលមិនបានការពារប្រជាពលរដ្ឋពីការរំលោភដីធ្លី ការបូមខ្សាច់របស់ក្រុមហ៊ុនឯកជន ការធ្វើប័ណ្ណកម្មសិទ្ធិមានការយឺតយ៉ាវ ការចំណាយលើសគំរោងក្នុងហិរញ្ញវត្ថុសំរាប់គ្រប់គ្រងថវិកាជាតិរបស់រាជរដ្ឋាភិបាលជាដើម ទាក់ទងនឹងការកំណើនទីប្រឹក្សា និងអនុរដ្ឋលេខាធិការរបស់ក្រសួងនីមួយៗ ពិសេសទៅទៀតការចំណាយខុសទិសដៅរបស់ក្រសួង ដែលមានការចំណាយលើសកំណត់ ដូចជាក្រសួងហិរញ្ញវត្ថុ និងទីស្តីការរដ្ឋមន្ត្រី។ ហើយការបញ្ចេញមតិជាលក្ខណៈអវិជ្ជមាននេះ ក៏ជាការរិះគន់ផង ដែលទៅលើចំណុចខ្វះខាតមួយចំនួនរបស់សេចក្តីព្រាងច្បាប់ ដែលដាក់ឲ្យពិភាក្សា ដូចជាសេចក្តីព្រាងច្បាប់ណាដែលចំណុចខ្លះ មានការរឹតត្បិតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ដូចជាច្បាប់បាតុកម្ម និងសេចក្តីច្បាប់អាស្សាមិករណ៍ដែលប៉ះពាល់ជីវភាពលំនៅដ្ឋាន និងសំណង់ជាដើម ប៉ុន្តែទោះបីយ៉ាងណា ក៏អ្នកការរិះគន់ និងការស្នើសុំកែប្រែទៅលើសេចក្តីព្រាងច្បាប់នោះ កម្រឃើញមានការទទួលយក និងយល់ព្រមកែតាមដោយរដ្ឋាភិបាលណាស់។ ការសង្កេតក៏បង្ហាញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ជារឿយៗ គឺនិយាយល្អពីរាជរដ្ឋាភិបាល និងការពាររាជរដ្ឋាភិបាល ពីការរិះគន់របស់គណបក្សប្រឆាំង។

ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បញ្ចេញមតិទាក់ទងនឹងរាជរដ្ឋាភិបាល ភាគច្រើនក្នុងន័យអព្យាក្រឹត (៤៦%) និងអវិជ្ជមាន (៤៥%) ដែលជារឿយៗ រិះគន់ដល់សកម្មភាព និងភាពអសកម្មនានារបស់រាជរដ្ឋាភិបាល។ ចំណែកការបញ្ចេញមតិក្នុងន័យវិជ្ជមាន ឬសរសើរដល់រាជរដ្ឋាភិបាលគឺមានតែ៩%។ ចំណែកតំណាងរាស្ត្រគណបក្សជាតិនិយមបញ្ចេញមតិក្នុងន័យអព្យាក្រឹត៤៤% និងវិជ្ជមាន៥៦%។

- **ការបញ្ចេញមតិលើតំណាងរាស្ត្រដទៃ៖** អ្នកតំណាងរាស្ត្រក៏បានបញ្ចេញមតិទាក់ទងនឹងតំណាងរាស្ត្រដទៃទៀតនៅក្នុងរដ្ឋសភាផងដែរ ដែលសរុបមានប្រមាណ ៩% (ឬ៤ម៉ោង ៣១នាទី) គឺស្ថិតក្នុងលំដាប់ទី៣។

*តួលេខ ២៣៖ ៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្សទៅលើតំណាងរាស្ត្រដទៃទៀត*




មានតំណាងរាស្ត្រមកពីគណបក្ស៣ ដែលនិយាយដល់អ្នកតំណាងរាស្ត្រដទៃ ក្រៅពីខ្លួនឯង។ គណបក្សប្រជាជនកម្ពុជា បាននាំមុខគេដោយបញ្ចេញមតិបាន៨០% (ឬ៣ម៉ោង ៣៨នាទី) នៃរយៈពេលសរុបនៃការបញ្ចេញមតិ ទៅលើអ្នកតំណាងរាស្ត្រដទៃ។ចំណែកគណបក្សសមរង្ស៊ីបញ្ចេញមតិបាន១៨% (ឬ៤៩នាទី) និងគណបក្សហ្វ៊ុនស៊ិនប៉ិច ២% (៤នាទី)។

*តួលេខ ២៤៖ ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរ យៈពេលសរុបតាមគណបក្សទៅលើអ្នកតំណាងរាស្ត្រដទៃទៀត*




តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិភាគច្រើនក្នុងន័យអព្យាក្រឹត និងអវិជ្ជមាន ចំពោះអ្នកតំណាងរាស្ត្រដទៃ ជាពិសេសចំពោះអ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី។ ខ្លឹមសារអព្យាក្រឹតមាន ៥៩% (ឬ២ម៉ោង ៩នាទី) នៃរយៈពេលដែលតំណាងរាស្ត្រគណបក្សនេះសរុបបញ្ចេញមតិទៅលើតំណាងរាស្ត្រដទៃ។ ហើយខ្លឹមសារអវិជ្ជមាន គឺមាន ៤០% (ឬ១ម៉ោង ២៧នាទី) និងវិជ្ជមានមាន ១% (២នាទី)។

ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ី គឺបញ្ចេញមតិតិចតួចប៉ុណ្ណោះ ត្រង់ចំណុចនេះសរុបបាន៤៩នាទី។ ក្នុងនោះខ្លឹមសារអព្យាក្រឹត៣៤នាទី (៦៩%) វិជ្ជមាន ៤នាទី (៨%) និងអវិជ្ជមាន១១នាទី (២៣%)។ តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចបញ្ចេញមតិបាន៤នាទីក្នុងន័យអព្យាក្រឹត។

- **ការបញ្ចេញមតិទៅលើមណ្ឌលរបស់ខ្លួន និងមណ្ឌលផ្សេងទៀត៖**

រដ្ឋធម្មនុញ្ញមាត្រា៧៧បានកំណត់ថា តំណាងរាស្ត្រក្នុងរដ្ឋសភា គឺជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ អ្នកតំណាងរាស្ត្រអាចមានលទ្ធភាពពេលពិភាក្សាសេចក្ដីព្រាងច្បាប់និយាយពីតួអង្គផ្សេងៗ ដូចជារាជរដ្ឋាភិបាល ក៏ប៉ុន្តែការសង្កេតឃើញថា អ្នកតំណាងរាស្ត្រមិនថាមកពីគណបក្សកាន់

អំណាច ឬគណបក្សជំទាស់ បានភ្ជាប់ការពិភាក្សាសេចក្តីព្រាងច្បាប់ទៅនឹងបញ្ហាមណ្ឌលខ្លួន ឬមណ្ឌលផ្សេងបានតិចតួចប៉ុណ្ណោះ គឺមានប្រមាណ៣% (ឬ១ម៉ោង ១៣នាទី) ក្នុងសម័យប្រជុំទាំង៣៧លើក។

- **ការបញ្ចេញមតិទៅលើចំណុចផ្សេងៗទៀត៖** ក្រៅពីការបញ្ចេញមតិទៅលើចំណុចខាងលើ អ្នកតំណាងរាស្ត្រក៏បានបញ្ចេញមតិទៅលើស្ថាប័នរដ្ឋសភាខ្លួនឯង គណបក្សរបស់ខ្លួន តំណាងរាស្ត្រខ្លួនឯងផ្ទាល់ និងតុលាការដែលចំណុចនីមួយៗត្រូវបានលើចឡោះពី ៣% (ឬប្រមាណជាង១ម៉ោង) ទៅ ៤% (ឬប្រមាណ២ម៉ោង)។ ការបញ្ចេញមតិទៅលើចំណុចទាំងនេះភាគច្រើន គឺក្នុងន័យអព្យាក្រឹត និងវិជ្ជមាន លើកលែងតែស្ថាប័នតុលាការដែលត្រូវបានតំណាងរាស្ត្រគណបក្សសមរង្ស៊ីបញ្ចេញមតិអវិជ្ជមានច្រើន។

ចំណែកការបញ្ចេញមតិទាក់ទងនឹងព្រឹទ្ធសភា គណបក្សផ្សេងក្រៅពីគណបក្សខ្លួន ស្ត្រី និងបញ្ហាផ្សេងៗទៀតរួមគ្នាមានប្រមាណ២ម៉ោង ៧នាទី។

*តារាងទី២៖ ការប៉ាន់ប្រមាណគុណភាពការបញ្ចេញមតិរបស់តំណាងរាស្ត្រ ១០រូប ដែលឈានមុខគេក្នុងការបញ្ចេញមតិ* តាមលំដាប់ពីច្រើនទៅតិច (រយៈពេលជានាទី)( សូមមើលបន្ថែមនៅឧបសម្ព័ន្ធទី ១ )

-សំគាល់:ឯ.ឧ. = ឯកឧត្តម, ល.ជ. = លោកជំទាវ

| ល.រ | ឈ្មោះតំណាងរាស្ត្រ | គណបក្ស | ចំនួនដងឡើងនិយាយ | អព្យាក្រឹត | វិជ្ជមាន | អវិជ្ជមាន | សរុប |
|---|---|---|---|---|---|---|---|
| ១ | ឯ.ឧ. យឹម សុវណ្ណ | | ៣៨ | ២៨០ | ៣១ | ២០៩ | **៥២០** |
| ២ | ឯ.ឧ. សុន ឆ័យ | | ២២ | ២៤០ | ១១ | ៩០ | **៣៤១** |
| ៣ | ល.ជ. មូរ សុខហួរ | | ២៧ | ១៩៦ | ២០ | ៦៩ | **២៨៥** |
| ៤ | ឯ.ឧ. ជាម យៀប | | ២៤ | ១៩២ | ៥០ | ៧ | **២៤៩** |
| ៥ | ឯ.ឧ. ឈាង វុន | | ២១ | ១១៤ | ២៣ | ១៥ | **១៥២** |
| ៦ | ឯ.ឧ. គឹមសួរ ភីរិទ្ធ | | ១១ | ៦៣ | ១៣ | ៦១ | **១៣៧** |
| ៧ | ល.ជ. លី ស្រីវីណា | | ១២ | ១០៩ | ៣ | ១៤ | **១២៦** |
| ៨ | ឯ.ឧ. អេង ឆៃអង | | ១៧ | ៧៧ | ១ | ៣០ | **១០៨** |
| ៩ | ឯ.ឧ. ងួន ញ៉ិល | | ១៦ | ៧២ | ១៥ | ៦ | **៩៣** |
| ១០ | ឯ.ឧ. យូ ហុកគ្រី | | ១០ | ៦៤ | ១៦ | ១០ | **៩០** |

ក្នុងចំណោមតំណាងរាស្ត្រដែលបានបញ្ចេញមតិច្រើនជាងគេ១០រូប ៦រូបគឺមកពីគណបក្សសមរង្ស៊ី ៣រូបមកពីគណបក្សប្រជាជនកម្ពុជា និង១រូបមកពីគណបក្សជាតិនិយម។ តំណាងរាស្ត្រដែលបានបញ្ចេញមតិច្រើនជាងគេចំនួន៣រូប គឺសុទ្ធតែមកពីគណបក្សសមរង្ស៊ី។ ការសង្កេតបង្ហាញថា អ្នកតំណាងរាស្ត្រគណបក្ស សមរង្ស៊ី ភាគច្រើនបញ្ចេញមតិក្នុងន័យអព្យាក្រឹត និងអវិជ្ជមាន ខណៈដែលតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាភាគច្រើន ក្នុងន័យអព្យាក្រឹត និងវិជ្ជមាន។

អ្នកតំណាងរាស្ត្រ យឹម សុវណ្ណ មណ្ឌលភ្នំពេញមកពីគណបក្ស សមរង្ស៊ី បានឡើងបញ្ចេញមតិប្រើរយៈពេលច្រើនជាងគេ ដោយបាន៣៨លើក ប្រើពេលអស់៥២០នាទី (ស្មើនឹង៨ម៉ោង៤០នាទី) ដែលក្នុងនោះ ក្នុងន័យអព្យាក្រឹត្យ៤ម៉ោង ៤០នាទី ក្នុងន័យវិជ្ជមាន៣១នាទី និងអវិជ្ជមាន៣ម៉ោង២៩នាទី។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មកពីគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញដដែល បានឡើងបញ្ចេញមតិច្រើនជាងគេលំដាប់ទី២ ដោយបានឡើងចំនួន២២លើក និងប្រើរយៈពេលអស់៣៤១នាទី (ស្មើនឹង៥ម៉ោង៤១ នាទី) ដែលក្នុងនោះខ្លឹមសារក្នុងន័យអព្យាក្រឹតរយៈពេល ៤ម៉ោង វិជ្ជមាន១១នាទី និងអវិជ្ជមាន១ម៉ោង៣០នាទី។

អ្នកតំណាងរាស្ត្រមណ្ឌលកំពត មូរ សុខហួរ មកពីគណបក្សសមរង្ស៊ីបានបញ្ចេញមតិច្រើនជាងគេលំដាប់ទី ៣ ដែលមានរយៈពេលសរុប ២៨៥នាទី (៤ម៉ោង ៤៥ នាទី)។

ខណៈដែលតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មណ្ឌលព្រៃវែង ជាម យៀប បានច្រើនលំដាប់ទី៤ មានរយៈពេល ២៤៩នាទី (៤ម៉ោង ៩នាទី) និងអ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង **ឈាង វុន** បានលំដាប់ទី៥ ដែលមានរយៈពេលសរុប១៥២នាទី (២ម៉ោង ៣២នាទី)។

ក្នុងចំណោមអ្នកដែលបញ្ចេញមតិច្រើនជាងគេទាំង៥ គឺសុទ្ធតែជាប្រធាន ឬអនុប្រធានក្រុមបញ្ចេញមតិ។ ជាមួយគ្នានេះ អ្នកតំណាងរាស្ត្រដែលបញ្ចេញមតិច្រើនជាងគេ៧នាក់ គឺសុទ្ធតែជាអ្នកតំណាងរាស្ត្រដែលបានបញ្ចេញមតិច្រើនជាងគេកាលពីឆ្នាំមុនផងដែរ។

### ១.៦. គុណភាពនៃការពិភាក្សា និងអនុម័តរបៀបវារៈ

រដ្ឋសភាក្នុងឆ្នាំសង្កេតនេះ (តុលា ២០០៩ - កញ្ញា ២០១០) បានធ្វើការប្រជុំចំនួន ៣៧ដង (ព្រឹក) ដោយបានពិភាក្សា ឬ/និងអនុម័តរបៀបវារៈសរុបចំនួន ៣៥។ ក្នុងចំណោមរបៀបវារៈទាំង៣៥ គឺមាន២៤ដែលជាសេចក្តីព្រាងច្បាប់ និងកិច្ចព្រមព្រៀងដែលបើកឲ្យមានការពិភាក្សា និងអនុម័ត។ ចំណែករបៀបវារៈចំនួន៤គឺទាក់ទងនឹងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងដកអភ័យឯកសិទ្ធិសភាដែលមិនមានការពិភាក្សា។ ចំណែករបៀបវារៈចំនួន៧ផ្សេងទៀត គឺមិនតម្រូវឲ្យមានការអនុម័តនោះទេ។

តាមការសង្កេត អត្ថបទច្បាប់ដែលអ្នកតំណាងរាស្ត្របានទទួលគឺជាមធ្យមតែ ៣ថ្ងៃមុនថ្ងៃប្រជុំតែប៉ុណ្ណោះ ដែលជាហេតុនាំឲ្យតំណាងរាស្ត្រខ្វះខាតការសិក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។

ដោយគិតតែរបៀបវារៈដែលត្រូវពិភាក្សា និងអនុម័តទាំង២៤ គឺបង្ហាញថា ក្នុង១របៀបវារៈគឺជាមធ្យមត្រូវបានពិភាក្សា និងអនុម័តដោយប្រើចន្លោះពេលពី ១ ឬ២កិច្ចប្រជុំ ហើយរយៈពេលបញ្ចេញមតិនោះគឺមានប្រមាណ២ម៉ោង ១០នាទី ដោយមានអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិជាមធ្យមប្រមាណ១៣ ដង។

ការសង្កេតឃើញថា សម័យប្រជុំពេញអង្គរដ្ឋសភាដែលជាកន្លែងតែមួយគត់ដែលគណបក្សចម្រុះអាចពិភាក្សា និងពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់ គឺធ្វើឡើងសម្រាប់តែដើម្បីអនុម័តរបៀបវារៈដែលបានស្នើឡើងតែប៉ុណ្ណោះ។

អ្នកតំណាងរាស្ត្រគណបក្សកាន់អំណាច ក៏ដូចជារាជរដ្ឋាភិបាល ជារឿយៗតែងលើកឡើងថា សេចក្តីព្រាងច្បាប់ត្រូវបានពិភាក្សា និងសួរដេញដោលយ៉ាងពិស្តារ ឬកែប្រែនៅតាមគណៈកម្មការជំនាញរបស់រដ្ឋសភា មុននឹងឈានដល់សម័យប្រជុំពេញអង្គ។ ក៏ប៉ុន្តែនៅនីតិកាលទី៤នេះ គ្មានតំណាងរាស្ត្រគណបក្សជំទាស់ណាមួយនៅក្នុងគណៈកម្មការជំនាញនោះទេ។ ហើយគ្រប់គណៈកម្មការទាំងអស់ គឺសុទ្ធតែគ្រប់គ្រងដោយគណបក្សកាន់អំណាច។ ដូចនេះបានន័យថា សេចក្តីព្រាងច្បាប់ គឺតាក់តែងឡើងដោយរាជរដ្ឋាភិបាលដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ហើយយកមកពិភាក្សាតែក្នុងចំណោមតំណាងរាស្ត្រក្នុងគណៈកម្មការដែលសុទ្ធតែជាគណបក្សប្រជាជនកម្ពុជាដដែល។

ដូចនេះបានន័យថា សេចក្តីព្រាងច្បាប់ដែលត្រូវបានរដ្ឋសភាអនុម័តនោះ គឺភាគច្រើនមិនមានការចូលរួមពីចម្រុះគណបក្សនោះទេ មុននឹងត្រូវបានចូលក្នុងរដ្ឋសភាពេញអង្គ ហើយពេលចូលដល់រដ្ឋសភាពេញអង្គ គឺសម្រាប់តែការអនុម័តប៉ុណ្ណោះ គឺមានន័យថា ការកែប្រែ ឬអនុសាសន៍នានាដែលមកពីតំណាងរាស្ត្រគណបក្សផ្សេងទៀត គឺមិនត្រូវបានបញ្ចូល។

ទោះបីជា នៅសម័យប្រជុំពេញអង្គជាកន្លែងដែលតំណាងរាស្ត្រមិនកាន់អំណាចអាចបញ្ចេញមតិក៏ដោយ ក៏ការចូលរួមរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សភាគតិចទៅលើសេចក្តីព្រាងច្បាប់ គឺស្ទើរតែមិនមាន ឬមិនមានទាល់តែសោះ ដោយសារតែតំណាងរាស្ត្រមកពីគណបក្ស ភាគតិចមិនអាចបង្កើតក្រុមបញ្ចេញមតិរបស់ខ្លួនបាន ហើយត្រូវបានផាត់ចេញពីការបញ្ចេញមតិក្នុងសម័យប្រជុំពេញអង្គ លើកលែងតែតំណាងរាស្ត្រនោះត្រូវទៅចូលរួមជាមួយក្រុមរបស់គណបក្សដទៃ។

## ១.៧. សេចក្តីព្រាងច្បាប់សំខាន់ៗត្រូវបានអនុម័តហើយបន្សល់នូវភាពចម្រូងចម្រាស

ក្នុងឆ្នាំសង្កេតនេះ រដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់សំខាន់ៗមានចំនួន១៤ច្បាប់ ដូចជាសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ សេចក្តីព្រាងក្រមព្រហ្មទណ្ឌ សេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី សេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍ (ការដកហូតទ្រព្យសម្បតិឯកជនដោយស្របច្បាប់) សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

### <u>សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ</u>

ក្នុងឆ្នាំសង្កេតនេះ រដ្ឋសភាបានពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលរាជរដ្ឋាភិ បាលបានសន្យាជាយូរឆ្នាំមកហើយ។

សេចក្តីព្រាងច្បាប់នេះ មានគោលបំណងសំខាន់គឺលើកកម្ពស់ប្រសិទ្ធិភាពសេវាគ្រប់យ៉ាង ពង្រឹងអភិបាលកិច្ច និងនីតិរដ្ឋនៅក្នុងការដឹកនាំ និងការគ្រប់គ្រងរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌ដែលជាមូលដ្ឋានចាំបាច់ ក្នុងការអភិវឌ្ឍន៍ជាតិ និងកាត់បន្ថយភាពក្រីក្រ......ទោះបីយ៉ាងណា ការពិភាក្សា និងការអនុម័តនោះបន្សល់នូវភាពចម្រូងចម្រាសជាច្រើនក្នុងរង្វង់សមាជិកសភាមកពីគណបក្សកាន់អំណាច និងគណបក្សជំទាស់ ទាក់ទងនិងរយៈពេលដ៏ខ្លីដែលទទួលបានសេចក្តីព្រាងច្បាប់ និងការពិភាក្សា និងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ទាំងមូល។

**ភាពចម្រូងចម្រាសទាក់ទងនឹងពេលវេលាដែលច្បាប់ចូលរដ្ឋសភាៈ** រយៈពេលដែលសេចក្តីព្រាងច្បាប់នេះ ចែកផ្សាយជាសាធារណៈដល់តំណាងរាស្ត្រ មុនពេលប្រជុំពិភាក្សា គឺមិនដល់២ថ្ងៃនៃថ្ងៃធ្វើការទេ។ អ្នកតំណាងរាស្ត្រប្រឆាំង និងសង្គមស៊ីវិលបានរិះគន់ទៅលើរយៈពេលដ៏ខ្លីសម្រាប់ខ្លួនធ្វើការសិក្សាសេចក្តីព្រាងច្បាប់នេះ ដើម្បីសិក្សា និងចូលរួមផ្តល់អនុសាសន៍ហើយបានស្នើឱ្យមានការពន្យារការពិភាក្សានិងអនុម័ត។ ទោះបីយ៉ាងណាការស្នើនេះត្រូវបានបដិសេធ។

សេចក្តីព្រាងព្រោះច្បាប់នេះ ចែកជូនអ្នកតំណាងរាស្ត្រនៅល្ងាចថ្ងៃទី៥ ខែមីនា ហើយថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ជាថ្ងៃដែលរដ្ឋសភាធ្វើការពិភាក្សា។ ទោះបីយ៉ាងណា ពីថ្ងៃទី០៦ ដល់ថ្ងៃទី០៨ ខែមីនា គឺជាថ្ងៃឈប់សម្រាក។

នៅខណៈដែលច្បាប់នេះកំពុងពិភាក្សានៅរដ្ឋសភា ក្រុមការងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ដោយឡែកនៅថ្ងៃទី១០ខែមីនា បង្ហាញពីកង្វល់របស់ខ្លួនថា សេចក្តីព្រាងច្បាប់នេះត្រូវបានចែករំលែកជាសាធារណៈក្នុងរយៈពេលដ៏ខ្លី ហើយបានស្នើឱ្យមានដំណើរការពិគ្រោះយោបល់មួយដែលមានការចូលរួមនិងតម្លាភាព។

**ភាពចម្រូងចម្រាសក្នុងអំឡុងពេលពិភាក្សានិងអនុម័តៈ** មានតំណាងរាស្ត្រមកពី៤គណបក្សប៉ុណ្ណោះ ដែលបានចូលរួមសម័យប្រជុំ ដើម្បីពិភាក្សាសេចក្តីព្រាងច្បាប់នេះដោយតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានធ្វើពហិការ។ មាត្រាមួយចំនួនបានបន្សល់ទុកនូវភាពចម្រូងចម្រាស ដូចជាសមាសភាពរបស់ក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយ ការប្រកាសទ្រព្យសម្បត្តិ និងការផ្តន្ទាទោសអ្នករាយការណ៍ព័ត៌មានមិនពិត។ល។

មាត្រា៦ទាក់ទងនឹងរចនាសម្ព័ន្ធក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវបានអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងយល់ថា អាចនឹងមិនមានឯករាជ្យ និងមិនមានអំណាចពេញលេញ។ ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាលបានលើកឡើងថា ការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺទាមទារនូវឆន្ទៈ។

មាត្រា២០ ដែលនិយាយពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលជាសម្ងាត់ ក៏ត្រូវបានតំណាងរាស្ត្រគណបក្សប្រឆាំងយល់ថា មិនត្រឹមត្រូវដែរ ហើយបានស្នើឱ្យធ្វើការប្រកាសជាសាធារណៈវិញ ដើម្បីឱ្យប្រជាពលរដ្ឋនិងស្ថាប័នពាក់ព័ន្ធនានាបានដឹងបានឮ។ ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាលបានលើកឡើងពីសុវត្ថិភាពរបស់ម្ចាស់ទ្រព្យថា ជាហេតុផលមួយដែលត្រូវប្រកាសជាសម្ងាត់។

ការផ្តន្ទាទោសចំពោះជនដែលផ្តល់ពត៌មានមិនពិតអំពីអំពើពុករលួយ ក៏បានក្លាយជាប្រធានបទពិភាក្សាគ្នាដ៏ចម្រូងចម្រាសដែរ ដោយតំណាងរាស្ត្រគណបក្សប្រឆាំងបានលើកឡើងថា ការផ្តន្ទាទោសនេះអាចត្រឹមតែការផាកពិន័យជាប្រាក់បានហើយ តែកុំឱ្យដល់មានការដាក់ពន្ធនាគារ ព្រោះវានឹងមិនជម្រុញឱ្យមានការចូលរួមក្នុងការរែកមុខអ្នកប្រព្រឹត្តអំពើពុករលួយនោះទេ។

ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាល និងតំណាងរាស្ត្រគណបក្សកាន់អំណាចបានលើកឡើងថា នេះគឺដើម្បីផ្តល់យុត្តិធម៌ដល់អ្នកដែលពិតជាស្អាតស្អំ និងការពារការប្តឹងចោទដែលគ្មានភស្តុតាង។

មាត្រា៤១នៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយចែងថា «អំពើប្តឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការ......នាំឱ្យមានការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ៦ខែ និងពិន័យជាប្រាក់ពី១០០០០០រៀលទៅ១០០០០០០រៀល»។

ការសង្កេតឃើញថា នៅក្នុងអំឡុងពេលពិភាក្សាសេចក្តីព្រាងច្បាប់នេះ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានស្នើធ្វើវិសោធនកម្មជំពូកមួយចំនួន ក៏ប៉ុន្តែមិនទទួលបានជោគជ័យនោះទេ។

នៅថ្ងៃពិភាក្សាចុងក្រោយ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានធ្វើពហិការប្រជុំ ហើយសេចក្តីព្រាងច្បាប់នេះក៏ត្រូវបានអនុម័តដោយសំលេងអនុម័ត៨២/៨២ ដោយអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាហ្វ៊ុនស៊ិនប៉ិច និងជាតិនិយម។

ក្រោយពីច្បាប់នេះបានអនុម័តចប់នៅរដ្ឋសភា ក៏មានប្រតិកម្មពីខាងរាជរដ្ឋាភិបាលផងដែរ រហូតមានការគំរាមបណ្តេញចេញអ្នកសម្របសម្រួលប្រចាំប្រទេសកម្ពុជារបស់អង្គការសហប្រជាជាតិ ដែលក្រុមនេះបានចេញសេចក្តីថ្លែងការណ៍រិះគន់ពីរយៈពេលដ៏ខ្លី ដែលច្បាប់នេះចែកជូនជាសាធារណៈ និងដល់តំណាងរាស្ត្រ។

**<u>សេចក្តីព្រាងក្រមព្រហ្មទណ្ឌ៖</u>**

សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ត្រូវបានសភាពិភាក្សា និងអនុម័តនៅខែតុលាឆ្នាំ២០១០។ ក្រមនេះមានគោលបំណងដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់ថ្មីនៃបទល្មើស ព្រមទាំងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗប្រកបដោយប្រសិទ្ធិភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងគោលដៅធានាការពារឲ្យបាននូវសេរីភាព សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ គឺជារបៀបអធិភាពមួយនៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ខ្លួន និងដើម្បីជួយបំពេញកង្វះខាតនូវអ្វីដែលក្រមនិតិវិធីព្រហ្មទណ្ឌមានចន្លោះប្រហោង.......។ ទោះបីយ៉ាងណាមាត្រាខ្លះនៃសេចក្តីព្រាងក្រមនេះបានបន្សល់ទុកនៅភាពចម្រូងចម្រាស និងការរិះគន់ពីសំណាក់តំណាងរាស្ត្រប្រឆាំងនិងអង្គការសង្គមស៊ីវិលសិទ្ធិមនុស្ស និងច្បាប់មួយចំនួនដែលស្នើឱ្យមានការកែប្រែតែមិនបានសម្រេច។

មាត្រាដែលមានភាពម្រូងចម្រាសខ្លាំងនោះ គឺនៅត្រង់ផ្នែកនិយាយពីបទបរិហារកេរ្តិ៍ និងការជេរប្រមាថ និងការប្តឹងបរិហារ បង្កាច់កេរ្តិ៍ឈ្មោះ និងការរិះគន់ទៅលើលិខិត និងសេចក្តីសម្រេចរបស់តុលាការ។

ទោះបីទោសពីបទបរិហារកេរ្តិ៍ និងការជេរប្រមាថមានកម្រិតត្រឹមបង់ប្រាក់ពិន័យ និងគ្មានជាប់ពន្ធនាគារក្តី ក៏អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីស្នើឱ្យលុបមាត្រាទាំងនេះចេញពីក្រមព្រហ្មទណ្ឌ ដើម្បីការពារសិទ្ធិក្នុងការបញ្ចេញមតិ។ ចំណែកការប្តឹងបរិហារបង្កាច់កេរ្តិ៍ឈ្មោះ គឺតម្រូវឱ្យបង់ប្រាក់ពិន័យផង និងជាប់ពន្ធនាគារផង។

មាត្រា៥២៣នៃក្រមព្រហ្មទណ្ឌ ស្តីពីការដាក់ទោសអ្នករិះគន់តុលាការ ក៏ត្រូវទទួលរងការិះគន់ពីសង្គមស៊ីវិលផងដែរ ដោយសារតែវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិបញ្ចេញមតិ និងរិះគន់ស្ថាប័នជាតិសាធារណៈ។ មាត្រានេះចែងថា "អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពរឹករវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ) ខែទៅ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី១០០០០០ (មួយសែន) រៀលទៅ១០០០០០០ (មួយលាន) រៀល។..."

ទោះបីជាមានភាពចម្រូងចម្រាសនេះក៏ដោយ ក៏សេចក្តីព្រាងក្រមព្រហ្មទណ្ឌនេះដែលមានរហូតដល់ទៅ៦៧២មាត្រា ត្រូវបានរដ្ឋសភាពិភាក្សារយៈពេលតែ៧ព្រឹកប៉ុណ្ណោះ ដែលការពិភាក្សាប្រើរយៈពេលអស់ប្រមាណ១៣ម៉ោងហើយអនុម័តក្នុងសម្លេង៩៩/១០២។

**<u>សេចក្តីព្រាច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី៖</u>**

សេកថ្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានរដ្ឋសភាពិភាក្សា និងអនុម័តនៅក្នុងខែតុលា ឆ្នាំ ២០០៩។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងត្រូវកំណត់អំពីការរៀបចំ និងការប្រព្រឹតទៅនៃការធ្វើបាតុកម្មដោយសន្តិវិធីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ធានាឲ្យមានសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ដោយមិនឲ្យមានការរំលោភនាំឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។ សេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តដោយបន្សល់នូវភាពចម្រូងចម្រាសជាច្រើន រហូតមានតំណាងរាស្ត្រមួយចំនួនបានធ្វើពហិការមិនគាំទ្រសេចក្តីព្រាងច្បាប់នេះ។

សេចក្តីព្រាងច្បាប់នេះ ដែលមាន៣០មាត្រា ត្រូវបានពិភាក្សាអស់រយៈពេលប្រមាណ៧ម៉ោងប៉ុណ្ណោះ ហើយអនុម័តដោយសម្លេង៧៦/១០១។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានតំណាងរាស្ត្រគណបក្សប្រឆាំងយល់ឃើញថា ជាការបំបិទសិទ្ធិបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ហើយមិនស្របទៅតាមលទ្ធិប្រជាធិបតេយ្យ ដោយសារតែមាត្រា១៤នៃសេចក្តីព្រាងច្បាប់នេះ បានកំណត់ពីចំនួនមនុស្សធ្វើបាតុកម្ម មិនឱ្យលើសពី២០០នាក់នៅកន្លែងបញ្ចេញមតិសាធារណៈ ដែលបានបង្កើតឡើងតាមច្បាប់ ឬនៅតាមទីកន្លែងជាទ្រព្យសម្បត្តិឯកជន ហើយការធ្វើបាតុកម្មនេះនៅចន្លោះពីម៉ោង៦ព្រឹក ដល់ម៉ោង៦ល្ងាច។

ក្នុងករណីនេះ អ្នកធ្វើបាតុកម្មគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរ មានចុះហត្ថលេខា ឬស្នាមផ្តិតមេដៃ និងភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ថតចម្លងរបស់អ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធីចំនួន៣រូបប៉ុណ្ណោះ ទៅខេត្ត ឬរាជធានីមានសមត្ថកិច្ចនៅមូលដ្ឋាននោះ។

ទោះបីយ៉ាងណាមាត្រា៩នៃច្បាប់នេះ ក៏បានអនុញ្ញាតឱ្យមានការធ្វើបាតុកម្មនៅទីកន្លែងសាធារណៈផ្សេងទៀត និងការដង្ហែរក្បួនផងដែរ តែមាត្រា៦តម្រូវឱ្យអ្នកដឹកនាំធ្វើបាតុកម្មបំពេញនូវលក្ខខណ្ឌជាច្រើន ដូចជាអត្តសញ្ញាណអ្នកដឹកនាំចំនួន៣រូបគោលបំណងនៃការធ្វើបាតុកម្ម កាលបរិច្ឆេទ និងរយៈពេលធ្វើបាតុកម្ម ទីកន្លែងធ្វើបាតុកម្ម និងផ្លូវដែលត្រូវប្រើប្រាស់ ចំនួនអ្នកចូលរួមបាតុកម្ម និងចំនួនយានជំនិះតាមប្រភេទនីមួយៗ។

ចំណែកមាត្រា៩ បានផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរខេត្ត និងរាជធានីជាអ្នកសម្រេចថា មិនអនុញ្ញាតឱ្យធ្វើ ប្រសិនបើការធ្វើនោះ ប៉ះចំថ្ងៃបុណ្យទាន/ឈប់សម្រាករបស់ប្រទេស... ឬមានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

**<u>សេចក្តីព្រាច្បាប់ស្តីពីអស្សាមិករណ៍៖</u>**

សេចក្តីព្រាងច្បាប់ស្តីពីអស្សាមិករណ៍ ឬច្បាប់ស្តីពីការដកហូតអចលនវត្ថុ (សំណង់ដី...) ស្របច្បាប់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ត្រូវបានរដ្ឋសភាពិភាក្សា និងអនុម័តនៅចុងខែធ្នូឆ្នាំ២០០៩ ក្នុងការពិភាក្សា២ព្រឹក ដែលប្រើរយៈពេលប្រមាណ៥ម៉ោង ហើយអនុម័តក្នុងសម្លេង៧៦/១០០។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានអ្នកតំណាងរាស្ត្រគណបក្សជំទាស់យល់ឃើញថា មិនគួរមាននៅកាលៈទេសៈនេះទេ ប្រជាពលរដ្ឋមិនទាន់មានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី ផ្ទះសម្បែងបានគ្រប់គ្នា ម្យ៉ាងទៀតភាពដោយសារមានជំពូកខ្លះនៃច្បាប់នេះ គឺមិនទាន់មានធម្មនុញ្ញភាព និងមូលដ្ឋានត្រឹមត្រូវ និងតុលាការកម្ពុជាមិនទាន់មានឯករាជ្យភាព។ ហើយស្នើឲ្យពន្យារពេលពិភាក្សា និងអនុម័តរហូតដល់ប្រជាពលរដ្ឋទាំងអស់មានប្លង់កម្មសិទ្ធ។

ទោះបីយ៉ាងណារាជរដ្ឋាភិបាល និងតំណាងរាស្ត្រគណបក្សកាន់អំណាចបានពេញចិត្ត និងការពារជំហរឲ្យមានច្បាប់នេះ ព្រោះវាសមស្របនឹងប្រទេសដែលកំពុងអភិវឌ្ឍន៍ ដោយសារការអភិវឌ្ឍន៍ប្រទេសត្រូវការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម ហើយដើម្បីជួយការពារប្រយោជន៍ប្រជាពលរដ្ឋដែលរងការប៉ះពាល់ដោយគំរោងអាស្សាមិករណ៍ និងដើម្បីអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការជឿនលឿន។

ជាទីបញ្ចប់ ច្បាប់នេះត្រូវសមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាបោះឆ្នោតឲ្យយកមកពិភាក្សា និងអនុម័តក្នុងសម័យប្រជុំពេញអង្គ ហើយមានមាត្រាខ្លះបានបន្សល់ទុកនូវភាពចម្រូងចម្រាស រវាងតំណាងរាស្ត្រគណបក្សកាន់អំណាច និងប្រឆាំងទាក់ទងនឹងការដកហូតទ្រព្យស្របច្បាប់ បើទោះបីម្ចាស់ទ្រព្យមិនយល់ព្រម និងការដាក់ទោសដល់ម្ចាស់ទ្រព្យពេលធ្វើការរាំង។

មាត្រា១៩ នៃច្បាប់នេះកំណត់ថា "...ការដកហូតនៅតែប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី។ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់..."។

អ្នកតំណាងរាស្ត្រគណបក្សជំទាស់បានស្នើកែប្រែដោយមិនឲ្យមានការដកហូតចំពោះដីធ្លី (អចលនទ្រព្យ)របស់ប្រជាពលរដ្ឋ ប្រសិនបើទំនាស់មិនត្រូវបានដោះស្រាយ និងធ្វើយ៉ាងណាឲ្យមានសំណងសមរម្យដែលម្ចាស់សិទ្ធិអាចទទួលយកបាន និងសមស្របតាមតំលៃទីផ្សារ។ ប៉ុន្តែខាងរាជរដ្ឋាភិបាលបានបកស្រាយថា ការដកហូតនេះ ត្រូវតែដកប៉ុន្តែម្ចាស់សិទ្ធិដែលរងផលប៉ះពាល់ពីការធ្វើអាស្សាមិករណ៍ អាចនៅមានសិទ្ធិប្តឹងតវ៉ាបាន ហើយការប្តឹងនោះ គឺប្តឹងដើម្បីតែបានតំលៃសមរម្យ និងយុត្តិធម៌ តែមិនមែនប្តឹងឲ្យឈប់ធ្វើអាស្សាមិករណ៍ទេ។

មាត្រា៣៤ បានបើកសិទ្ធិឲ្យម្ចាស់ទ្រព្យធ្វើការប្តឹងដល់តុលាការ ដោយបានកំណត់ថា "ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌ ...។

ទោះបីយ៉ាងណា តំណាងរាស្ត្រគណបក្សជំទាស់យល់ថា ការដំណើរការទៅតុលាការ គឺជារឿងលំបាកសម្រាប់ប្រជាពលរដ្ឋក្រីក្រ ដោយសារតែប្រព័ន្ធតុលាការមិនមានភាពយុត្តិធម៌ ហើយជនរងគ្រោះភាគច្រើន គឺជាអ្នកក្រីក្រ។ ទោះបីយ៉ាងណា តំណាងរាជរដ្ឋាភិបាលបានបំភ្លឺថា ប្រព័ន្ធយុត្តិធម៌កំពុងតែមានការកែប្រែ និងអភិវឌ្ឍន៍កាន់តែប្រសើរថែមទៀតដូចនេះ នៅពេលសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយចេញ នោះនឹងជាចំណែករួមមួយដើម្បីប្រព័ន្ធយុត្តិធម៌នៅកម្ពុជាកាន់តែប្រសើរ។

មាត្រា៣៦ ដែលដាក់ទោសដល់អ្នករារាំងដល់ការអនុវត្តន៍ការដកហូតរហូតដល់ជាប់ពន្ធនាគារ ក៏ត្រូវបានរិះគន់ផងដែរ។ មាត្រានេះកំណត់ថា «បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តន៍សេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិតធ្វើឲ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តន៍គម្រោងដែលបម្រើឲ្យផលប្រយោជន៍សាធាណៈ ឬផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ដល់១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀល ដល់ ២.០០០.០០០(ពីរលាន)រៀល។» អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងបានស្នើសុំកុំឲ្យមានទោសទណ្ឌជាប់ពន្ធធនាគារ គឺសុំ

ត្រឹមបង់ពិន័យបន្តិចបន្តួចបានហើយ លើការតវ៉ារារាំងមិនឲ្យមានការធ្វើគម្រោងអាស្សាមិករណ៍ ព្រោះដើម្បីកុំឲ្យប្រជាពលរដ្ឋ ឬម្ចាស់សិទ្ធិក្លាយជាជនរងគ្រោះមួយថែមទៀត។ ចំណែកការឆ្លើយតបរបស់រដ្ឋាភិបាល ជាអ្នកការពារសេចក្តីព្រាងច្បាប់នេះមិនទទួលយកសំណើនេះទេ ដោយថាអ្នករារាំងបង្កចលាចល បង្អាក់ រំខានដល់ដំណើរការនៃគម្រោងអាស្សាមិករណ៍ គឺត្រូវ តែទទួលទោស ហើយទោសនេះ គឺបានផ្អែកតាមក្រមព្រហ្មទណ្ឌនៅពេលច្បាប់នេះចូលជាធរមាន។

## ២. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

រដ្ឋធម្មនុញ្ញមាត្រា ៧៧ បានកំណត់ថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ មាត្រា៨៣ក៏បានកំណត់ដែរថា រដ្ឋសភាប្រជុំជាសមញ្ញពីរដងក្នុងមួយឆ្នាំ ដោយសម័យប្រជុំមួយដងមានថិរៈវេលាយ៉ាងតិចបីខែ។

ដូចនេះបានន័យថា សមាជិកសភាអាចមានពេលសម្រាកពីការប្រជុំ៦ខែក្នុងមួយឆ្នាំ សម្រាប់សកម្មភាពការងារផ្សេងៗក្នុងនាមជាតំណាងប្រជាពលរដ្ឋ។ ទោះបីជានៅក្នុងរយៈពេលសម័យប្រជុំ៣ខែក៏ដោយ ក៏ការសង្កេតបង្ហាញថា រដ្ឋសភាមិនមែនប្រជុំពេញ៣ខែនោះដែរ។ ដូចនេះតំណាងរាស្ត្រក្រៅពីការប្រជុំពិភាក្សានៅវិមានរដ្ឋសភា ក៏បានចំណាយពេលវេលារបស់ខ្លួនចុះទៅមូលដ្ឋានជួបម្ចាស់ឆ្នោតផងដែរ។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានរាប់ជាដង។ ទោះបីយ៉ាងណា ខុមហ្វ្រែលជួបឧបសគ្គខ្លះក្នុងការប្រមូលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ។

ឈរលើមូលដ្ឋាននេះ ខុមហ្វ្រែលយល់ថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺអាចមានច្រើនជាងទិន្នន័យដែលខុមហ្វ្រែលប្រមូលបាន។ ដូចនេះ ការវិភាគនៅក្នុងរបាយការណ៍នេះ គឺផ្អែកទៅលើតែទិន្នន័យដែលខុមហ្វ្រែលប្រមូលបានតែប៉ុណ្ណោះ។

### ២.១. ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន

តាមទិន្នន័យខុមហ្វ្រែលបង្ហាញថា ក្នុងឆ្នាំសង្កេតនេះមានអ្នកតំណាងរាស្ត្រសរុប១០៩រូប ក្នុងចំណោម១២៣រូបមកពីគ្រប់គណបក្សជាប់ឆ្នោតបានចុះមូលដ្ឋានសរុប១៧២១លើក ឬជាមធ្យមក្នុងមួយខែអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប១៤៣លើក ឬមួយថ្ងៃមានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានប្រមាណ៥លើក។

*តួលេខ ២៥៖ កំណើនចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន និងចំនួនចុះមូលដ្ឋានជា% ធៀងនឹងឆ្នាំ២០០៨-២០០៩*




បើធៀបឆ្នាំមុន ចំនួនចុះមូលដ្ឋានគឺមានការកើនឡើង ប្រមាណ ៦៩% ហើយចំនួនតំណាងរាស្ត្រចុះមូលដ្ឋាន គឺមានកំណើនប្រមាណ១១% (ឆ្នាំមុនមានអ្នកតំណាងរាស្ត្រសរុប៩៨រូបចុះមូលដ្ឋាន បានសរុប១០១៨លើក)។

បើគិតជាមធ្យម គឺអ្នកតំណាង

រាស្ត្រមួយរូបក្នុងចំណោមតំណាងរាស្ត្រដែលចុះមូលដ្ឋាន គឺចុះមូលដ្ឋានបានប្រមាណ១៦លើក ក្នុង១ឆ្នាំ ឬក្នុងមួយខែអ្នកតំណាងរាស្ត្រម្នាក់ចុះមូលដ្ឋានបានចន្លោះពី១ ដងទៅ២ដងជាមធ្យម។

*<u>តួលេខ ២៦៖ចំនួន និងភាគរយតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងចុះមូលដ្ឋានសរុប</u>*




បើធៀបនឹងចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូល ដ្ឋានច្រើនជាងគេ ដែលមាន៧២%(ឬ៧៩រូប) នៃអ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋាន សរុបទាំងអស់ ១០៩រូប។ តំណាងរាស្ត្រ គណបក្សសមរង្ស៊ី ច្រើនលំដាប់ទី២ មាន ២២%(ឬ២៤រូប) គណបក្សសិទ្ធិមនុស្ស៣%(៣រូប) គណបក្សជាតិនិយម១% (១រូប) និងគណបក្សហ៊្វុនស៊ិនប៉ិច ២% (២រូប)។

*<u>តួលេខ ២៧៖ភាគរយនៃអាសនៈរដ្ឋសភា និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុបតាមគណបក្ស</u>*




បើធ្វើការប្រៀបធៀបភាគរយនៃចំនួនអាសនៈសរុបតាម គណបក្ស និងភាគរយនៃចំនួនអ្នកតំណាងរាស្ត្រ ចុះមូលដ្ឋានសរុបតាមគណបក្ស គឺស្ទើរតែសមាមាត្រគ្នា។ ដូចនេះ បានន័យថា ភាគរយតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋាន គឺស្ទើរតែស្មើទៅនឹងភាគរយនៃអាសនៈដែលគណបក្សនីមួយៗទទួលបាននៅរដ្ឋសភា។

ក្នុងចំណោមអ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋានសរុប មានចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា៧២% ខណៈដែលគណបក្សនេះ មានអាសនៈនៅសភា៧៣%នៃអាសនៈសភាសរុប។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីមាន ២២% ខណៈអាសនៈក្នុងសភាមាន២១% តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមាន៣% ខណៈអាសនៈក្នុងសភាមាន២% គណបក្សជាតិនិយមមាន១% ខណៈអាសនៈក្នុងសភាមាន២% និងគណបក្សហ៊្វុនស៊ិនប៉ិចមាន២% និងអាសនៈក្នុងសភាមាន២%។

*តួលេខ ២៨៖ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន*




បើសិក្សាទៅលើអ្នកតំណាងរាស្ត្របានចុះមូលដ្ឋានធៀបនឹងចំនួនតំណាងរាស្ត្រ សរុបក្នុងគណបក្សរបស់ខ្លួនវិញ បង្ហាញថា មានតែគណបក្ស២ប៉ុណ្ណោះ ដែលតំណាងរាស្ត្ររបស់ខ្លួនទាំងអស់បានចុះមូលដ្ឋាន គឺគណបក្សសិទ្ធិមនុស្សដែលមានតំណាងរាស្ត្ររូប៣រូប និងគណបក្សហ៊្វុនស៊ិនប៉ិចដែលមានតំណាងរាស្ត្រសរុប២រូប។

ចំណែកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានតំណាងរាស្ត្ររបស់ខ្លួនសរុប៨៨% (នៃតំណាងរាស្ត្ររបស់ខ្លួនសរុប ៩០រូប) និងគណបក្សសមរង្ស៊ីមនា៩២% (នៃតំណាងរាស្ត្រសុរប ២៦រូប)។ ចំណែកគណបក្សជាតិនិយមមានតែ១រូបក្នុងចំណោម២រូប។

*តួលេខ ២៩៖ ចំនួន នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុបតាមគណបក្ស*




ក្នុងឆ្នាំសង្កេតនេះ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចំនួន ៧៩រូប បានចុះមូលដ្ឋានសរុបបាន ៩៧៤លើក (ឆ្នាំ២០០៨-២០០៩ មានអ្នកតំណាងរាស្ត្រ ៦៩រូប ចុះមូលដ្ឋានបាន៨២២លើក)។ ជាមធ្យមអ្នកតំណាងរាស្ត្រម្នាក់ ក្នុងចំណោមតំណាងរាស្ត្រទាំង៧៩រូប បានចុះមូលដ្ឋានបាន១២លើក ឬជាមធ្យមចុះមូលដ្ឋានបាន១លើកក្នុង១ខែក្នុងតំណាងរាស្ត្រម្នាក់ៗ។

គណបក្សសមរង្ស៊ីមាន២៤រូបចុះមូលដ្ឋានបានចំនួន៣៩៧លើក (ឆ្នាំ២០០៨-២០០៩ មាន២២រូបចុះមូលដ្ឋានសរុបបាន១៥៦លើក)។ ជាមធ្យមអ្នកតំណាងរាស្ត្រម្នាក់ ក្នុងចំណោមតំណាងរាស្ត្រទាំង២៤រូបចុះមូលដ្ឋានសរុបបានជិត១៧លើកក្នុង១ឆ្នាំ ឬក្នុង១ខែចុះបានចន្លោះពី១ទៅ២លើក។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូបចុះមូលដ្ឋានបាន

៣៣៦លើក (ឆ្នាំ២០០៨-២០០៩ មាន៣រូបចុះមូលដ្ឋានបាន២៤លើក)។ ជាមធ្យមតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស១រូបចុះបាន១១២លើកក្នុង១ឆ្នាំ ឬជាមធ្យមក្នុង១ខែម្នាក់ចុះបានប្រមាណ៩លើក។

តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច២រូបចុះបបាន៦លើកក្នុង១ឆ្នាំសង្កេតនេះ (ឆ្នាំសង្កេតមុនមាន២រូបចុះបាន៩លើក) និងតំណាងរាស្ត្រគណបក្សជាតិនិយម១រូបចុះបាន៨លើក (ឆ្នាំសង្កេតមុនមាន២រូបចុះបាន៧លើក)។

## ២.២. គោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

គោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ត្រូវបានបែងចែកជា៥ គឺ ១. ចុះសួរសុខទុក្ខ ចែកអំណោយសម្ភោធសមិទ្ធផលនានា (សួរសុខទុក្ខ) ២. ការចុះមូលដ្ឋានដើម្បីពង្រឹងបណ្ដាញគណបក្សរបស់ខ្លួន (ពង្រឹងគណបក្ស) ៣. ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ (អមដំណើរ) ៤. ការចូលរួមវេទិកា/សិក្ខាសាលាសាធារណៈ (វេទិកា) និង ៥. ចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានា (អន្តរាគមន៍)។

*<u>តួលេខ៣០៖ ភាគរយនៃគោលបំណងនីមួយរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស ធៀបនឹងគោលបំណងសរុបតាមគណបក្ស</u>*




តួលេខ៣០ បង្ហាញពីភាគរយតាមគោលបំណងនៃគណបក្សនីមួយៗ ដើម្បីប្រៀបធៀបថា ក្នុងចំណោមការចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន តើគណបក្សនោះផ្ដោតទៅលើគោលបំណងណាសំខាន់ជាងគេ។ អ្នកតំណាងរាស្ត្រស្ទើរគ្រប់គណបក្សដែលចុះមូលដ្ឋានភាគច្រើន គឺផ្ដោតខ្លាំងទៅលើការសួរសុខទុក្ខចែកអំណោយ និងការសម្ភោធសមិទ្ធផលនានា និងគោលំណងដើម្បីពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សរបស់ខ្លួន។ តំណាងរាស្ត្រគណបក្សកាន់អំណាចបានផ្ដោតខ្លាំងជាងតំណាងរាស្ត្រគណបក្សដទៃទៀតក្នុងការចុះមូលដ្ឋានក្នុងគោលបំណងសួរសុខទុក្ខ។ ចំណែកគណបក្សដទៃទៀត គឺផ្ដោតខ្លាំងទៅលើការពង្រឹងផ្ទៃក្នុងគណបក្សរបស់ខ្លួន។ (សូមមើលពិស្តារនៅតារាងទី៣ខាងក្រោម)។

*<u>តារាងទី ៣ ៖ ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង</u>*

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ១៧២១លើក របស់តំណាងរាស្ត្រទាំង ១០៩រូប** | **គណបក្សនយោបាយ** | | | | | **សរុបនៃគោលបំណង** |
|---|---|---|---|---|---|---|
| | ៧៩រូប | ២៤រូប | ៣រូប | ២រូប | ១រូប | |
| ស្ទួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ៦៧៤ | ១៦៨ | ៩៦ | ០ | ៣ | ៩៤១ (៥៥%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស | ១៨១ | ១៨៩ | ២២៣ | ៣ | ២ | ៥៩៨(៣៤%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៩៨ | ០ | ២ | ១ | ០ | ១០១(៦%) |
| ការចូលរួមក្នុងវេទិកា/សិក្ខាសាលាសាធារណៈ | ៨ | ២០ | ១៣ | ២ | ៣ | ៤៦(៣%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១៣ | ២០ | ២ | ០ | ០ | ៣៥(២%) |
| **សរុបជាភាគរយតាមគណបក្ស** | ៩៧៤ (៥៧%) | ៣៩៧ (២៣%) | ៣៣៦ (២០%) | ៦ (០%) | ៨ (០%) | ១ ៧២១ (១០០%) |

អ្នកតំណាងរាស្ត្របានចុះមូលដ្ឋានគ្រប់គោលបំណងទាំងអស់។ ក្នុងចំណោមតំណាងរាស្ត្រទាំង៥គណបក្ស មានតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា និងសមរង្ស៊ីដែលបានចុះមូលដ្ឋានក្នុងគោលបំណងទាំង៥។

គោលបំណងស្ទួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា មាន៥៥% (៩៤១លើក) នៃគោលបំណងសរុប និងគោលំណងដើម្បីពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សរបស់ខ្លួនមាន៣៤% (៥៩៨លើក)។

ការចុះមូលដ្ឋានក្នុងគោលបំណងអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមាន៦% (ឬ១០១លើក)។

ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកាសាធារណៈ សិក្ខាសាលាដែលរៀបចំដោយភាគីផ្សេងដូចជា NGO មាន៣% (៤៥លើក) និងក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋមាន២% (ស្មើនឹង ៣៥ លើក)។

- **ការចុះមូលដ្ឋានក្នុងគោលបំណងស្ទួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាសរុប៩៤២លើក (៥៥%)៖** អ្នកតំណាងរាស្ត្រមកពីស្ទើរគ្រប់គណបក្សទាំងអស់ (លើកលែងតែគណបក្សហ៊្វុនស៊ិនប៉ិច) សុទ្ធតែបានចុះមូលដ្ឋានក្នុងគោលបំណងនេះ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានក្នុងបំណងនេះច្រើនជាងគេ ដែលមាន

រហូតដល់៦៧៤លើក ខណៈដែលតំណាងរាស្ត្រគណបក្ស សមរង្ស៊ីមានចំនួន១៦៨លើក និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៩៦លើក។ គណបក្សជាតិនិយមចំនួន៣លើកនិងគណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន១លើក។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ភាគច្រើនផ្តោតទៅលើការសួរសុខទុក្ខ សំណេះសំណាលពីបញ្ហាផ្សេងៗដែលកើតមានក្នុងមណ្ឌល និងចែកអំណោយផ្សេងៗ។ ព្រមជាមួយគ្នានេះ ក៏ដើម្បីពិនិត្យមើលការបង្កបង្កើនផលរបស់ប្រជាពលរដ្ឋ ស្ថានភាពលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងដើម្បីសម្ពោធសមិទ្ធផលដែលបានសាងសង់រួចផងដែរ។

| អ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងគោលបំណង សួរសុខទុក្ខ ចែកអំណោយ...ច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន |
|---|
| - គណបក្សប្រជាជនកម្ពុជា៖ អ្នកតំណាងរាស្ត្រ ឡោក ខេង មណ្ឌលភ្នំពេញបានចុះមូលដ្ឋាន ក្នុងគោលបំណងនេះច្រើនជាងតំណាងរាស្ត្រដទៃក្នុងគណបក្សរបស់ខ្លួន។ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ឡោក ខេង មានចំនួន៥៤លើក។ ដូចជាកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្ររូបនេះបានផ្តល់ម្សៅឱ្យសិស្ស១០០៦នាក់ នៅសាលាភូមិ៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ និងបានចុះទៅសហគមន៍ជនក្រីក្រ គោករកាចែកម្សៅឱ្យប្រជាពលរដ្ឋផ្ទុកមេរោគអេដស៍ និងកុមារខ្វះជីវជាតិដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន។ ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្រ ឡោក ខេង បានចុះមូលដ្ឋានសរុបចំនួន៧០លើក។ |
| - គណបក្សសមរង្ស៊ី៖ អ្នកតំណាងរាស្ត្រ មូរ សុខហួរ មណ្ឌលកំពត គឺជាអ្នកនាំមុខគេ ក្នុងគណបក្សរបស់ខ្លួន ក្នុងការចុះមូលដ្ឋានដើម្បីសាកសួរសុខទុក្ខប្រជាពលរដ្ឋ ដែលសរុបមានចំនួន៤២លើក។ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ អ្នកតំណាងរាស្ត្ររូបនេះ បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំល្បើក ស្រុកឈូក ខេត្តកំពតដើម្បី ចុះផ្សព្វផ្សាយសិទ្ធិរបស់ស្ត្រីនៅក្នុងឆាកនយោបាយ។ ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្រ មូរ សុខហួរ បានចុះមូលដ្ឋានសរុបចំនួន៧៩លើក។ |
| - គណបក្ស សិទ្ធិមនុស្ស៖ អ្នកតំណាងរាស្ត្រ កឹម សុខា មណ្ឌលកំពង់ចាម មកពីគណបក្ស សិទ្ធិមនុស្ស បាននាំមុខអ្នកតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួនពីររូបទៀត ដោយចុះមូលដ្ឋាន ក្នុងគោលបំណងនេះសរុបបាន ៧៧លើក។ កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្ររូបនេះបានចុះមូលដ្ឋាននៅឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង ដើម្បីប្រជុំសំណេះសំណាល និងសួរសុខទុក្ខជាមួយប្រជាពលរដ្ឋមានអ្នកចូលរួមប្រហែល៣៦០នាក់។ ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្រ កឹម សុខា បានចុះមូលដ្ឋានសរុបចំនួន ១៨១ លើកនាំមុខគ្រប់តំណាងរាស្ត្រទាំងអស់។ |
| - គណបក្សជាតិនិយម៖ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០ កន្លងទៅនេះ អ្នកតំណាងរាស្ត្រ សៅ រ៉ានី មកពីគណបក្សជាតិនិយមមណ្ឌលព្រៃវែង បានអញ្ជើញចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំនៅឃុំទួលពង្រ ស្រុកម៉ាខ្សែហើយបានចែកអំណោយដល់អ្នកចូលរួមក្នុងម្នាក់សារុង១ ថវិកា១០០០០៛ ព្រមទាំងឧបត្ថម្ភថវិកា១០ម៉ឺនរៀលដល់រដ្ឋបាលនៅឃុំទួលពង្រ។ |

- **ការចុះមូលដ្ឋានដើម្បីពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្សមានចំនួន ៥៩៨ លើក(៣៤%)៖** ការចុះមូលដ្ឋានដើម្បីពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សនៅលំដាប់ទី២ បន្ទាប់ពីការចុះសួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋ។ តំណាងរាស្ត្រមកពីគ្រប់គណបក្សនយោបាយទាំងអស់ សុទ្ធតែបានចុះមូលដ្ឋានក្នុងគោលបំណងនេះ។ គណបក្សសិទ្ធិមនុស្សបានធ្វើសកម្មភាពនេះច្រើនជាងគេរហូតដល់២២៣លើក បន្ទាប់មកគណបក្សសមរង្ស៊ី១៨៩ លើក គណបក្សប្រជាជនកម្ពុជា១៨១ លើកគណបក្សជាតិនិយម៣ លើកនិងគណបក្សហ្វ៊ុនស៊ិនប៉ិចបានចំនួន២លើក។

| អ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងគោលបំណង ពង្រឹងបណ្តាញគណបក្សច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន |
|---|
| - គណបក្សប្រជាជនកម្ពុជា៖ អ្នកតំណាងរាស្ត្រ គ្រួច សំអាន មណ្ឌលភ្នំពេញ បាននាំមុខតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួន ដើម្បីចុះមូលដ្ឋានពង្រឹងបណ្តាញគណបក្សរបស់ខ្លួនដែលបានចុះចំនួន១៤លើក។ ដូចជានៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រនេះ បានអញ្ជើញចូលរួម សិក្ខាសាលាស្តីពីបញ្ហាទីផ្សារសង្គម ឧបត្ថម្ភដោយអង្គការខុនរ៉ាដ ដែលប្រព្រឹត្តទៅនៅគណបក្សប្រជាជនកម្ពុជាខណ្ឌចំការមន។ |
| - គណបក្សសម រង្ស៊ី៖ អ្នកតំណាងរាស្ត្រ ជីវ កត្តា មណ្ឌលភ្នំពេញបាននាំមុខតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួន ដើម្បីចុះមូលដ្ឋានពង្រឹងបណ្តាញគណបក្សរបស់ខ្លួនដែលបានចុះចំនួន ២២លើក។ ដូចជានៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្ររូបនេះ បានអញ្ជើញចូលរួម ជួបសំណេះសំណាលជាមួយជំទប់ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុករបស់គណបក្ស នៅភូមិស្តីលើ ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង វត្តមានសរុបចំនួន១៤នាក់ បានឧបត្ថម្ភថវិកាម្នាក់៥០០០រ។ |
| - គណបក្សសិទ្ធិមនុស្ស៖ អ្នកតំណាងរាស្ត្រ កឹម សុខា មណ្ឌលកំពង់ចាម បាននាំមុខតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួន ដើម្បីចុះមូលដ្ឋានពង្រឹងបណ្តាញគណបក្សរបស់ខ្លួនដែលបានចុះចំនួន ១០៣លើក។ ដូចជានៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រនេះ បានអញ្ជើញចូលរួមវេទិកាដែលរៀបចំដោយគណបក្សខ្លួនឯង ជួបប្រជុំសំណេះសំណាលជាមួយក្រុមការងារ សកម្មជន និងប្រជាពលរដ្ឋដែលគាំទ្រគណបក្ស នៅឃុំដារ ឃុំពោធិ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ |
| - គណបក្សជាតិនិយម៖អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែង បាននាំមុខតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួន ដើម្បីចុះមូលដ្ឋានពង្រឹងបណ្តាញគណបក្សរបស់ខ្លួនដែលបានចុះចំនួន២លើក។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រនេះបានអញ្ជើញចូលរួម ប្រជុំជាមួយមេគណបក្សទាំង២ (គណបក្សហ្វុនស៊ិនប៉ិចនិងគណបក្សជាតិនិយម) គោលបំណងការបញ្ចុះបញ្ចូលសម្ព័ន្ធភាពរវាងគណបក្សទាំង២ ដែលក្នុងនោះមានភ្ញៀវចូលរួមប្រហែល៣៧០នាក់ផងដែរ។ |
| - គណបក្សហ៊្វុនស៊ិនប៉ិច៖ អ្នកតំណាងរាស្ត្រគណបក្សនេះបានចុះមូលដ្ឋានក្នុងគោលបំណងនេះចំនួន ៣លើកដោយអ្នកតំណាងរាស្ត្រញឹក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៩ បានចូលរួមសួរសុខទុក្ខអ្នកគាំទ្រនៅការិយាល័យគណបក្សហ៊្វុនស៊ិនប៉ិចខេត្តបន្ទាយមានជ័យ ដោយមានអ្នកចូលរួមចំនួន២៩៣នាក់ ផ្តល់ថវិកា២ម៉ឺនរៀល ក្រណាត់១ដុំ សារ៉ុង១ មៀ្សស៊ុប១គីឡូក្រាម អំបិល១០គីឡូក្រាម ថ្នាំប៉ារ៉ា១ដប ថ្នាំវីតាមីន១ដបក្នុងមួយនាក់ៗ។ |

- ការចុះមូលដ្ឋានដើម្បីអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំមានចំនួនសរុបទាំងអស់១០១ លើក (៦)៖ការចុះមូលដ្ឋានដើម្បីអមដំណើរ ថ្នាក់ដឹកនាំរបស់ខ្លួនដោយតំណាងរាស្ត្រ ភាគច្រើនលើសលុបគឺធ្វើឡើងដោយតំណាងរាស្ត្រមកពីគណបក្ស ប្រជាជនកម្ពុជា ដែលមានរហូតដល់ ៩៨ លើក ដូចជាអមដំណើរថ្នាក់ដឹកនាំនៅក្នុងគណបក្ស ប្រធានរដ្ឋសភា និងក្នុងរាជរដ្ឋាភិបាលដូចជា នាយករដ្ឋមន្ត្រី ជាដើម។ ចំណែកតំណាងរាស្ត្រមកពីគណបក្ស សិទ្ធិមនុស្ស បានចុះមូលដ្ឋានដើម្បីអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនចំនួន២លើក និងគណបក្សហ៊្វុនស៊ិនប៉ិចចំនួន១លើក។ ខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីក្នុងគោលបំណងនេះទេ។

| អ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងគោលបំណង ពង្រឹងបណ្តាញគណបក្សច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន |
|---|
| - គណបក្សប្រជាជនកម្ពុជា៖ អ្នកតំណាងរាស្ត្រ លី គឹមលៀង មណ្ឌលបាត់ដំបង បាននាំមុខតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួន ដើម្បីអមថ្នាក់ដឹកនាំរបស់ខ្លួនដែល បានចុះចំនួន ៩លើក។ ដូចជានៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្ររូប |

នេះ បានអញ្ជើញចូលរួម អមដំណើរឯកឧត្តម ស ខេង អញ្ជើញជាអធិបតីក្នុងពិធីប្រគេនទៀនព្រះវស្សា ទេយ្យវត្ថុជូនចំនួន ១៤វត្តក្នុងឃុំតាគ្រាម ស្រុកបាណន់នៅវត្តចាន់តាគ្រាម និងពិធីប្រគល់ទទួលផ្លូវចាក់ក្រាលកៅស៊ូលេខ១៥៧០ដែលជាអំណោយដ៏ថ្លៃថ្លាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ។

- គណបក្សសិទ្ធិមនុស្ស៖ ថ្ងៃ០៥ ខែតុលា ឆ្នាំ២០០៩ អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មណ្ឌលព្រៃវែងរបស់គណបក្សសិទ្ធិមនុស្សបានចុះអមដំណើរអ្នកតំណាងរាស្ត្រ កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្សចូលរួមជាអធិបតីក្នុងពិធីប្រជុំមួយនៅភូមិបឹងឡៃង ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ក្នុងគោលបំណងសំណេះសំណាល ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋ ប្រហែល២០០នាក់។

- គណបក្សហ្វ៊ុនស៊ិនប៉ិច៖ អ្នកតំណាងរាស្ត្រគណបក្សនេះ បានចុះមូលដ្ឋានក្នុងគោលបំណងនេះចំនួន ១លើកដោយអ្នកតំណាងរាស្ត្រញឹក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យកាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ បានបានអញ្ជើញអមសម្តេចតេជោ ហ៊ុន សែន ជាអធិបតីភាពក្នុងពិធីបើកសម្ពោធការដ្ឋានសាងសង់ផ្លូវជាតិលេខ៦២ ប្រវែង១២៨គីឡូម៉ែត្រ ចាប់ពីផ្លូវបំបែកភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ក្នុងនោះអ្នកចូលរួមមានសមាជិកសភា ព្រឹទ្ធសភា គណៈប្រតិភូជាច្រើនរូប មានថ្នាក់ដឹកនាំខេត្ត ស្រុក មន្ត្រីរាជការ មន្ទីរ ស្ថាប័ន គ្រូបង្រៀន សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើននាក់។

**៤. ការចុះមូលដ្ឋានដើម្បីចូលរួមវេទិកា/សិក្ខាសាលាសាធារណៈមានចំនួន ៤៦លើក (៣%)៖** នៅក្នុងឆ្នាំសង្កេតនេះ តាមព័ត៌មានដែលខុមហ្វ្រែលបានទទួលបង្ហាញថា ចំនួនលើកដែលអ្នកតំណាងរាស្ត្របានចុះមូលដ្ឋានដើម្បីចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈ ដែលរៀបចំដោយNGO និងភាគីផ្សេងទៀត គឺមានតិចតួចបំផុតបើប្រៀបធៀបទៅនឹងការចុះមូលដ្ឋាន ក្នុងគោលបំណង៣ខាងលើ។ ទោះបីយ៉ាងណាតំណាងរាស្ត្រគ្រប់គណបក្សទាំងអស់សុទ្ធតែបានចូលរួមនៅក្នុងវេទិកា និងសិក្ខាសាលា។ ក្នុងឆ្នាំសង្កេតនេះ ចំនួនលើកដែលតំណាងរាស្ត្រមកពីគណបក្សទាំង៥ ចូលរួមវេទិកាសាធារណៈ និងសិក្ខាសាលាសរុប គឺ៤៦លើក (ស្មើនឹង៣% នៃការចុះមូលដ្ឋានសរុប) ក្នុងនោះ គណបក្សជំទាស់គឺ គណបក្សសមរង្ស៊ីបាននាំមុខគេ គឺសរុបបាន២០លើក គណបក្សសិទ្ធិមនុស្សចំនួន១៣ គណបក្សប្រជាជនកម្ពុជាចំនួន៨លើក គណបក្សជាតិនិយម៣លើក គណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន២លើក ។

**អ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងគោលបំណង ពង្រឹងបណ្តាញគណបក្សច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន**

- គណបក្សប្រជាជន៖ អ្នកតំណាងរាស្ត្រមណ្ឌល កំពង់ឆ្នាំង កែ ច័ន្ទមុនី នាំមុខអ្នកតំណាងរាស្ត្រក្នុងគណបក្សរបស់ខ្លួនក្នុងការចូលរួមវេទិកាបាន២ដងដោយធ្វើជាវាគ្មិននៅវេទិកាប្រជាពលរដ្ឋ និងម្ចាស់ឆ្នោតរបស់អង្គការ អ៊ិន ឌី អាយ នៅភូមិច្រកត្នោត ឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០។

- គណបក្សសមរង្ស៊ី៖ មានអ្នកតំណាងរាស្ត្រពីររូប ដែលនាំមុខអ្នកតំណាងរាស្ត្រដទៃទៀតក្នុងគណបក្សសមរង្ស៊ី។ អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺនុត រំដួល និងអ្នកតំណាងរាស្ត្រមណ្ឌលកំពត មូរ សុខហួរ បានចូលរួមជាវាគ្មិនក្នុងវេទិកា៣ដងដូចគ្នា។ ដូចជាកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ នុត រំដួលបានចូលរួមធ្វើជាវាគ្មិននៅក្នុងសិក្ខាសាលាស្តីពីបញ្ហាសុខភាពប្រជាពលរដ្ឋ ទំនាស់ដីធ្លីប្រជាពលរដ្ឋរបស់អង្គការ អ៊ិន ឌី អាយ នៅឃុំកក្តិ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ អ្នកតំណាងរាស្ត្រ មូរ សុខហួរ មណ្ឌលកំពតគណបក្សសមរង្ស៊ី បានចូលរួមវេទិកាសាធារណៈដែលរៀបចំដោយអង្គការអ៊ិនឌីអាយ ប្រធានបទ ស្តីពីតំណាងរាស្ត្រ និងម្ចាស់ឆ្នោតដែលមានប្រជាពលរដ្ឋចូលរួម៩២១នាក់នៅឃុំស្រែជាខាងជើងស្រុកជង

| |
|---|
| ទង់ខេត្តកំពត កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។ |
| - គណបក្សសិទ្ធិមនុស្ស៖ ភាគច្រើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដើម្បីចូលរួមវេទិកាសាធារណៈភាគច្រើនធ្វើឡើងដោយអ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង យ៉ែម បុញ្ញឫទ្ធិ ដែលបានចូលរួមសរុបចំនួន១០លើក ដូចជាចូលរួមវេទិកាសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅស្រុកស្នួល ខេត្តក្រចេះកាលពីថ្ងៃទី ១៩ខែ សីហា ឆ្នាំ២០១០។ |
| - គណបក្សហ្វ៊ុនស៊ិនប៉ិច៖ អ្នកតំណាងរាស្ត្រគណបក្សនេះ បានចុះមូលដ្ឋានក្នុងគោលបំណងនេះចំនួនមួយ២លើក ដោយអ្នកតំណាងរាស្ត្រញឹក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យ១លើក និងអ្នកតំណាងរាស្ត្រ គុជ ម៉ូលី មណ្ឌលកំពង់ធំ១លើក។ អ្នកតំណាងរាស្ត្រ គុជ ម៉ូលី បានអញ្ជើញចូលរួមជាវាគ្មិនវេទិកាសាធារណៈសិទ្ធិមនុស្ស ទាក់ទងអាជ្ញាធរអប្សរា និងប្រជាពលរដ្ឋនៅវត្តអន្លង់ក្រមោល ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាបដែលរៀបចំដោយអង្គការ អិន ឌី អាយ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០។ |
| - គណបក្សជាតិនិយម៖ អ្នកតំណាងរាស្ត្រ សៅ រ៉ានី បានចុះមូលដ្ឋានក្នុងគោលបំណងនេះចំនួន៣លើក ដូចជាទៅភូមិថ្នល់បទឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដើម្បីចូលរួមវេទិកាសាធារណៈ ស្តីពីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ដោយមានការចូលរួមពីប្រជាពលរដ្ឋប្រហែល៥០០នាក់កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ។ |

**៥. ការចុះមូលដ្ឋានដើម្បីអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមានចំនួន ៣៥លើក (២%)៖** ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមានចំនួនតិចជាងគេគឺ២% (ស្មើនឹង៣៥លើក) នៃការចុះមូលដ្ឋានសរុបរបស់តំណាងរាស្ត្រ។ មានតំណាងរាស្ត្រមកពី៣គណបក្ស ដែលបានចុះមូលដ្ឋានដើម្បីអន្តរាគមន៍ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបាននាំមុខដោយចុះបានចំនួន២០លើក និងបន្ទាប់មកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន១៣លើក និងគណបក្សសិទ្ធិមនុស្សចំនួន២លើក។

ខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនិងការចុះអន្តរាគមន៍របស់តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច និងជាតិនិយមនោះទេ។

| អ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងគោលបំណង ពង្រឹងបណ្តាញគណបក្សច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន |
|---|
| -គណបក្សប្រជាជនកម្ពុជា៖ អ្នកតំណាងរាស្ត្រ សួស កាណាន មណ្ឌលព្រះសីហនុ បាននាំមុខអ្នកតំណាងរាស្ត្រដទៃក្នុងគណបក្សរបស់ខ្លួនក្នុងការចុះជួយអន្តរាគមន៍ ឬដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋដោយចុះបានសរុបចំនួ៥លើក ក្នុងគោលបំណងនេះ។ ដូចជាការចុះជួបប្រជាពលរដ្ឋ និងបន្ទាប់មកធ្វើអន្តរាគមន៍តាមរយៈលិខិតលេខ០២៥/១០កតរខសន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ជូនទៅឯកឧត្តមអភិបាលខេត្តព្រះសីហនុ ដើម្បីជួយដោះស្រាយបញ្ហាពាក្យបណ្តឹងប្រជាពលរដ្ឋចំនួន៩២គ្រួសារ ដែលមានទំនាស់ដីធ្លីនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ជាមួយលោក ស ស៊ឹង យោធាសឹករងខេត្តព្រះសីហនុ និងក្រុមហ៊ុនចំរើនជាតិ ដែលកើតមានចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ននេះនៅមិនទាន់បានដោះស្រាយបានជោគជ័យនៅឡើយទេ។ |
| -គណបក្សសមរង្ស៊ី៖ តំណាងរាស្ត្រហូរ វ៉ាន់មណ្ឌលភ្នំពេញ បាននាំមុខតំណាងរាស្ត្រក្នុងគណបក្សខ្លួនដោយបានចុះចំនួន៧លើក ដូចជាកាលពីថ្ងៃទី២៧ខែសីហាឆ្នាំ២០១០ បានចុះអន្តរាគមន៍ជូនប្រជាពលរដ្ឋ ភូមិ៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលត្រូវក្រុមហ៊ុនបិទផ្លូវមិនឱ្យពួកគាត់ធ្វើដំណើរឆ្លងកាត់ តែក្រោយមកក្រុមហ៊ុនបានយល់ព្រមរក្សាផ្លូវ |

**នោះវិញ។**

**-គណបក្សសិទ្ធិមនុស្ស៖ ខុមហ្វ្រែលបានទទួលព័ត៌មានតែអ្នកតំណាងរាស្ត្រ អូរ ច័ន្ទឫទ្ធិ មណ្ឌលកណ្តាលមួយគត់ ក្នុងគណបក្សសិទ្ធិមនុស្សដែលបានចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋចំនួន២លើក ដូចជាចុះអន្តរាគមន៍ការដាក់កុងត្រូលយកលុយនៅស្រុកស្អាង ខេត្តកណ្តាលនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០។**

*<u>តួលេខ៣១៖កំណើនជាភាគរយចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងធៀបនឹងឆ្នាំ២០០៨-២០០៩</u>*




បើធ្វើការប្រៀបធៀបនឹងឆ្នាំសង្កេតមុន (២០០៨-២០០៩) បង្ហាញថា ក្នុងឆ្នាំសង្កេតនេះ ជារួមអ្នកតំណាងរាស្ត្របានបង្កើនការចុះមូលដ្ឋានគ្រប់គោលបំណង។ ក្នុងនោះការសួរសុខទុក្ខមានកំណើន៤៩%ធៀបនឹងឆ្នាំសង្កេតមុន (២០០៨-២០០៩) អមដំណើរកើន២២% និងការចូលរួមវេទិកាមាន២១%។ ការចុះមូលដ្ឋានក្នុងការពង្រឹងបក្សមានកំណើន១៣៩% (ឬច្រើនជាង២ដង)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ ថ្វីត្បិតមានតិចជាងគេ ក៏ប៉ុន្តែបើធៀបនឹងឆ្នាំមុនគឺមានកំណើនដល់១៥០% (ឬច្រើនជាង២,៥ដង)។

*<u>តារាងទី៤៖ រាយនាមអ្នកតំណាងរាស្ត្រសកម្មជាងគេ១០រូបដែលបានចុះមូលដ្ឋានច្រើនជាងគេ (រៀបតាមលំដាប់ពីច្រើនទៅតិចចាប់ពីថ្ងៃទី០១តុលា២០០៩ដល់ថ្ងៃទី៣០កញ្ញា២០១០)</u>*

សម្គាល់៖ ឯ.ឧ. =ឯកឧត្តម, ល.ជ.=លោកជំទាវ

| លរ | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងគណបក្ស | វេទិកា | អមដំណើរ | |
| ១ | ឯ.ឧ គឹម សុខា | | ០ | ៧៧ | ១០៤ | ១ | ០ | **១៨២** |
| ២ | ឯ.ឧ យ៉ែម បុញ្ញឫទ្ធិ | | ០ | ៧ | ៩៦ | ១០ | ២ | **១១៥** |
| ៣ | ល.ជ មូរ សុខហួរ | | ២ | ៤២ | ៤៤ | ៣ | ០ | **៧៩** |

| លរ | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងគណបក្ស | វេទិកា | អមដំណើរ | |
| ៤ | ល.ជ ឡោក ខេង | | ០ | ៥៤ | ១៣ | ០ | ៣ | **៧០** |
| ៥ | ឯ.ឧ កាទើ តូយ៉េប | | ២ | ៤៩ | ៥ | ០ | ២ | **៥៨** |
| ៦ | ឯ.ឧ ទេស ហ៊ាញ | | ០ | ៣៨ | ២ | ០ | ៨ | **៤៨** |
| ៧ | ល.ជ លី គឹមលៀង | | ០ | ៣៨ | ១ | ០ | ៩ | **៤៨** |
| ៨ | ល.ជ ជួញ សុផៃ | | ០ | ៣៧ | ២ | ១ | ៧ | **៤៧** |
| ៩ | ល.ជ ត្រឹង ថាវី | | ៣ | ៣២ | ៧ | ០ | ៤ | **៤៦** |
| ១០ | ឯ.ឧ យន្ត ថារូ | | ២ | ២០ | ១៩ | ១ | ០ | **៤២** |

តំណាងរាស្ត្រដែលចុះមូលដ្ឋានបានច្រើនជាងគេ១០រូប គឺភាគច្រើនធ្វើឡើងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ទោះបីយ៉ាងណា តំណាងរាស្ត្រដែលនាំមុខគេ៣នាក់គឺមកពីគណបក្សសិទ្ធិមនុស្ស និងសមរង្ស៊ី។

គណបក្សសិទ្ធិមនុស្សដែលមានតំណាងរាស្ត្រសរុប៣រូប មាន២រូបគឺបានចុះមូលដ្ឋានច្រើនជាងតំណាងរាស្ត្រមកពីគណបក្សដទៃទៀតគឺអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម កឹម សុខា ចុះមូលដ្ឋានសរុបបាន១៨២លើក និងអ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញាឫទ្ធិ ចុះមូលដ្ឋានសរុបបាន១១៥លើក។ អ្នកតំណាងរាស្ត្រទាំងពីរផ្តោតខ្លាំងដើម្បីចុះទៅពង្រឹងបក្ស។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ មណ្ឌលកំពតរបស់គណបក្សសមរង្ស៊ីឈរលំដាប់ទី៣ ចុះបាន៧៩លើក។ (សូមមើលលម្អិតឈ្មោះអ្នកតំណាងរាស្ត្រទាំងអស់ដែលបានចុះទៅកាន់មូលដ្ឋានទៅគ្រប់មណ្ឌលរាជធានី-ខេត្តក្នុងឧបសម្ព័ន្ធទី៣)។

## ២.៣. គោលបំណងចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមគណបក្សនយោបាយនីមួយៗ

នៅក្នុងផ្នែកនេះ និងបង្ហាញទិន្នន័យ និងវិភាគទៅលើការចុះមូលដ្ឋានតាមគណបក្សនីមួយៗ ដោយផ្តោតថា តើគណបក្សនីមួយៗពេលចុះមូលដ្ឋានក្នុងគោលបំណងអ្វីច្រើនជាងគេ ធៀបនឹងការចុះមូលដ្ឋានសរុបរបស់គណបក្សនោះ។

*តួលេខ ៣២៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតាមគោលបំណងនីមួយៗ*




និន្នាការនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ក្នុងឆ្នាំសង្កេតនេះគឺប្រហាក់ប្រហែល ដូចនឹងឆ្នាំសង្កេតមុនដែរ។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានផ្តោតខ្លាំង ការចុះមូលដ្ឋានក្នុងគោលបំណង សួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា ដែលមាន ៦៩% (៦៧៤៤ លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ៩៧៤។ ចំនួនចុះមូលដ្ឋាន ក្នុងគោលបំណងនេះរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានការកើនឡើងប្រមាណ១៧%ធៀបនឹងឆ្នាំសង្កេត២០០៨-២០០៩ ដែលមាន៥៧៨លើក។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងគណបក្សមាន ១៩% (ឬ១៨១លើក គឺមានការកើនឡើងប្រមាណ២៤%ធៀបនឹងឆ្នាំមុនមាន១៤៦លើក)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងអន្តរាគមន៍រួមគ្នាមាន២% (២១លើក) ដូចឆ្នាំមុនដែរ ដែលការចុះមូលដ្ឋានក្នុងគោលបំណងនេះរួមគ្នាមាន២១លើកដែរ។

*តួលេខ ៣៣៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ីតាមគោលបំណងនីមួយៗ*




ការចុះមូលដ្ឋាន របស់គណបក្សសមរង្ស៊ីក្នុងឆ្នាំសង្កេតនេះគឺផ្តោតក្នុងការពង្រឹងបណ្តាញគណបក្ស និងសួរសុខទុក្ខដូចឆ្នាំសង្កេតមុនដែរ។

ការចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងបណ្តាញ គណបក្សនយោបាយរបស់ខ្លួន មាន៤២% (១៦៨លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ ទាំង ៣៩៧លើក។

ចំនួននេះមានការកើនឡើងប្រមាណ១៣៣% ធៀបនឹងឆ្នាំសង្កេតមុន (២០០៨-២០០៩ មាន៨១លើក)។

ការចុះមូលដ្ឋានក្នុងគោលបំណងសួរសុខទុក្ខ ចែកអំណោយមាន៤២% (ឬ១៦៨លើក កើនជាងឆ្នាំមុន២៥០% ឬជាង២ដង ដែលឆ្នាំមុនមាន៤៨លើក)។ ការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ និងចូលរួមវេទិកាមាន៥% (២០លើក) ដូចគ្នា គឺចំនួនកើនឡើងប្រមាណ៤ដង (ឆ្នាំមុនមាន៤ដងដូចគ្នា)។

ខុមហ្វ្រែលមិនបានទទួលព័ត៌មានការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ក្នុងគោលំណងអមថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

*តួលេខ ៣៤៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សតាមគោលបំណងនីមួយៗ*




ដូចឆ្នាំសង្កេតមុនដែរ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ភាគច្រើនចុះមូលដ្ឋាន ដើម្បីពង្រឹង បណ្តាញគបក្សមាន៦៦% (ឬ២២៣លើក គឺមានកំណើនជាងឆ្នាំមុនប្រមាណ១៥ដង ដែលឆ្នាំមុនមាន១៤លើក)។ ការចុះមូលដ្ឋាន ដើម្បីសួរសុខទុក្ខប្រជាពលរដ្ឋមាន២៨% (ឬ៩៦លើក គឺកើនជាងឆ្នាំមុន ប្រមាណ១៥ដងដែរ ដែលឆ្នាំមុនមាន៦លើក)។

ការចុះមូលដ្ឋាន ក្នុងគោលបំណងចូលរួមវេទិកាមាន៤% (ឬ១៣លើក គឺកើនជាងឆ្នាំមុនប្រមាណ៣ដង ដែលឆ្នាំមុនមាន៣លើក)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ និងអមដំណើរថ្នាក់ដឹកនាំមាន២លើកដូចគ្នា។

*តួលេខ ៣៥៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សជាតិនិយមតាមគោលបំណងនីមួយៗ*




ខុមហ្វ្រែលបានទទួលព័ត៌មាន ពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សជាតិនិយមតែមួយរូបប៉ុណ្ណោះគឺអ្នកតំណាងរាស្ត្រ សៅ រ៉ានីចុះបាន៨លើក ក្នុងនោះការចុះមូលដ្ឋានក្នុងគោលបំណងសួរសុខទុក្ខ ចូលរួមវេទិកាមាន៣លើកដូចគ្នា និងការចុះមូលដ្ឋានក្នុងគោលបំណង ពង្រឹងគណបក្សមាន២លើក។

ក្នុងឆ្នាំសង្កេតមុន អ្នកតំណាងរាស្ត្រគណបក្សនេះចុះមូលដ្ឋានសរុបបាន៧លើក ក្នុងនោះការចុះពង្រឹងបក្សមាន៣លើក ការចូលរួមវេទិកាមាន២លើក ការសួរសុខទុក្ខ និងអមដំណើររួមគ្នាបាន២លើក។

*តួលេខ ៣៦៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចតាមគោលបំណងនីមួយៗ*




តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចមានពីររូបបានចុះមូលដ្ឋានសរុប៦លើក ក្នុងនោះការចុះពង្រឹងផ្ទៃក្នុងគណបក្សមាន៣លើក ការចុះអមដំណើរ១លើក និងការចូលរួមវេទិកាមាន២លើក។ ក្នុងឆ្នាំងសង្កេតមុន (២០០៨-២០០៩) អ្នកតំណាងរាស្ត្រគណបក្សនេះចុះមូលដ្ឋានបាន៩លើក ក្នុងនោះការពង្រឹងបណ្ដាញបក្សមាន៦លើក និងការចូលរួមវេទិកាមាន៣លើក។

## ២.៤. មណ្ឌលរាជធានី-ខេត្តនានាដែលអ្នកតំណាងរាស្ត្របានចុះ

រដ្ឋធម្មនុញ្ញមាត្រា៧៧ កំណត់ថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ ខុមហ្វ្រែលក៏ធ្វើការវិភាគដែរនៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋានថាតើអ្នកតំណាងរាស្ត្រចុះមូលដ្ឋានក្នុងមណ្ឌលរបស់ខ្លួន ឬមណ្ឌលដទៃទៀត។

ទិន្នន័យរបស់ខុមហ្វ្រែលទទួលបានបង្ហាញថា អ្នកតំណាងរាស្ត្រភាគច្រើន គឺចុះមូលដ្ឋានក្នុងមណ្ឌលរបស់ខ្លួន។ ក្នុងឆ្នាំសង្កេតនេះដែលមានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប១៧២១លើក គឺមាន១២៣៤លើក (ឬប្រមាណ៧២%) គឺជាការចុះមូលដ្ឋានក្នុងមណ្ឌល ចំណែកការចុះមូលដ្ឋានក្រៅមណ្ឌលវិញមាន៤៨៧លើក (ប្រមាណ ២៨%)។ ការចុះមូលដ្ឋានក្រៅមណ្ឌលធ្វើឡើងដោយគណបក្សប្រជាជនកម្ពុជាមានចំនួន១០៦លើក គណបក្សសមរង្ស៊ីសរុបមាន១២៦លើក គណបក្សសិទ្ធិមនុស្សសរុបមាន២៤៨លើក គណបក្សជាតិនិយមមាន៣លើក និងគណបក្សហ្វ៊ុនស៊ិនប៉ិចសរុបមាន៤លើក។

*តួលេខ ៣៧៖ ភាគរយចុះមូលដ្ឋានក្នុង និងក្រៅមណ្ឌលធៀបនឹងចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស*




បើធៀបនឹងទៅនឹង ការចុះមូលដ្ឋានក្នុងគណបក្សវិញ ឃើញថា អ្នកតំណាងរាស្ត្រគណបក្សដែលមានអាសនៈច្រើនក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី ភាគច្រើន ផ្ដោតការចុះមូលដ្ឋានក្នុងមណ្ឌលរបស់ខ្លួន ចំណែកគណបក្សដែលមានសម្លេងតិច (ជាប់ឆ្នោតក្នុង

មណ្ឌលតិច) គឺភាគច្រើនចុះមូលដ្ឋានក្រោមមណ្ឌល។

*តួលេខ ៣៨៖ មណ្ឌលរាជធានី-ខេត្តដែលតំណាងរាស្ត្របានចុះ*




ដូចឆ្នាំសង្កេតមុនដែរ បាត់ដំបងដែលមានតំណាងរាស្ត្រក្នុងមណ្ឌលចំនួន៨រូប នៅតែជាមណ្ឌលដែលមានអ្នកតំ ណាងរាស្ត្រចុះច្រើនជាងគេ ដែលសរុបមាន២៧០លើក តែតិចជាងឆ្នាំមុនដែលមាន៣២៣លើក។ មណ្ឌលកំពង់ចាមដែលមានតំណាងរាស្ត្រច្រើនជាងគេរហូតដល់១៨រូប មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានច្រើនលំដាប់ទី២សរុប២២៩លើក។ មណ្ឌលភ្នំពេញលំដាប់ទី៣ មាន២២៦លើក។

ចំណែកមណ្ឌលដែលមានអ្នកតំណាងរាស្ត្រចុះតិចតួច គឺជាមណ្ឌលដែលមានតំណាងរាស្ត្រតិច គឺ១រូប រួមមានកោះកុង១លើក ឧត្តរមានជ័យ១លើក ប៉ៃលិន១លើក ស្ទឹងត្រែង៣លើក ព្រះវិហារ ៨លើក។ ចំណែកមណ្ឌល៣ទៀត ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនោះរួមមាន មណ្ឌលគីរី រតនៈគីរី និងកែប។

## ២.៥.ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី-ខេត្ត

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក៏អាស្រ័យទៅលើការិយាល័យតំណាងរាស្ត្រនៅមណ្ឌលរាជធានី-ខេត្តផងដែរ។ ការិយាល័យតំណាងរាស្ត្រ គឺជាទីកន្លែងធ្វើការរបស់អ្នកតំណាងរាស្ត្រ នៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋាននោះ ហើយក៏ជាស្ពានទំនាក់ទំនងរវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោតនៅក្នុងមណ្ឌលនោះដែរ។ ការិយាល័យតំណាងរាស្ត្រជាទីកន្លែងដែលប្រជាពលរដ្ឋមកជួបតំណាងរាស្ត្រសរសេរ និងដាក់ពាក្យបណ្ដឹងជូនតំណាងរាស្ត្រ ជួយអន្តរាគមន៍បញ្ហាផ្សេងៗ និងជួយសម្រួលដល់តំណាងរាស្ត្រក្នុងការបំពេញភារកិច្ចផ្សេងៗក្នុងមណ្ឌលនោះ។ រហូតមកដល់ពេលនេះមានការិយាល័យតំណាងរាស្ត្រតែក្នុង២៤រាជធានី-ខេត្តប៉ុណ្ណោះ ចំណែក៣ខេត្តទៀត គឺកែបប៉ៃលិន និងឧត្តរមានជ័យ គឺនៅតែមិនទាន់មានការិយាល័យតំណាងរាស្ត្រនោះទេរហូតមកដល់ពេលនេះ។

ជាមួយគ្នានេះដែរ ការសង្កេតទៅលើការិយាល័យតំណាងរាស្ត្របង្ហាញថា ការិយាល័យតំណាងរាស្ត្រមួយចំនួនមិនដំណើរការ ឬបើកដំណើរការមិនទៀងទាត់ បុគ្គលិកបំពេញការងារមិនទៀងទាត់ពេលវេលា ការិយាល័យតំណាងរាស្ត្រខ្លះត្រូវបានលក់ ខ្វះសម្ភារៈបច្ចេកទេសដែលមិនអាចបំពេញភារកិច្ចបម្រើដល់អ្នកតំណាងរាស្ត្រ និងជូនម្ចាស់ឆ្នោត។ ទោះបីយ៉ាងណាក៏មានការសាងសង់អាគារថ្មីចំនួន៤ ដូចជាខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តកោះកុង និងខេត្តស្ទឹងត្រែង ក្នុងចំណោមអាគារចាស់ៗទាំង២០ការិយាល័យ កំឡុងឆ្នាំទី២របស់សភាអាណត្តិទី៤នេះ។

អ្នកតំណាងរាស្ត្រមួយចំនួន មិនថាមកពីគណបក្សកាន់អំណាច ឬជំទាស់នោះទេ ពេលចុះមូលដ្ឋានម្តងៗ គឺច្រើនរំលងដោយមិនបានចូលក្នុងការិយាល័យអ្នកតំណាងរាស្ត្រដើម្បីពិនិត្យការងារទាក់ទង និងលិខិតបណ្តឹងរបស់ប្រជាជនក៏ដូចជាសំណូមពររបស់ប្រជាពលរដ្ឋសុំការជួយអន្តរាគមន៍ពីតំណាងរាស្ត្រទេ ហើយខ្លះក៏មិនបានផ្តល់ដំណឹងពីវត្តមានអំពីការចុះមូលដ្ឋានរបស់គាត់ទៅមន្ត្រីនៅការិយាល័យតំណាងរាស្ត្រដែរ។

នេះអាចផ្តល់នូវគម្លាតរវាងតំណាងរាស្ត្រ និងប្រជាពលរដ្ឋ រួមទាំងធ្វើឲ្យការិយាល័យតំណាងរាស្ត្រនេះកាន់តែអសកម្មភាពទៅៗ។

ជាមួយគ្នានេះ តំណាងរាស្ត្រនៃគណបក្សមួយចំនួន ជាពិសេសគណបក្សប្រឆាំងនៅមិនទាន់មានភាពជឿជាក់ទៅលើឯករាជ្យភាពរបស់បុគ្គលិកបំរើការនៅការិយាល័យតំណាងរាស្ត្រមួយចំនួន។

បណ្តាញខុមហ្វ្រែលនៅតាម២៤រាជធានី-ខេត្ត ជារឿយៗត្រូវទៅការិយាល័យតំណាងរាស្ត្រនៅក្នុងមណ្ឌលដើម្បីប្រមូលព័ត៌មាននានាទាក់ទងនឹងអ្នកតំណាងរាស្ត្រ ដែលក្នុងមួយខែបណ្តាញខុមហ្វ្រែលត្រូវចុះទៅចន្លោះពី២ ទៅ៤ដង ឬច្រើនដងទៅតាមព្រឹត្តិការណ៍ជាក់ស្តែងដើម្បីអាចជួបបុគ្គលិកបំរើការនៅទីនោះ។

ការិយាល័យតំណាងរាស្ត្រក្នុងខេត្តចំនួន៩ ដែលបណ្តាញខុមហ្វ្រែលសង្កេតថា មិនមានបញ្ហាម៉ោង និងថ្ងៃធ្វើការ (មានបុគ្គលិកប្រចាំការនៅថ្ងៃធ្វើការ និងម៉ោងធ្វើការ) រួមមាន៖ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកណ្តាល ខេត្តព្រះវិហារ និងខេត្តព្រះសីហនុ។

ចំណែកខេត្តមួយចំនួន ដែលការិយាល័យតំណាងរាស្ត្រមិនសូវដំណើរការម៉ោងធ្វើការមិនច្បាស់លាស់ និងបុគ្គលិកមកធ្វើការមិនសូវទៀងទាត់មានដូចជា៖

១- ខេត្តពោធិ៍សាត់៖ អាគារបិទទ្វារ ហើយធ្វើការនៅតូបលក់នំខាងមុខការិយាល័យតំណាងរាស្ត្រ។ តំណាងរាស្ត្រ ឯម ប៉ុណ្ណា យកមជ្ឈមណ្ឌលរបស់លោកជំទាវប៊ុនរ៉ានី ហ៊ុនសែន (កាកបាទក្រហម) ជាកន្លែងទំនាក់ទំនងជាមួយប្រជាជន។
២- ខេត្តរតនគីរី៖ ការិយាល័យតំណាងរាស្ត្របានលក់ និងបានទិញដីសំរាប់សង់អាគារនៅកន្លែងផ្សេងវិញហើយឥឡូវយកផ្ទះរបស់មន្ត្រីការិយាល័យជាការិយាល័យបណ្តោះអាសន្ន។
៣- កំពង់ស្ពឺ៖ ការិយាល័យតំណាងរាស្ត្រមិនបើកទ្វារធ្វើការ។
៤- កោះកុង៖ ធ្វើការតែពេលព្រឹកពេលថ្ងៃ ជួនកាលបើក ជួនកាលបិទ។
៥- ព្រៃវែង៖ បុគ្គលិកមិនសូវប្រចាំការទេការិយាល័យ ពេលខ្លះបើក ពេលខ្លះបិទទ្វារ។
៦- សៀមរាប៖ ការិយាល័យពេលខ្លះបើក ពេលខ្លះបិទទ្វារ មានខែខ្លះធ្វើការ មានខែខ្លះមិនធ្វើការ។
៧- ស្ទឹងត្រែង៖ ការិយាល័យធ្វើការតែមួយព្រឹកទេ ពេលថ្ងៃបិទ។
៨- ស្វាយរៀង៖ បុគ្គលិកមានមកប្រចាំការម្តងម្កាលនៅការិយាល័យ។

៩- តាកែវ៖ ធ្វើការតែពេលព្រឹកទេពេលថ្ងៃ ជួនមក ជួនមិនមក។

## ៣. ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ

ខុមហ្វ្រែលអង្កេតសកម្មភាពរបស់អ្នកតំណាងរាស្ត្រ រួមទាំងការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ។ លិខិតដែលខុមហ្វ្រែលអង្កេតនោះ រួមមានលិខិតអន្តរាគមន៍ (ចេញលិខិតដល់ភាគីជម្លោះដើម្បីដោះស្រាយបញ្ហា) លិខិតស្នើ ឬអំពាវនាវឲ្យចាត់វិធានការ (ស្នើឲ្យភាគីមួយទៀតអន្តរាគមន៍) លិខិតដាក់សំណួរដល់រាជរដ្ឋាភិបាល លិខិតស្នើឲ្យរាជរដ្ឋាភិបាលមកបំភ្លឺនៅរដ្ឋសភា លិខិតបញ្ចេញមតិ។ ខុមហ្វ្រែលក៏តាមដានការឆ្លើយតបទៅលើលិខិតតំណាងរាស្ត្រវិញផងដែរ។

តាមព័ត៌មានដែលខុមហ្វ្រែលបានទទួលក្នុងអំឡុងឆ្នាំសង្កេតនេះ មានតំណាងរាស្ត្រសរុបចំនួន១៤ រូប មកពី២គណបក្សដែលមានអាសនៈក្នុងរដ្ឋសភា បានចេញលិខិតសរុបចំនួន៧៤ច្បាប់ ជូនរាជរដ្ឋាភិបាល និងជូនស្ថាប័នពាក់ព័ន្ធនានា។ ចំនួនលិខិតនេះមានការកើនឡើងជាងឆ្នាំសង្កេតមុន២៨% ឬ១៦លិខិត។ ក្នុងចំណោមតំណាងរាស្ត្រទាំង១៤ មាន១៣រូបមកពីគណបក្សសមរង្ស៊ីដោយចេញលិខិតសរុបបាន៧២លិខិត និង១រូបមកពីគណបក្សសិទ្ធិមនុស្សដោយចេញលិខិតបាន២លិខិត។ ខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចេញលិខិតនេះពីតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ហ្វ៊ុនស៊ិនប៉ិច និងជាតិនិយមឡើយ។

*<u>តារាងទី ៥ ៖ ឈ្មោះអ្នកតំណាងរាស្ត្រទាំង ១៤ រូបដែលបានចេញលិខិត និងគោលបំណងនៃលិខិត</u>*

សំគាល់: ឯ.ឧ. = ឯកឧត្តម, ល.ជ. = លោកជំទាវ

| លរ | គោត្តនាមនិងនាម | គណបក្ស | សរុប | គោលបំណងនៃលិខិត | | | | | ការឆ្លើយតប |
|---|---|---|---|---|---|---|---|---|---|
| | | | | អន្តរាគមន៍ | អំពាវនាវ | បញ្ចេញមតិ | ដាក់សំណួរ | បំភ្លឺនៅសភា | |
| ១ | ឯ.ឧ. ម៉ែន សុថាវរិន្ទ្រ | | ២៥ | ៥ | ១៨ | ០ | ០ | ២ | ១០ |
| ២ | ឯ.ឧ. ហូរ វ៉ាន់ | | ១១ | ៣ | ៨ | ០ | ០ | ០ | ៤ |
| ៣ | ឯ.ឧ. សុន ឆ័យ | | ១១ | ០ | ៦ | ០ | ២ | ៣ | ២ |
| ៤ | ឯ.ឧ. យន្ត ថារ៉ូ | | ៥ | ១ | ៤ | ០ | ០ | ០ | ០ |
| ៥ | ល.ជ. មូរ សុខហួរ | | ៤ | ០ | ២ | ០ | ០ | ២ | ១ |
| ៦ | ឯ.ឧ. ជា ប៉ូច | | ៣ | ០ | ៣ | ០ | ០ | ០ | ២ |
| ៧ | ល.ជ កែ សុវណ្ណរ័ត្ន | | ៣ | ១ | ២ | ០ | ០ | ០ | ០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៨ | ឯ.ឧ. ម៉ៅ មុនីវណ្ណ | | ៣ | ០ | ៣ | ០ | ០ | ០ | ០ |
| ៩ | ឯ.ឧ. ចាន់ ចេង | | ២ | ០ | ២ | ០ | ០ | ០ | ០ |
| ១០ | ឯ.ឧ. អ៊ូ ច័នទឫទ្ធិ | | ២ | ០ | ២ | ០ | ០ | ០ | ០ |
| ១១ | ឯ.ឧ. ឡុង រី | | ២ | ០ | ២ | ០ | ០ | ០ | ១ |
| ១២ | ឯ.ឧ. ជាម ច័ន្ទនី | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ១៣ | ល.ជ. លី ស្រីវីណា | | ១ | ០ | ១ | ០ | ០ | ០ | ១ |
| ១៤ | ឯ.ឧ. នុត រំដួល | | ១ | ០ | ១ | ០ | ០ | ០ | ១ |
| សរុប | | | ៧៤ | ១០ | ៥៥ | ០ | ២ | ៧ | ២២ |

ក្នុងឆ្នាំសង្កេតនេះ លិខិតភាគច្រើនដែលតំណាងរាស្ត្របានចេញ គឺក្នុងគោលបំណងស្នើបន្តឲ្យស្ថាប័នរាជរដ្ឋាភិបាលចាត់វិធានការ ឬអន្តរាគមន៍ទៅលើបញ្ហានានាដែលអ្នកតំណាងរាស្ត្របានប្រមូលព័ត៌មាន និងបានទទួលពីម្ចាស់ឆ្នោតដែលលិខិតក្នុងគោលបំណងនេះមានរហូតដល់៥៥លិខិត (ប្រមាណ៧៤% នៃលិខិតសរុប)។

ចំណែកលិខិតរបស់អ្នកតំណាងរាស្ត្រ ក្នុងគោលបំណងអន្តរាគមន៍ដោយផ្ទាល់ (គឺដាក់លិខិតទៅភាគីដែលមានបញ្ហាដោយផ្ទាល់) មាន១០លិខិត។ ហើយការស្នើឲ្យរាជរដ្ឋាភិបាលមកបំភ្លឺផ្ទាល់មាត់នៅរដ្ឋសភាមានចំនួន៧លិខិត និងការដាក់សំណួរដល់រាជរដ្ឋាភិបាលមាន២លិខិត។

មិនមែនរាល់លិខិតដែលអ្នកតំណាងរាស្ត្រចេញទៅ សុទ្ធតែទទួលបានការឆ្លើយតបនោះទេ។ ក្នុងឆ្នាំសង្កេតនេះ ខុមហ្វ្រែលទទួលបានព័ត៌មានថា ក្នុងចំណោមលិខិតទាំង៧៤ គឺមានលិខិតតែ ២២ (គឺប្រមាណ៣០%) ប៉ុណ្ណោះដែលមានការឆ្លើយតបពីរាជរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធ។

អ្នកតំណាងរាស្ត្រដែលបានចេញលិខិតច្រើនជាងគេ៣រូប គឺសុទ្ធតែមកពីគណបក្សសមរង្ស៊ីរួមមានអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ ម៉ែន សុថាវិរិន្ទ្របានចេញលិខិតសរុប ២៥លិខិត ហើយបានទទួលការឆ្លើយតបវិញចំនួន១០លិខិត។ អ្នកតំណាងរាស្ត្រ ហូ វ៉ាន់ មណ្ឌលភ្នំពេញបានចេញ១១លិខិត និងបានទទួលការឆ្លើយតបចំនួន៤លិខិត និងអ្នកតំណាងរាស្ត្រសុន ឆ័យ មណ្ឌលភ្នំពេញបានចេញ១១លិខិតដែរ តែបានការឆ្លើយតបតែ២លិខិតប៉ុណ្ណោះ។

**ការឆ្លើយតបខ្លះៗ ពីស្ថាប័នពាក់ព័ន្ធចំពោះលិខិតនានារបស់អ្នកតំណាងរាស្ត្រ ៖**

- **ការឆ្លើយតបចំពោះអ្នកតំណាងរាស្ត្រ ម៉ែន សុថាវិរិន្ទ្រ៖** ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ អ្នកតំណាងរាស្ត្រ ម៉ែន សុថាវិរិន្ទ្រ មណ្ឌលកំពង់ធំ បានចេញលិខិតជម្រាបជូនសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើសុំសម្តេចធ្វើការទប់ស្កាត់កុំឲ្យឈ្មោះ ហ៊ាង ហួយ ភេទប្រុស ជាប្រធានដែនសហគមន៍នេសាទភូមិប្រគាប ស្ថិតនៅឃុំម្សាក្រង ស្រុកស្ទោង ខេត្តកំពង់ធំ លក់ដែនសហគមន៍នេសាទភូមិប្រគាបទៅឲ្យឈ្មួញផ្តាច់មុខចាប់ពីឆ្នាំ២០០៩នេះតទៅ។ នៅថ្ងៃ២៣ ខែកញ្ញា ឆ្នាំ២០០៩ សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន និងឯកឧត្តម ច័ន្ទ

សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានឆ្លើយតបសំណើរបស់អ្នកតំណាងរាស្ត្រ ម៉ែន សុថាវរិន្ទ្រ ថា ករណីនេះត្រូវបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះស្រាវជ្រាវ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋឱ្យបានទទួលបានការនេសាទជាលក្ខណៈគ្រួសារហើយ។

- **ការឆ្លើយបតចំពោះអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់៖** អ្នកតំណាងរាស្ត្រហូរវ៉ាន់មណ្ឌលភ្នំពេញរបស់គណបក្សសមរង្ស៊ីបានដាក់លិខិតទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ដើម្បីស្នើសុំការអន្តរាគមន៍លើករណីអនុវត្តសាលដីការបស់តុលាការកំពូល ដោយបានរំលោភលើលំនៅដ្ឋានរបស់លោកសេងពៅ និងពីរគ្រួសារទៀតដោយលោកព្រះរាជអាជ្ញារងឯក ឆេងហួត។ លិខិតបានស្នើឲ្យផ្តន្ទាទោសលោកព្រះរាជអាជ្ញារង ដោយឲ្យសងការខូចខាត និងប្រគល់ដីជូនអ្នកទាំងអស់។
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានធ្វើការឆ្លើយបំភ្លឺវិញ តាមរយៈលិខិតចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ដោយបានធ្វើការបំភ្លឺថាសំណង់ផ្ទះទំហំ៧.៦៥មគុណ១០ម ដែលឈ្មោះសេងពៅសាងសង់បន្ថែមប៉ែកខាងកើតជាប់ព្រំរបងវត្ត មានសំណង់ផ្ទះស័ង្កសីចំនួន១ខ្នងនៅខាងត្បូងផ្ទះរបស់ឈ្មោះសេងពៅ និងសំណង់ស័ង្កសីចំនួន១ខ្នងនៅខាងជើងផ្ទះរបស់ឈ្មោះសេងពៅ ហើយសំណង់ទាំងនេះសាងសង់លើប្រឡាយសាធារណៈផងដែរ គឺជាសំណង់ខុសច្បាប់។

## ៤. អ្នកតំណាងរាស្ត្រស្ត្រី

ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្រស្ត្រីមិនមានការថយចុះ ឬកើនឡើងជាងឆ្នាំសង្កេតមុននោះទេ គឺអ្នកតំណាងរាស្ត្រមាន២៦រូប (២១% នៃតំណាងរាស្ត្រសរុប)។

ច្បាប់បោះឆ្នោតដែលផ្តល់អំណាចដល់គណបក្សនយោបាយ ក្នុងការផ្លាស់ប្តូរតំណាងរាស្ត្រ គឺបានន័យថា ចំនួនតំណាងរាស្ត្រស្ត្រីកើន ឬថយតិច ឬច្រើន គឺអាស្រ័យទៅលើគោលនយោបាយ ឬឆន្ទៈរបស់គណបក្សនយោបាយនោះផ្ទាល់ក្នុងការលើកតម្កើងស្ត្រី។

ក្នុងឆ្នាំសង្កេតនេះដែរ ការតតាំងរវាងអ្នកតំណាងរាស្ត្រស្ត្រីមណ្ឌលកំពត មូរ សុខហួរ មកពីគណបក្សសមរង្ស៊ី ជាមួយអ្នកតំណាងរាស្ត្របុរសមណ្ឌលកណ្តាល និងជានាយករដ្ឋមន្ត្រីសម្តេច ហ៊ុន សែន ក្នុងបណ្តឹងបរិហារកេរ្តិ៍ ប្តឹងដោយសម្តេច ហ៊ុន សែន នៅសាលាឧទ្ធរណ៍ និងតុលាការកំពូល គឺបានបញ្ចប់ហើយ ដោយតុលាការកំពូលសម្រេចរក្សាតម្កល់សាលក្រមតុលាការដំបូង ដែលតម្រូវឲ្យអ្នកតំណាងរាស្ត្រ មូរ សុខហួរ បង់ប្រាក់ពិន័យ ១៦,៥លានរៀលដល់សម្តេច ហ៊ុន សែន និងរាជរដ្ឋាភិបាល។

ការសម្រេចបែបនេះ បានទទួលការប្រឆាំងពីអ្នកតំណាងរាស្ត្រ មូរ សុខហួរ ដោយមិនព្រមបង់ប្រាក់ពិន័យ។ ទោះបីយ៉ាងណា នៅខែសីហា ឆ្នាំ២០១០ តុលាការរាជធានីភ្នំពេញបានសម្រេចរឹបអូសប្រាក់ខែសភារបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ។

នៅក្នុងរឿងក្តីនេះ បានធ្វើឲ្យអ្នកតំណាងរាស្ត្រស្ត្រីរូបនេះ ត្រូវបាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួន រហូតដល់ជាង៣ឆ្នាំ ដោយអ្នកតំណាងរាស្ត្ររូបនេះ ត្រូវដកអភ័យឯកសិទ្ធតាំងពីខែសីហា ឆ្នាំ២០០៩ និងអាចបានអភ័យឯកសិទ្ធិវិញនៅចុងឆ្នាំ២០១១។

ករណីបណ្តឹងរបស់សម្តេច ហ៊ុន សែនប្រឆាំងនឹងអ្នកតំណាងរាស្ត្រ មូរ សុខហួរ គឺកើតឡើងក្នុងឆ្នាំ២០០៩ ដោយនៅខែមេសា ឆ្នាំ២០០៩ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញរកឃើញថា អ្នកតំណាងរាស្ត្រ មូរ សុខហួរ មានទោសបរិហារ

កេរ្តិ៍សម្តេច ហ៊ុន សែន ហើយពិន័យជាប្រាក់១៦,៥លានរៀល ដោយសារតែអ្នកតំណាងរាស្ត្ររូបនេះធ្វើសន្និសីទសារព័ត៌មានពីបំណងប្តឹងសម្តេច ហ៊ុន សែន ដែលបាននិយាយពីស្ត្រីជើងខ្លាំងម្នាក់នៅមណ្ឌលកំពតថា បានទៅឱបគេ តែបែរជាថា គេប្រឡេះឡេវអាវខ្លួនវិញ។

អ្នកតំណាងរាស្ត្រ មួរ សុខហួរ យល់ថា គឺសំដៅទៅលើខ្លួន ហើយបានដាក់ពាក្យបណ្តឹងទៅតុលាការ តែមិនត្រូវបានតុលាការចាត់វិធានការនោះទេ។

## ៤.១. ការចូលរួមប្រជុំពេញអង្គរបស់អ្នកតំណាងរាស្ត្រស្ត្រី

នៅក្នុងសម័យប្រជុំក្នុងឆ្នាំសង្កេតនេះ មានស្ត្រីចូលរួមប្រជុំជាមធ្យមប្រមាណ១៩ក្នុង១កិច្ចប្រជុំ ចំណែកអ្នកតំណាងរាស្ត្របុរសជាមធ្យម៧៨រូបក្នុង១កិច្ចប្រជុំ។

បើគិតជាភាគរយ ធៀបនឹងចំនួនតំណាងរាស្ត្រស្ត្រីសរុបក្នុងរដ្ឋសភា គឺអ្នកតំណាងរាស្ត្រស្ត្រីជាមធ្យមប្រមាណ៧៣% (នៃចំនួនអ្នកតំណាងរាស្ត្រស្ត្រីសរុប២៦ រូប) បានចូលរួម១កិច្ចប្រជុំ។ ចំណែកអ្នកតំណាងរាស្ត្របុរសជាមធ្យមមាន ៨០% នៃចំនួនតំណាងរាស្ត្របុរសសរុប។

**- ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រស្ត្រីនៅសម័យប្រជុំពេញអង្គៈ** ក្នុងឆ្នាំងសង្កេតនេះ ចំនួនអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិមានការកើនឡើងជាឆ្នាំងមុន៣ដង។ នៅក្នុងសម័យប្រជុំពេញអង្គទាំង៣៧លើក មានតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិចំនួន១២រូប ឬ៤៦%ធៀបនឹងចំនួនអ្នកតំណាងរាស្ត្រស្ត្រីទាំងអស់នៅក្នុងសភា ខណៈឆ្នាំមុនមានតែ៤រូបប៉ុណ្ណោះ។

កំណើននេះ គឺដោយសារតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានឡើងបញ្ចេញមតិចំនួន៨រូប ដែលឆ្នាំមុនមានតែ១រូប ឡើងបញ្ចេញមតិ ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមាន៤រូប ដែលឆ្នាំមុនមានតែ៣រូបឡើងបញ្ចេញមតិ។

អ្នកតំណាងរាស្ត្រស្ត្រីទាំង១២រូបបានបញ្ចេញមតិសរុប៥៩៧នាទី (៩ម៉ោង ៥៧នាទី)។ ទោះបីយ៉ាងណា មានតែអ្នកតំណាងរាស្ត្រស្ត្រីពីររូបប៉ុណ្ណោះ គឺអ្នកតំណាងរាស្ត្រ មណ្ឌលកំពត មួរ សុខហួរ និងមណ្ឌលភ្នំពេញ លី ស្រីវីណា មកពីគណបក្សសមរង្ស៊ីដែលសរុបបញ្ចេញមតិបានដល់៤១១នាទី។ ចំណែកតំណាងរាស្ត្រ១០រូបផ្សេងទៀត បញ្ចេញមតិរួមគ្នាបានតែ១៨៦នាទីប៉ុណ្ណោះ។

**- ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី៖** ក្នុងឆ្នាំសង្កេតនេះ មានអ្នកតំណាងរាស្ត្រស្ត្រីចំនួន ២២រូបបានចុះមូលដ្ឋាន មានការកើនឡើងប្រមាណ ១៦% ធៀបនឹងឆ្នាំមុនដែលមាន (១៩រូប)។ បើគិតជាភាគរយធៀបនឹងតំណាងរាស្ត្រស្ត្រីសរុប គឺប្រមាណ៨៥% នៃអ្នកតំណាងរាស្ត្រស្ត្រីបានចុះមូលដ្ឋាន ធៀបនឹងតំណាងរាស្ត្របុរសមានប្រមាណ៩០% (៨៧រូបនៃតំណាងរាស្ត្របុរសសរុប៩៧រូប)។

តំណាងរាស្ត្រស្ត្រីទាំង២២រូប ចុះមូលដ្ឋានសរុបបាន៤៥៣លើក។ ក្នុងចំណោមតំណាងរាស្ត្រស្ត្រីទាំង២២រូប អ្នកតំណាងរាស្ត្រស្ត្រីទាំង៦រូប មកពីគណបក្សសមរង្ស៊ីសុទ្ធតែបានចុះមូលដ្ឋានសរុបបាន១២៦លើក ឬម្នាក់ចុះមូលដ្ឋានបាន ២១លើក ចំណែកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមាន១៦រូប (ស្មើនឹង៨០%នៃតំណាងរាស្ត្រស្ត្រីគណបក្សនេះសរុប) បានចុះមូលដ្ឋានសរុប៣២៧លើក ឬ១រូបចុះបានប្រមាណ២០លើក។

អ្នកតំណាងរាស្ត្រស្ត្រីចំនួន៥រូប ក៏ស្ថិតនៅក្នុងចំណោមតំណាងរាស្ត្រដែលចុះមូលដ្ឋានបានច្រើនជាងគេ ក្នុងចំណោម១១រូបផងដែរ ដែលតំណាងរាស្ត្រស្ត្រីទាំង៥រូប មកពីគណបក្សប្រជាជនកម្ពុជា (៤រូប) និងគណបក្សសមរង្ស៊ី(១រូប)។ ក្នុងនោះរួមមាន អ្នកតំណាងរាស្ត្រ មួរ សុខហួរ មណ្ឌលកំពតគណបក្សសមរង្ស៊ី បានចុះមូលដ្ឋានសរុប៧៩លើកស្ថិតនៅលំដាប់ទី៣ អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា៤រូបទៀត គឺអ្នកតំណាងរាស្ត្រឡោក ខេង មណ្ឌលភ្នំពេញ បាន៧០លំដាប់លេខ៤ អ្នកតំណាងរាស្ត្រ លី គឹមលៀងបាន៤៨ លើក ស្ថិតនៅសលំដាប់ទី៧ អ្នកតំណាងរាស្ត្រ ជួញ សុផៃមណ្ឌលបាត់ដំបងបាន៤៧លើកស្ថិតនៅលំដាប់ទី៨ និងអ្នកតំណាងរាស្ត្រ ត្រឹង ថាវី បាន៤៦លើក ស្ថិតនៅលំដាប់ទី៩។

- **ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រស្ត្រី៖** ក្នុងចំណោមតំណាងរាស្ត្រស្ត្រីទាំង២៦រូប មានតំណាងរាស្ត្រស្ត្រីតែ៣រូបប៉ុណ្ណោះមកពីគណបក្សសមរង្ស៊ីដែលចេញលិខិតទៅកាន់ស្ថាប័ននានាដើម្បីស្នើអន្តរាគមន៍ និងឲ្យមកបំភ្លឺនៅវិមានរដ្ឋសភា។ អ្នកតំណាងរាស្ត្រស្ត្រីទាំង៣រូប រួមមានអ្នកតំណាងរាស្ត្រ មួរ សុខហួរ អ្នកតំណាងរាស្ត្រ កែ សុវណ្ណរ័ត្ន និងអ្នកតំណាងរាស្ត្រ លី ស្រីវីណា បានចេញលិខិតសរុប៨លិខិត តែបានទទួលការឆ្លើយតបតែ២លិខិតវិញប៉ុណ្ណោះ។

## ៥. ព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### បន្តការអនុវត្តន៍ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភាដែលមិនស៊ីសង្វាក់តាមច្បាប់ដែលមានស្រាប់

ការសង្កេតសភានីតិកាលទី៣ និងទី៤ ជាពិសេសក្នុង២ឆ្នាំដំបូងនៃនីតិកាលទី៤ នេះបង្ហាញថា ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រ មានភាពខុសគ្នាទៅតាមការសម្រេចរបស់ថ្នាក់ដឹកនាំស្ថាប័ននេះ។ ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រមានចែងនៅក្នុងរដ្ឋធម្មនុញ្ញច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

រដ្ឋធម្មនុញ្ញមាត្រា៨០ បានលើកឡើងពីអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រដោយកំណត់ថា ការចោទប្រកាន់ ការចាប់ខ្លួន...អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា...។

មាត្រានេះក៏បានបន្តទៀតដែរថា ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា (នៅចន្លោះសម័យប្រជុំ) ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។

របៀបនៃការលើកអភ័យឯកសិទ្ធសភាពីអ្នកតំណាងរាស្ត្រ បានលើកឡើងពិស្តារថែមទៀតនៅក្នុងច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ពីមាត្រា៧ ដល់១៦ ជាពិសេសផ្តោតទៅលើបទល្មើសព្រហ្មទណ្ឌ ដែលក្នុងនោះតម្រូវឲ្យមានលិខិតស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ទោះបីយ៉ាងណា ការអនុវត្តន៍ក្នុងនីតិកាលទី៤ នេះមានភាពមិនស៊ីសង្វាក់គ្នាទៅនឹងនីតិវិធី ដែលកំណត់ដោយច្បាប់នេះ ជាពិសេសការអនុវត្តន៍ការលើកអភ័យឯកសិទ្ធិនៅចន្លោះសម័យប្រជុំរដ្ឋសភា។

មាត្រា១០នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្របានលើកឡើងថា ការលើកអភ័យឯកសិទ្ធិសភានៅក្នុងចន្លោះសម័យប្រជុំរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ទោះបីយ៉ាងណាបទបញ្ជាផ្ទៃក្នុងរដ្ឋសភាមិនបានលើកឡើងពីរបៀបទាក់ទងនឹងការអនុម័តនេះទេ។

មាត្រា១១បានបន្តថា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ទោះបីយ៉ាងណា ច្បាប់នេះក៏មិនមានចែងដែរថា តើការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា គឺត្រូវចូលជាធរមាននៅពេលសម្រេចនោះ ឬក៏ត្រូវចូលជាធរមាននៅពេលមានការសម្រេចរបស់សមាជិកសភា ភាគច្រើនពីរភាគបីនៃចំនួនសមាជិកសភាទាំងមូល។

ការសង្កេតឃើញថា ក្នុងនីតិកាលទី៤នេះ រដ្ឋសភាធ្លាប់បានលើកអភ័យឯកសិទ្ធិសភាត្រឹមតែគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប៉ុណ្ណោះ ហើយការសម្រេចនោះមិនបានដាក់ជូនសម័យប្រជុំរដ្ឋសភា ដើម្បីអនុម័តតាមមាត្រា១១នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រឡើយ។

ការអនុវត្តន៍នេះបានធ្វើឡើងចំពោះការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ **សម រង្ស៊ី**។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាបានសំរេចលើកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រសមរង្ស៊ីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងចន្លោះសម័យប្រជុំលើកទី១ និងទី២ ដើម្បីបើកផ្លូវឱ្យតុលាការអាចធ្វើការចោទប្រកាន់ ពីបទជេរប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ក្នុងអំឡុងពេលយុទ្ធនាការឃោសនារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨។

ក្រោយពីការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ការលើកអភ័យឯកសិទ្ធិនេះក៏បានចូលជាធរមាន ហើយតុលាការក៏បានធ្វើការចោទប្រកាន់ភ្លាមៗដែរ ដោយមិនចាំបាច់រង់ចាំការអនុម័តយល់ព្រមពីសមាជិកសភាដូចចែងក្នុងមាត្រា១១នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រនោះទេ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា អ្នកតំណាងរាស្ត្រ**ឈាងវុន** ធ្លាប់ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីការពារការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ថា *"...សភាឈប់សម្រាកហើយគណៈកម្មាធិការអចិន្ត្រៃយ៍មានអំណាចព្យួរអភ័យឯកសិទ្ធរបស់លោកសមរង្ស៊ីដោយគ្មានតម្រូវការសម្លេងឆ្នោតរបស់សភាទាំងមូលតាមរដ្ឋធម្មនុញ្ញឡើយ។"*

ជាងនេះទៅទៀត នៅពេលសម័យប្រជុំរដ្ឋសភាទី២ចាប់ផ្តើម គណៈកម្មាធិការអចិន្ត្រៃយ៍មិនបានដាក់ជូនសម័យប្រជុំរដ្ឋសភាដើម្បីអនុម័តការសម្រេចទៅលើការព្យួរនោះទេ។

ការអនុវត្តន៍បែបនេះបានចោទជាសំណួរថា តើគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមាជិក១២រូប កំពុងតែដើរតួនាទីជំនួសសមាជិកសភា ពីរភាគបី (៨២ រូប) ក្នុងការលើកអភ័យឯកសិទ្ធិសភាដែលសម្លេងនេះ គឺមានច្រើនជាងតម្រូវការអនុម័តច្បាប់ និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលទៅទៀត ដែលត្រូវការសម្លេងសមាជិកសភាច្រើនដាច់ខាតតែ៦៣រូបប៉ុណ្ណោះ។

អ្នកវិភាគខ្លះលើកឡើងថា *"គណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើហួសមាឌរបស់គាត់ ព្រោះខ្លួនគ្រាន់តែជាអ្នកសំរេចលើកយករបៀបវារៈដកអភ័យឯកសិទ្ធិទៅដាក់ក្នុងសម័យប្រជុំពេញអង្គប៉ុណ្ណោះ មិនមែនមានសិទ្ធិសំរេចដកតែម្តងទេ។ គណៈកម្មាធិការអចិន្ត្រៃយ៍គ្រាន់តែជារដ្ឋបាលសំរាប់ទាក់ទងនៅសម័យរដ្ឋសភាវិស្សមកាលប៉ុណ្ណោះ។"*

បើមើលក្នុងទិដ្ឋភាពនយោបាយ ប្រសិនបើការអនុវត្តន៍បែបនេះនៅតែបន្តទៀត ដោយការលើកអភ័យឯកសិទ្ធិសភាត្រឹមគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នោះអភ័យឯកសិទ្ធិសភាដែលចាត់ទុកថាជា អាវក្រោះសម្រាប់ការពារតំណាងរាស្ត្រ

នឹងងាយត្រូវដកចេញ ដោយគណបក្សណាដែលមានសម្លេងគ្រប់ដណ្តប់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដោយមិនត្រូវការការអនុម័តពីតំណាងរាស្ត្រយ៉ាងតិច៨២រូប ដែលអាចមកពីគណបក្សចម្រោះនោះទេ។

ប្រការនេះនឹងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការបំពេញការងាររបស់អ្នកតំណាងរាស្ត្រ ដែលមិនកាន់អំណាចក្នុងការឃ្លាំមើល រួមទាំងការបញ្ចេញមតិរិះគន់ការងាររបស់រាជរដ្ឋាភិបាលផងដែរ ដែលជួនកាលត្រូវបានចោទពីបទបរិហារកេរ្តិ៍ ។ល។

ទន្ទឹមនឹងនេះ ការប្រគល់អភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រវិញក៏មានការអនុវត្តពុំទាន់ច្បាស់ដែរ ហើយមាននិយាយតិចតួចប៉ុណ្ណោះនៅក្នុងច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រមាត្រា១៥ ដែលថា អ្នកតំណាងរាស្ត្រណាមួយជាទណ្ឌិតត្រូវបានព្រះមហាក្សត្រលើកលែងទោស នោះតំណាងរាស្ត្រនោះនឹងបានអភ័យឯកសិទ្ធិឡើងវិញ និងមាត្រា១៦ដែលថា តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬសាលដីកាសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ...ពេញលេញឡើងវិញ។

ទោះបីយ៉ាងណា ការអនុវត្តជាក់ស្តែងដើម្បីបានអភ័យឯកសិទ្ធិមកវិញ គឺទាមទារនូវនីតិវិធីដែលបកស្រាយខុសៗគ្នាទៅលើមាត្រា១៥ និង១៦នេះ ហើយជាទូទៅអ្នកសម្រេច គឺគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា។

ក្នុងនីតិកាលទី៤ ការសង្កេតឃើញថា ការប្រគល់អភ័យឯកសិទ្ធិសភាគឺដើរតាមនីតិវិធីដូចការ «លើក» ដែរ ហើយនីតិវិធីបែបនេះ ត្រូវបានការពារដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា។ បានន័យថា ប្រសិនបើតុលាការជាអ្នកស្នើលើកអភ័យឯកសិទ្ធិ ហើយការលើកអភ័យឯកសិទ្ធិតាមរយៈការបោះឆ្នោតដោយសមាជិករដ្ឋសភា នោះការប្រគល់អភ័យឯកសិទ្ធសភាវិញ លុះត្រាតែមានលិខិតពីតុលាការ តាមរយៈក្រសួងយុត្តិធម៌ ហើយត្រូវធ្វើការបោះឆ្នោតផ្តល់អភ័យឯកសិទ្ធិដោយសមាជិកសភាវិញផងដែរ។

សំណួរថា ប្រសិនបើតំណាងរាស្ត្រដែលត្រូវបានលើកអភ័យឯកសិទ្ធិត្រូវបានតុលាការរកឃើញថា គ្មានទោស ក៏ប៉ុន្តែតុលាការ ឬក្រសួងមិនបានបញ្ជូនលិខិតមករដ្ឋសភាទេនោះ (ព្រោះមិនមានច្បាប់ ឬឯកសារណាឲ្យក្រសួងយុត្តិធម៌បញ្ជូនលិខិតមកវិញ ដូចកាលស្នើលើកអភ័យឯកសិទ្ធិនោះទេ) នោះតំណាងរាស្ត្រនោះនឹងមិនបានទទួលអភ័យឯកសិទ្ធិរបស់ខ្លួនវិញនោះទេ។

បញ្ហាក៏អាចចោទដែរថា ប្រសិនបើត្រូវបោះឆ្នោតតាមសម្លេងពីរភាគបី ដើម្បីបានអភ័យឯកសិទ្ធិមកវិញ ចុះបើសិនជាសមាជិកសភាមិនបោះឆ្នោតឲ្យនោះ ថាតើអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រនោះក៏នៅតែនឹងមិនបានវិញទេឬ? គ្មានច្បាប់ណាដែលកំណត់ថា អភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រត្រូវបានប្រគល់វិញ តាមរយៈការបោះឆ្នោតគាំទ្រពីអ្នកតំណាងរាស្ត្រនោះទេ។

ការបកស្រាយក៏ដូចជាការអនុវត្តន៍បែបនេះ មិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឬបទបញ្ជាផ្ទៃក្នុងរដ្ឋសភានោះទេ។ ហើយវាហាក់ដូចជាមានភាពចម្រូងចម្រាសទៅនឹងមាត្រា១៥ និង១៦នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រដែលធានាដល់ការបានអភ័យឯកសិទ្ធិជាស្វ័យប្រវត្តិនៅពេលគ្មានទោស ឬត្រូវបានលើកលែងទោស។

ភាពមិនរលូននូវការអនុវត្តន៍បែបនេះបានកើតមាននៅក្នុងឆ្នាំសង្កេតនេះ នៅក្នុងករណីអ្នកតំណាងរាស្ត្រ **ហូ វ៉ាន់** មណ្ឌលភ្នំពេញ មកពីគណបក្សសមរង្ស៊ីដែលត្រូវបានលើកអភ័យឯកសិទ្ធិ ដើម្បីឲ្យតុលាការធ្វើការចោទប្រកាន់ ក៏ប៉ុន្តែត្រូវបានតុលាការលើកលែងការចោទប្រកាន់វិញនៅចុងខែកញ្ញា ឆ្នាំ២០០៩។ ទោះបីយ៉ាងណា អភ័យឯកសិទ្ធិសភារបស់អ្នក

តំណាងរាស្ត្ររូបនេះ ត្រូវបានផ្តល់មកឲ្យវិញនៅដើមខែមីនា ឆ្នាំ២០១០ គឺរយៈពេលប្រមាណ៦ខែ បន្ទាប់ពីការលើកលែងការចោទប្រកាន់។

ជាមួយគ្នានេះ បើមើលតាមទិដ្ឋភាពនយោបាយវិញការផ្តល់អភ័យឯកសិទ្ធិវិញ តាមរយៈការបោះឆ្នោតសម្លេងភាគច្រើនពីរភាគបីក៏អាចជាបញ្ហាផងដែរ នៅពេលដែលបុគ្គលមានអំណាចក្នុងគណបក្សឈ្នះឆ្នោតចង់ធ្វើបាបគូប្រឆាំងរបស់ខ្លួន តាមរយៈមិនបោះឆ្នោតផ្តល់អភ័យឯកសិទ្ធិសភាឲ្យវិញ។

អនុប្រធានគណបក្សប្រជាជនកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ធ្លាប់បាននិយាយជាសាធារណៈនៅខែមិថុនាឆ្នាំ២០០៩ ទៅដល់ការលើកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រចំនួនពីររូប ដោយមិនបញ្ចេញឈ្មោះថា *"ខ្ញុំករុណាព្រួយណាស់ ព្រួយថាដកមួយហ្នឹង ៩១អ្នក [សម្លេង][តំណាងរាស្ត្រមណ្ឌល] នៅភ្នំពេញ [និង តំណាងរាស្ត្រ] កំពត៩០ [សម្លេង] ដល់ឲ្យទៅវិញ ឲ្យវាមិនកើត។*

ដូចនេះ ការអនុវត្តន៍បែបនេះតាមរយៈ «**ការលើកតាមណា ផ្តល់តាមហ្នឹង**» គឺកំពុងតែអាចរំលោភទៅលើល័ក្ខខ័ណ្ឌបានអភ័យឯកសិទ្ធិដោយស្វ័យប្រវត្តិវិញ ហើយវានឹងក្លាយជាឧបករណ៍នយោបាយមួយ នៅពេលណាដែលមានអំណាចចង់ប្រើប្រាស់វា។

ជាក់ស្តែងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនីតិកាលទី៤ នេះក៏មិនស៊ីសង្វាក់គ្នាដែរដែលថា អភ័យឯកសិទ្ធិលើកតាមណាត្រូវប្រគល់ឲ្យវិញតាមនោះដែរ។

អ្នកតំណាងរាស្ត្រ **ហូ វ៉ាន់**ត្រូវបានសភាដកអភ័យឯកសិទ្ធិតាមរយៈការបោះឆ្នោត ក៏ប៉ុន្តែនៅពេលប្រគល់អភ័យឯកសិទ្ធិវិញគឺគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នកសម្រេចប្រគល់ឲ្យដោយគ្មានការបោះឆ្នោតពីសមាជិករដ្ឋសភានោះទេ។

ខុមហ្វ្រែលយល់ឃើញថា នីតិវិធីនៃការលើកអភ័យឯកសិទ្ធិមានចែងពិស្តារនៅក្នុងច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ក៏ប៉ុន្តែគឺកង្វះខាតការអនុវត្តន៍ឲ្យបានពេញលេញទៅតាមមាត្រា ក៏ដូចជាអត្ថន័យនៅក្នុងច្បាប់នេះទាក់ទងនឹងការលើកអភ័យឯកសិទ្ធិតំណាងរាស្ត្រនៅចន្លោះសម័យប្រជុំ ដែលតម្រូវឲ្យការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាទាក់ទងនឹងការលើកអភ័យឯកសិទ្ធិត្រូវតែទទួលបានការអនុម័តពីសមាជិកសភា ពីរភាគបី ហើយគណៈកម្មាធិការខុមហ្វ្រែលស្នើសុំបញ្ឈប់ការអនុវត្តន៍ការលើកអភ័យឯកសិទ្ធិសភាត្រឹមតែគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។

ជាមួយគ្នានេះដែរ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ក៏គួបញ្ឈប់ការអនុវត្តការប្រគល់អភ័យឯកសិទ្ធិតាមការបកស្រាយដោយខ្លួនឯងថា ការប្រគល់អភ័យឯកសិទ្ធិវិញ គឺធ្វើតាមនីតិវិធីនៃការដក។ តែត្រូវពង្រឹងការអនុវត្តមាត្រា១៥ និង១៦ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រដែលធានាដល់ការបានអភ័យឯកសិទ្ធិសភាមកវិញដោយស្វ័យប្រវត្តិ ចំពោះតំណាងរាស្ត្រណាដែលគ្មានទោស ឬព្រះមហាក្សត្រលើកលែងទោស។

## អ្នកតំណាងរាស្ត្រស្ត្រីចង់បង្កើតក្រុមតំណាងរាស្ត្រស្ត្រី

នៅចុងឆ្នាំសង្កេតនេះ (ខែកញ្ញា២០១០) មានការជួបជុំគ្នារវាងស្ត្រីជាថ្នាក់ដឹកនាំក្នុងប្រទេស និងក្រៅប្រទេសមួយចំនួននៅក្នុងសិក្ខាសាលា ស្តីពីគោលការណ៍សហស្សវត្សរ៍ស្តីពីការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៣នៅឆ្នាំ២០១៥ដើម្បីសំរេចឱ្យមានស្ត្រីចូលរួមនៅក្នុងវិស័យនយោបាយឱ្យបានច្រើន ដោយក្នុងនោះមានការជំរុញឱ្យមានការបង្កើតក្រុមតំណាងរាស្ត្រស្ត្រីផងដែរដែលទទួលស្គាល់ដោយរដ្ឋសភាខ្លួនឯងផ្ទាល់ដើម្បីលើកកម្ពស់ការងារ និងការពារផលប្រយោជន៍ស្ត្រី។

អ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សកាន់អំណាច និងគណបក្សជំទាស់ហាក់បង្ហាញការគាំទ្រចំពោះការបង្កើតក្រុមតំណាងរាស្ត្រស្ត្រី ក្នុងគោលបំណងការពារផលប្រយោជន៍ស្ត្រី ក៏ប៉ុន្តែការសង្កេតឃើញថា និន្នាការនយោបាយហាក់ធ្វើឲ្យតំណាងរាស្ត្រក្នុងគណបក្សទាំងពីរនេះពិបាកធ្វើការជាមួយគ្នា។

អ្នកតំណាងរាស្ត្រស្ត្រីគណបក្សកាន់អំណាចលើកឡើងថា តំណាងរាស្ត្រស្ត្រីគណបក្សប្រឆាំងមិនសហការធ្វើការជាមួយខ្លួន ខណៈដែលតំណាងរាស្ត្រស្ត្រីគណបក្សប្រឆាំងថា មានការរើសអើងចំពោះខ្លួននៅពេលចុះអនុវត្តការងាររួមគ្នា។

អ្នកតំណាងរាស្ត្រ **ឡោក ខេង** មណ្ឌលភ្នំពេញមកពីគណបក្សកាន់អំណាចប្រជាជនកម្ពុជាបានលើកឡើងក្នុងឱកាសសិក្ខាសាលាខាងលើថា *«សភានាងខ្ញុំបច្ចុប្បន្នមានការលំបាកណាស់ចំពោះការចូលរួមរបស់ស្ត្រីដោយយើងស្ថិតនៅក្នុងគណបក្សកាន់អំណាចជាស្ត្រីមានមតិភាគច្រើនក្នុងសភាធ្វើអីមួយៗចង់ឱ្យគេចូលរួមទាំងអស់គ្នាតែគំរឃើញគេចូលរួមណាស់ពីគណបក្សដែលមានសំលេងភាគតិចនៅក្នុងសភាព្រោះខ្ញុំមានបញ្ហាថា អញ្ជើញគេមកអត់ដែរគេចូលរួមផង។»*

ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលសៀមរាប **កែ សុវណ្ណរ័តន៍** បានលើកឡើងពីការមិនឲ្យតម្លៃដល់តំណាងរាស្ត្រស្ត្រីមកពីគណបក្សសម្លេងភាគតិចថា *«គ្មានតម្លាភាព។ ខ្ញុំធ្លាប់បានចូលរួមជាមួយក្រុមស្ត្រីគណៈកម្មការតាមខេត្តមួយចំនួនទៅចែកអំណោយ។ ធ្វើសន្ទរកថាឱ្យប្រធានក្រុមមានសិទ្ធិនិយាយ។ប្រធានមកពីគណបក្សកាន់អំណាចទៀតហើយយើងទៅបានអង្គុយល្ហមើលការចាត់ចែងមិនស្មើភាព។»*

អ្នកតំណាងរាស្ត្ររូបនេះមិនមានជំនឿចិត្តថា ក្រុមតំណាងរាស្ត្រស្ត្រី បើទោះបីជាត្រូវបានបង្កើតនឹងមិនជោគជ័យក្នុងការធ្វើការសហការដើម្បីការពារផលប្រយោជន៍ស្ត្រីបាននោះដែរដោយបង្ហាញថា *«កន្លងមកស្ត្រីគ្នាឯងធ្លាប់លើកដៃដកអភ័យឯកសិទ្ធិគ្នាឯង។ ម្យ៉ាងទៀតស្ត្រីនៅក្នុងគណបក្សកាន់អំណាចមិនហ៊ានចេញមុខអន្តរាគមន៍ជួយស្ត្រីគ្នាឯងដូចករណីលោកជំទាវមូរសុខហួរផង។»*

ក្រុមតំណាងរាស្ត្រស្ត្រីបង្កើតឡើងដើម្បីជំរុញឱ្យស្ត្រីមានអំណាច និងលើកទឹកចិត្តដើម្បីចូលរួមក្នុងការសំរេចចិត្តថ្នាក់ជាតិតំបន់និងជំរុញឱ្យស្ត្រកាន់តែមានភាពក្លាហានក្នុងការសំដែងមតិរបស់ខ្លួនដោយមិនមានការគាបសង្កត់ហើយរដ្ឋសភាគួរមានចំណែកថវិកានិងយន្តការដើម្បីសំរួលក្នុងការធ្វើយ៉ាងណាដើម្បីបំផុសឱ្យស្ត្រីធ្វើសកម្មភាពធំៗថ្នាក់ជាតិ។

ក៏ប៉ុន្តែ ការប្រកាន់និន្នាការនយោបាយរៀងៗខ្លួន ហាក់ជាឧបសគ្គក្នុងការបង្កើក្រុមនេះឡើង ឲ្យមានប្រសិទ្ធិភាព។

## គណបក្សរំលាយអាសនៈតំណាងរាស្ត្របាត់បង់

ក្នុងឆ្នាំអង្គតនេះដែរ ក្នុងខែសីហា ឆ្នាំ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញដែលជាស្ថាប័នបកស្រាយច្បាប់កំពូលបានកំណត់ភាពជាតំណាងប្រជាពលរដ្ឋរបស់អ្នកតំណាងរាស្ត្រកាន់តែខ្សោយថែមទៀត បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយសំណួររបស់អ្នកតំណាងរាស្ត្រទាក់ទងនឹងភាពតំណាងនេះថា សមាជិកភាពសភានឹងត្រូវបាត់បង់ បើសិនជាគណបក្សនយោបាយដែលអ្នកតំណាងរាស្ត្រជាសមាជិកនោះត្រូវបានរំលាយ។

ការបកស្រាយនេះ ជាការឆ្លើយតបទៅនឹងសំណួររបស់អ្នកតំណាងរាស្ត្រ សៅ រ៉ានី មកពីគណបក្សជាតិនិយមដែលចង់ច្របាច់បញ្ចូលគ្នាជាមួយគណបក្សហ៊្វុនស៊ិនប៉ិច ទៅក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៣៦នៃច្បាប់ ស្តីពីគណបក្សនយោបាយ នៅពេលគណបក្សនយោបាយរួមបញ្ចូលគ្នាតើសមាជិកសភានឹងបាត់បង់អាសនៈដែរឬទេ?

ម្យ៉ាងទៀត ច្បាប់បោះឆ្នោតក៏បានចងសមាជិកភាពអ្នកតំណាងរាស្ត្រទៅនឹងគណបក្សនយោបាយ ដែលបានន័យថា តំណាងរាស្ត្រណាដែលបាត់សមាជិកភាពពីគណបក្សនយោបាយនោះសមាជិកសភាក៏ត្រូវបាត់បង់ផងដែរ។

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញក៏មិនបានឆ្លុះបញ្ចាំងក្នុងក្របខណ្ឌធម្មនុញ្ញភាព និងគោលការណ៍សំខាន់ភាពជាតំណាងរបស់អ្នកតំណាងរាស្ត្រ ព្រោះថា រដ្ឋធម្មនុញ្ញមិនបាននិយាយថាតំណាងរាស្ត្រ គឺស្មើតំណាងគណបក្សនោះទេ។

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញទៅលើមាត្រា៣៦នេះ ដែលតម្រូវឲ្យអាសនៈរបស់គណបក្សនយោបាយជាប់ឆ្នោតត្រូវរលាយនៅពេល ១) គណបក្សនយោបាយណាដែលបញ្ចូលខ្លួនជាមួយគណបក្សផ្សេងទៀត តំណាងរាស្ត្រគណបក្សដែលទៅចូលរួមជាមួយគេ នឹងត្រូវបាត់បង់អសនៈដែលបានមកពីការជាប់ឆ្នោតទាំងអស់ ឬ២) ប្រសិនបើគណបក្សបញ្ចូលគ្នាហើយ បង្កើតជាគណបក្សថ្មីនោះគណបក្សដើមបានប្រកាសរំលាយ នោះអ្នកតំណាងរាស្ត្ររបស់ខ្លួនត្រូវបាត់បង់អសនៈដែលបានមកពីការបោះឆ្នោតទាំងអស់។

ការបកស្រាយនេះត្រូវបានអ្នកវិភាគខ្លះយល់ថា ហាក់ចង់ព្រមានដល់គណបក្សជំទាស់ទាំងឡាយដែលមានបំណងរួមបញ្ចូលគ្នាបង្កើតគណបក្សផ្សេង ដើម្បីប្រកួតប្រជែងការបោះឆ្នោតពីគណបក្សកាន់អំណាច ឬគណបក្សនោះត្រូវបានរំលាយដោយសាលក្រម ឬសាលដីការបស់តុលាការអាចនឹងឈានដល់ការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយក៏បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវចេតនាប្រហែស ឬចន្លោះសម្រាប់បកស្រាយពីភាពមិនប្រក្រតីនៃបញ្ញត្តិទាំងឡាយដែលបានតាក់តែង និងអនុម័តឡើងដើម្បីដាក់គំនាប រឹតបន្តឹងភាពជាតំណាង។

ខុមហ្វ្រែលយល់ឃើញថា ដើម្បីធានាដល់គោលការណ៍របស់រដ្ឋធមនុញ្ញ ជាពិសេសគោរពដល់មាត្រា៧៧ ដែលកំណត់ថា អ្នកតំណាងរាស្ត្រជាតំណាងប្រជាពលរដ្ឋទូទាំងប្រទេស សមាជិកសភា គួរធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដោយមិនត្រូវចងសមាជិកសភាពអ្នកតំណាងរាស្ត្រទៅនឹងគណបក្សនយោបាយ និងធ្វើវិសោធនកម្មមាត្រា៣៦នៃច្បាប់ស្តីពី គណបក្សនយោបាយដោយបញ្ជាក់ឲ្យច្បាស់ថា គណបក្សដែលរំលាយ ឬបញ្ចូលជាមួយគណបក្សដទៃទៀតនឹងមិនត្រូវបាត់បង់អាសនៈរបស់ខ្លួននោះទេ រហូតដល់ចប់អាណត្តិរបស់ខ្លួន។

## អ្នកតំណាងរាស្ត្រសមរង្ស៊ីត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធធនាគារ១២ឆ្នាំ

អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម សម រង្ស៊ី និងជាប្រធានគណបក្សសមរង្ស៊ីត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារសរុប១២ឆ្នាំ នៅក្នុងសំណុំរឿងពីរផ្សេងគ្នាជាមួយរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។

ការកាត់ទោសនេះ បានធ្វើឡើងបន្ទាប់ពីសមាជិកសភាមកពីគណបក្សកាន់អំណាចបោះឆ្នោតព្យួរអភ័យឯកសិទ្ធិសភាជាលើកទី២នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ ដើម្បីបើកផ្លូវឱ្យតុលាការខេត្តស្វាយរៀងធ្វើការស៊ើបសង្កេត និងចោទប្រកាន់អ្នកតំណាងរាស្ត្ររូបនេះពីបទប្រព្រឹត្តអំពើដកបំផ្លាញតម្រុយបង្គោលព្រំដែនកម្ពុជា វៀតណាម និងញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹមដោយពុំបានសំរេចផលនៅស្រុកចន្ទ្រា ខេត្តស្វាយរៀង ហើយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ តុលាការខេត្តស្វាយរៀងក៏បានកាត់ទោសឲ្យអ្នកតំណាងរាស្ត្ររូបនេះជាប់ពន្ធនាគាររយៈពេល២ឆ្នាំ និងផាកពិន័យជាប្រាក់ជាង៦០លានរៀល។

ថែមទៀតដោយសារបញ្ហាព្រំដែនរាជរដ្ឋាភិបាលបានដាក់ពាក្យបណ្ដឹងនេះទៅតុលាការ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១០ ដោយចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ និងផ្សព្វផ្សាយព័ត៌មានមិនពិតដែលអ្នកតំណាងរាស្ត្ររូបនេះ បានបង្ហោះឯកសារទាក់ទងនឹងព្រំដែនកម្ពុជា វៀតណាមតាមអ៊ីនធឺណែត។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ តុលាការរាជធានីភ្នំពេញក៏បានកាត់ទោសឲ្យអ្នកតំណាងរាស្ត្រសមរង្ស៊ីជាប់ពន្ធនាគារ១០ឆ្នាំទៀត ពីបទផ្សាយព័ត៌មានមិនពិត និងក្លែងបន្លំឯកសារសាធារណៈតាមការប្ដឹងរបស់រាជរដ្ឋាភិបាល។

ដូចនេះក្នុងឆ្នាំនេះសង្កេតនេះ អ្នកតំណាងរាស្ត្ររូបនេះត្រូវបានតុលាការកាត់ទោសសរុបរយៈពេល១២ឆ្នាំ។ ទោះបីយ៉ាងណា អ្នកតំណាំងរាស្ត្ររូបនេះបាននិរទេសខ្លួននៅក្រៅប្រទេស ហើយសំណុំរឿងនេះក៏កំពុងប្ដឹងឧទ្ធរណ៍បន្តទៀត។

ខុមហ្វ្រែលយល់ថា បញ្ហាជម្លោះព្រំដែនរវាងតំណាងរាស្ត្រជាមួយនឹងរាជរដ្ឋាភិបាលនេះ គួរមានដំណោះស្រាយបែបនយោបាយ ព្រោះអ្នកតំណាងរាស្ត្រ គឺជាបុគ្គលដែលតំណាងឱ្យប្រជាពលរដ្ឋទាំងមូល ហើយដែលមានតួនាទីត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល ហើយសមាជិកសភាសហគមន៍អឺរុបខ្លះក៏បានអំពាវនាវឱ្យមានដំណោះស្រាយបែបនយោបាយនេះដែរ។

## ឧបសម្ព័ន្ធទី១ : ការប៉ាន់ប្រមាណគុណភាពនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រ

(**តាមលំដាប់ពីច្រើនទៅតិច**)

- **សំគាល់: ឯ.ឧ .= ឯកឧត្តម , ល.ជ = លោកជំទាវ**

| ល.រ | ឈ្មោះតំណាងរាស្ត្រ | គណបក្ស | ចំនួនលើក | អញ្ញត្រិត្យ ជានាទី | វិជ្ជមាន ជានាទី | អវិជ្ជមាន ជានាទី | សរុបជានាទី |
|---|---|---|---|---|---|---|---|
| ១ | ឯ.ឧ យឹម សុវណ្ណ | | ៣៨ | ២៨០ | ៣១ | ២០៩ | ៥២០ |
| ២ | ឯ.ឧ សុន ឆ័យ | | ២២ | ២៤០ | ១១ | ៩០ | ៣៤១ |
| ៣ | ល.ជ. មូរ សុខហួរ | | ២៧ | ១៩៦ | ២០ | ៦៩ | ២៨៥ |
| ៤ | ឯ.ឧ ជាម យៀប | | ២៤ | ២០៣ | ៥៥ | ៧ | ២៦៥ |
| ៥ | ឯ.ឧ ឈាង វុន | | ២១ | ១១៤ | ២៣ | ១៥ | ១៥២ |
| ៦ | ឯ.ឧ គឹមសួរ ភីរិទ្ធិ | | ១១ | ៦៣ | ១៣ | ៦១ | ១៣៧ |
| ៧ | ល.ជ. លី ស្រីវីណា | | ១២ | ១០៩ | ៣ | ១៤ | ១២៦ |
| ៨ | ឯ.ឧ អេង ឆៃអ៊ាង | | ១៧ | ៧៧ | ១ | ៣០ | ១០៨ |
| ៩ | ឯ.ឧ ងួន ញ៉ិល | | ១៦ | ៧២ | ១៥ | ៦ | ៩៣ |
| ១០ | ឯ.ឧ យូ ហុកគ្រី | | ១០ | ៦៤ | ១៦ | ១០ | ៩០ |
| ១១ | ឯ.ឧ ជាម ច័ន្ទនី | | ៥ | ៥៦ | ៦ | ២២ | ៨៤ |
| ១២ | ឯ.ឧ អាយ ខន | | ៦ | ៤០ | ១២ | ៣១ | ៨៣ |
| ១៣ | ឯ.ឧ ហែម ខន | | ១០ | ៧៧ | ៥ | ០ | ៨២ |
| ១៤ | ឯ.ឧ ស៊ិក ប៊ុនហុក | | ៦ | ៤៩ | ៣ | ២៨ | ៨០ |
| ១៥ | ឯ.ឧ ប៉ែន បញ្ញា | | ៩ | ២៧ | ២៨ | ៨ | ៦៣ |
| ១៦ | ឯ.ឧ សម រង្ស៊ី | | ៣ | ២៩ | ២ | ២៩ | ៦០ |
| ១៧ | ឯ.ឧ វ៉ាន់ សេងលី | | ៥ | ២៦ | ២០ | ១២ | ៥៨ |
| ១៨ | ឯ.ឧ ហេង សំរិន | | ៩ | ៣៧ | ២ | ៨ | ៤៧ |
| ១៩ | ល.ជ. គ្រួច សំអាន | | ៣ | ១៨ | ១៥ | ៥ | ៣៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០ | ល.ជ. ជូឡុង សូមូរ៉ា | | ២ | ១៧ | ២ | ១៤ | ៣៣ |
| ២១ | ល.ជ. និន សុផុន | | ៣ | ៨ | ១៩ | ៤ | ៣១ |
| ២២ | ឯ.ឧ នុត រំដួល | | ៣ | ១៣ | ១០ | ៧ | ៣០ |
| ២៣ | ឯ.ឧ សោម ចិន | | ៤ | ១២ | ០ | ១៨ | ៣០ |
| ២៤ | ឯ.ឧ មឹន ស៊ាន | | ២ | ១៥ | ១២ | ០ | ២៧ |
| ២៥ | ល.ជ. ម៉ែន សំអន | | ៤ | ២០ | ៥ | ១ | ២៦ |
| ២៦ | ឯ.ឧ ហួរ វ៉ាន់ | | ២ | ២៣ | ០ | ០ | ២៣ |
| ២៧ | ឯ.ឧ យន្ត ថារូ | | ៣ | ១៥ | ៤ | ៣ | ២២ |
| ២៨ | ឯ.ឧ អ៊ិច សារ៉ូ | | ១ | ០ | ២១ | ០ | ២១ |
| ២៩ | ឯ.ឧ ម៉ុម ជឹមហ៊ុយ | | ១ | ១១ | ៩ | ០ | ២០ |
| ៣០ | ល.ជ. សោម គីមសួគ៌ | | ៣ | ៥ | ១២ | ០ | ១៧ |
| ៣១ | ល.ជ. កែ សុវណ្ណរតន៍ | | ២ | ១១ | ០ | ៥ | ១៦ |
| ៣២ | ឯ.ឧ គួយ ប៊ុនរឿន | | ៣ | ១៣ | ៣ | ០ | ១៦ |
| ៣៣ | ឯ.ឧ ញឹក ប៊ុនឆៃ | | ៤ | ៨ | ២ | ៤ | ១៤ |
| ៣៤ | ល.ជ. ហូ ណួន | | ១ | ៨ | ៣ | ០ | ១១ |
| ៣៥ | ឯ.ឧ ប៊ិន ឈិន | | ៣ | ៥ | ៤ | ២ | ១១ |
| ៣៦ | ឯ.ឧ ស្មាន ទៀត | | ២ | ១០ | ១ | ០ | ១១ |
| ៣៧ | ឯ.ឧ ម៉ៅ មុនីវណ្ណ | | ១ | ៣ | ០ | ៧ | ១០ |
| ៣៨ | ឯ.ឧ ទៀ បាញ់ | | ១ | ១០ | ០ | ០ | ១០ |
| ៣៩ | ឯ.ឧ ឃី វណ្ណដេត | | ១ | ៨ | ០ | ១ | ៩ |
| ៤០ | ឯ.ឧ ម៉ែន សុថាវរិន្ទ្រ | | ១ | ៦ | ១ | ២ | ៩ |
| ៤១ | ឯ.ឧ សុខ ឥសាន | | ១ | ៤ | ០ | ៥ | ៩ |
| ៤២ | ល.ជ. ឃួន សុដារី | | ១ | ៦ | ២ | ០ | ៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤៣ | ឯ.ឧ អន ស៊ុំ | | ១ | ៧ | ០ | ០ | ៧ |
| ៤៤ | ឯ.ឧ ជា ចំរើន | | ១ | ២ | ២ | ០ | ៤ |
| ៤៥ | ល.ជ. ឡោក ខេង | | ១ | ២ | ២ | ០ | ៤ |
| ៤៦ | ល.ជ. លី គឹមលៀង | | ១ | ២ | ០ | ០ | ២ |
| សរុប | = លើក១៣៩ = រូប២៧ =១២១០នាទី<br>= រូប១៧ =១៥៤លើកនាទី១៨២៩ =<br>= រូប១ =៤លើកនាទី១៤ =<br>= រូប១ =១០លើក នាទី៩០ = | | ៣០៧ លើក | ២០២១នាទី ( ៦៤%) | ៣៩៥នាទី ( ១៣%) | ៧២៧នាទី ( ២៣%) | ៣១៤៣នាទី (១០០%) |

**ឧបសម្ព័ន្ធទី២ : សេចក្តីព្រាងច្បាប់ និងរបៀបវារៈដែលបានពិភាក្សានិងអនុម័តក្នុងសម័យប្រជុំសភា**

នៅក្នុងសម័យប្រជុំទាំង៣៧ដង រដ្ឋសភាបានពិភាក្សា ឬ/និងអនុម័ត របៀបវារៈបាន ៣៥ច្បាប់ក្នុងនោះមានរបៀបវារៈ២៩ ដែលតម្រូវឲ្យមានការពិភាក្សា រួមមានអគ្គបទច្បាប់ សេចក្តីព្រាងច្បាប់/សេចក្តីស្នើច្បាប់រួមទាំងការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង និងសន្ធិសញ្ញានានាមានចំនួន ២៤ច្បាប់ ។ ចំណែករបៀបវារៈ ចំនួន ៦ទៀត គឺទាក់ទងនឹងការប្រកាសទទួលស្គាល់តំណាងរាស្ត្រថ្មី/ការផ្លាស់ប្តូរតំណាងរាស្ត្រដែលគ្មានការពិភាក្សា និងអនុម័តនោះទេ ។ល។

| ល. រ | ថ្ងៃខែឆ្នាំ | របៀបវារៈ | សំលេង |
|---|---|---|---|
| ១ | ១២-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ | ៩៩/ ១០២ |
| ២ | ១៤-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម | ១០២/ ១០៥ |
| ៣ | ១៥-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន | ១០១/ ១០២ |
| ៤ | ១៥-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមនប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន | ៩៩៩៩/ |

| | | | |
|---|---|---|---|
| ៥ | ១៦-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្ម នៃកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន | ៩៦៩៨/ |
| ៦ | ១៦-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេវាកម្មក្រោម កិច្ចព្រមព្រៀងក្របខណ្ឌស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ | ៩៨៩៨/ |
| ៧ | ២១-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី | ៧៦/ ១០១ |
| ៨ | ២៣-១០-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពី សុំកូនអន្តរប្រទេស | ៧២៧២/ |
| ៩ | ០១-១១-០៩ | អនុម័តសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រង់គ្រងថវិកាជាតិ ២០១០ | ៨១/ ១០៣ |
| ១០ | ១៦-១១-០៩ | ប្រជុំលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ សម រង្ស៊ី | |
| ១១ | ២៥-១២-០៩ | ការឆ្លើយបំភ្លឺរបស់ឯកឧត្តម វ៉ា គីមហុង លើសំនួររបស់ឯកឧត្តម  សុន ឆ័យ ទាក់ទងនឹងបញ្ហាបោះបង្គោះព្រំដែនកម្ពុជា-វៀតណាម | មិនតម្រូវឲ្យអនុម័ត |
| ១២ | ២៩-១២-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីអាស្យាមិករណ៍ | ៧៦/ ១០០ |
| ១៣ | ៣០-១២-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ | ៧៦៩៤/ |
| ១៤ | ៣០-១២-០៩ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ប្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌ | ៩៣៩៤/ |
| ១៥ | ១១-០៣-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ | ៨២/៨២ |
| ១៦ | ០៥-០៤-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការផ្តល់សិទ្ធិលើចំណែកឯកជននៃអាគារសហកម្មសិទ្ធិដល់ជនបរទេស | ៨៥៩៦/ |
| ១៧ | ០៥-០៤-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងអំពើភេរវកម្ម | ៨៩៩០/ |
| ១៨ | ២៦-០៤-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល | ១០០/ ១០០ |
| ១៩ | ២៧-០៤-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចប្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | ៨១៩១/ |

| | | | |
|---|---|---|---|
| ២០ | ០៦-០៥-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋ ប្រជាមានិតចិន | ៨៩៨៩/ |
| ២១ | ០៦-០៥-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចប្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយម វៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក | ៨១៩១/ |
| ២២ | ២៧-០៥-១០ | ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ១រូប សម្រាប់អណត្តិថ្មីឆ្នាំ ២០១០-២០១៩ | ៩៧/ ១០៨ |
| ២៣ | ២៧-០៥-១០ | ការបោះឆ្នោតទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលកែសម្រួលចំនួន ១១រូប | ៨៧/ ១០៨ |
| ២៤ | ២៧-០៥-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យទៅក្រុមហ៊ុនខេមបូឌាន ទ្វែនមីសិន លីមីធីត | ៨៤/ ១០៤ |
| ២៥ | ២៧-០៥-១០ | អ្នកតំណាងរាស្ត្រ សុខ សាយ ត្រូវបានជ្រើសតាំងជាសមាជិកគណកម្មាការទី៨ | ៨៥៩៥/ |
| ២៦ | ៣១-០៥-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ប្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ | ៨៦៨៩/ |
| ២៧ | ០៨-០៦-១០ | ការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | ៨៣/ ១០៦ |
| ២៨ | ០៩-០៦-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង | ៨០៨២/ |
| ២៩ | ០១-០៧-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចប្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្រប<br>ខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមព្រជាជាតិអាស៊ីអាគ្នេយ៍និង សាធារណរដ្ឋប្រជាមានិតចិន | ៨០៨១/ |
| ៣០ | ០១-០៧-១០ | ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្រប<br>ខណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋប្រជាមានិតកូរ៉េ | ៨៣៨៣/ |

## ឧបសម្ព័ន្ធទី៣ : នាមអ្នកតំណាងរាស្ត្រម្នាក់ៗដែលបានចុះមូលដ្ឋាន

(រៀបតាមលំដាប់ពីច្រើនទៅតិចដោយគិតចាប់ពីថ្ងៃទី ០១ តុលា ២០០៩ ដល់ កញ្ញា ២០១០)

- **សំគាល់: ឯ.ឧ. = ឯកឧត្តម , ល.ជ. លោកជំទាវ**

| លរ | ឈ្មោះតំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងគណបក្ស | វេទិកា | អមដំណើរ | |
| ១ | ឯ.ឧ កឹម សុខា | | ០ | ៧៧ | ១០៤ | ១ | ០ | ១៨២ |
| ២ | ឯ.ឧ យ៉ែម បុញ្ញឫទ្ធិ | | ០ | ៧ | ៩៦ | ១០ | ២ | ១១៥ |
| ៣ | ល.ជ. មូរ សុខហួរ | | ២ | ៤២ | ៣២ | ៣ | ០ | ៧៩ |
| ៤ | ល.ជ. ឡោក ខេង | | ០ | ៥៤ | ១៣ | ០ | ៣ | ៧០ |
| ៥ | ឯ.ឧ កាទើ តូយ៉េប | | ២ | ៤៩ | ៥ | ០ | ២ | ៥៨ |
| ៦ | ឯ.ឧ ទេស ហ៊ាញ | | ០ | ៣៨ | ២ | ០ | ៨ | ៤៨ |
| ៧ | ល.ជ. លី គឹមលៀង | | ០ | ៣៨ | ១ | ០ | ៩ | ៤៨ |
| ៨ | ល.ជ. ជួញ សុផៃ | | ០ | ៣៧ | ២ | ១ | ៧ | ៤៧ |
| ៩ | ល.ជ. ត្រឹង ថាវី | | ៣ | ៣២ | ៧ | ០ | ៤ | ៤៦ |
| ១០ | ឯ.ឧ យន្ត ថារូ | | ០ | ២០ | ២១ | ១ | ០ | ៤២ |
| ១១ | ឯ.ឧ មុយ ចាត | | ០ | ២៩ | ៤ | ១ | ៦ | ៤០ |
| ១២ | ឯ.ឧ អ៊ូ ច័ន្ទឬទ្ធិ | | ២ | ១២ | ២៣ | ២ | ០ | ៣៩ |
| ១៣ | ឯ.ឧ ជីវ កត្តា | | ០ | ១៤ | ២២ | ០ | ០ | ៣៦ |
| ១៤ | ឯ.ឧ ប៉ាល់ សំអឿន | | ០ | ២៧ | ៥ | ០ | ២ | ៣៤ |
| ១៥ | ឯ.ឧ ស ខេង | | ០ | ២៦ | ៣ | ០ | ៣ | ៣២ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៦ | ឯ.ឧ ម៉ែន សុថាវិរិន្ទ្រ | | ០ | ១៩ | ១៣ | ០ | ០ | ៣២ |
| ១៧ | ល.ជ. គ្រួច សំអាន | | ១ | ១៦ | ១៤ | ០ | ១ | ៣២ |
| ១៨ | ឯ.ឧ ហូរ វ៉ាន់ | | ៧ | ៨ | ១៣ | ២ | ០ | ៣០ |
| ១៩ | ល.ជ. កែ សុវណ្ណរតន៍ | | ០ | ១១ | ១៥ | ២ | ០ | ២៨ |
| ២០ | ឯ.ឧ អន ស៊ុំ | | ០ | ១៨ | ៦ | ១ | ១ | ២៦ |
| ២១ | ឯ.ឧ សារី កោសល្យ | | ០ | ២០ | ២ | ០ | ១ | ២៣ |
| ២២ | ឯ.ឧ នុត រំដួល | | ៥ | ១ | ១៣ | ៣ | ០ | ២២ |
| ២៣ | ល.ជ. ម៉ែន សំអន | | ០ | ១៤ | ២ | ០ | ៤ | ២០ |
| ២៤ | ឯ.ឧ យឹម ឆៃលី | | ០ | ១៤ | ៣ | ០ | ០ | ១៧ |
| ២៥ | ឯ.ឧ យី វណ្ណដេត | | ០ | ២ | ១៤ | ១ | ០ | ១៧ |
| ២៦ | ឯ.ឧ ហ៊ូ ស្រី | | ០ | ៤ | ១៣ | ០ | ០ | ១៧ |
| ២៧ | ឯ.ឧ ជៀប ស៊ីវន | | ០ | ៤ | ១២ | ១ | ០ | ១៧ |
| ២៨ | សម្តេច ហ៊ុន សែន | | ០ | ១៦ | ០ | ០ | ០ | ១៦ |
| ២៩ | ល.ជ. ជូឡុង សូម្យ៉ា | | ០ | ១០ | ៦ | ០ | ០ | ១៦ |
| ៣០ | ឯ.ឧ យឹម សុវណ្ណ | | ០ | ៨ | ៨ | ០ | ០ | ១៦ |
| ៣១ | ឯ.ឧ ឈាង វុន | | ០ | ៧ | ០ | ០ | ៨ | ១៥ |
| ៣២ | ឯ.ឧ សុន ឆ័យ | | ០ | ២ | ១២ | ១ | ០ | ១៥ |
| ៣៣ | ឯ.ឧ លី ណារុន | | ០ | ១៣ | ១ | ០ | ១ | ១៥ |
| ៣៤ | ឯ.ឧ សួស កាណាន | | ៥ | ៩ | ០ | ០ | ១ | ១៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣៥ | ឯ.ឧ នឹម ច័ន្ទតារា | | ០ | ១៣ | ១ | ០ | ០ | ១៤ |
| ៣៦ | ឯ.ឧ យាន ហ៊ុនលី | | ០ | ៩ | ៤ | ០ | ១ | ១៤ |
| ៣៧ | ល.ជ. និន សាផុន | | ១ | ៧ | ៣ | ០ | ២ | ១៣ |
| ៣៨ | ឯ.ឧ ទ្រី ឈាងហ៊ួត | | ០ | ៩ | ១ | ០ | ២ | ១២ |
| ៣៩ | សម្តេច ហេង សំរិន | | ០ | ១១ | ១ | ០ | ០ | ១២ |
| ៤០ | សម្តេច គង់ សំអុល | | ០ | ៦ | ៦ | ០ | ០ | ១២ |
| ៤១ | ល.ជ. សោម គីមសួគ៌ | | ០ | ៨ | ៣ | ០ | ១ | ១២ |
| ៤២ | ឯ.ឧ សាឡេះ សេន | | ០ | ១២ | ០ | ០ | ០ | ១២ |
| ៤៣ | ឯ.ឧ ឡុង រី | | ០ | ៧ | ៣ | ២ | ០ | ១២ |
| ៤៤ | ឯ.ឧ អ៊ុំ សុខន | | ០ | ៥ | ៦ | ០ | ១ | ១២ |
| ៤៥ | ល.ជ. កែ ច័ន្ទមុនី | | ០ | ៣ | ៦ | ២ | ០ | ១១ |
| ៤៦ | ឯ.ឧ ជា ប៉ូច | | ០ | ៨ | ២ | ១ | ០ | ១១ |
| ៤៧ | ឯ.ឧ ប្រាក់ ធុច | | ០ | ៧ | ៣ | ០ | ១ | ១១ |
| ៤៨ | ឯ.ឧ គង់ បូរា | | ០ | ៨ | ២ | ០ | ០ | ១០ |
| ៤៩ | ឯ.ឧ ស្មាន ទៀត | | ០ | ៧ | ២ | ០ | ១ | ១០ |
| ៥០ | ឯ.ឧ លី សុន | | ០ | ៧ | ២ | ០ | ០ | ៩ |
| ៥១ | ឯ.ឧ ញឹម វណ្ណដា | | ០ | ៣ | ៤ | ០ | ២ | ៩ |
| ៥២ | ឯ.ឧ ចៅ សូផុន | | ០ | ៥ | ២ | ០ | ២ | ៩ |
| ៥៣ | ឯ.ឧ គឹមសួរ ភីរិទ្ធិ | | ០ | ១ | ៧ | ០ | ០ | ៨ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥៤ | ឯ.ឧ ស៊ុក អេង | | ០ | ៥ | ១ | ០ | ២ | ៨ |
| ៥៥ | ឯ.ឧ ប៊ិន ឈិន | | ០ | ៤ | ៣ | ០ | ១ | ៨ |
| ៥៦ | ឯ.ឧ សៅ រ៉ានី | | ០ | ៣ | ២ | ៣ | ០ | ៨ |
| ៥៧ | ឯ.ឧ សុខ អាន | | ០ | ៥ | ២ | ០ | ១ | ៨ |
| ៥៨ | ឯ.ឧ ជាម យៀប | | ០ | ២ | ៣ | ០ | ២ | ៧ |
| ៥៩ | ឯ.ឧ ប៉ែន បញ្ញា | | ០ | ២ | ៤ | ០ | ១ | ៧ |
| ៦០ | ឯ.ឧ ទៀ បាញ់ | | ០ | ៤ | ០ | ០ | ៣ | ៧ |
| ៦១ | ឯ.ឧ ចាយ បូរិន | | ០ | ៦ | ០ | ០ | ០ | ៦ |
| ៦២ | ល.ជ. ចែម សាវ៉ៃ | | ០ | ៦ | ០ | ០ | ០ | ៦ |
| ៦៣ | ឯ.ឧ ជាម ច័ន្ទនី | | ២ | ០ | ៤ | ០ | ០ | ៦ |
